អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Nov-2016, 15:09
CMS/CFO: Sann Rada

កំណត់ហេតុជាឈាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦

ម៉ោង ០៨:៥៩នាទី

សទនាការលើកទី៤៣៥

ចៅក្រមសាលាដំបូង៖

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
(Judge Claudia FENZ)

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
(Judge Jean-Marc LAVERGNE)

ចៅក្រម ឃួរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
(Judge Martin KAROPKIN)

ក្រឡាបញ្ជីសាលាដំបូង៖

កញ្ញា ជា ស៊ីវហ៊ាង

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

ការិយាល័យសហព្រះរាជអាជ្ញា៖

លោក នីកូឡាស គូមជែន
(Mr. Nicolas KOUMJIAN)

កញ្ញា សុង ឆវីន្ត

ជនជាប់ចោទ៖

លោក ឆួន ជា

លោក ខៀវ សំផន

មេធាវីការពារជនជាប់ចោទ ឆួន ជា៖

លោក វ៉ិចទ័រ កូប៉ៃ *(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

មេធាវីប្រចាំការលោក ខៀវ សំផន៖

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

(Mr. Calvin SAUNDERS)

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គីមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ឹន សុវ៉ន

ផ្នែកគ្រប់គ្រងតុលាការ៖

លោក អ៊ុច អរុណា

លោកស្រី សួ សុទ្ធាវី

បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

អ្នកនិយាយ	**ភាសា**
ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ)	ខ្មែរ
ចៅក្រម ក្លូឌា ហ្វេនស៍	អង់គ្លេស
លោក វ៉ិចទ័រ កូប៉ៃ	អង់គ្លេស
លោក នីកូឡាស គូមជែន	អង់គ្លេស
កញ្ញា សុង ឆវ័ន្ត	ខ្មែរ
លោក ពេជ អង្គ	ខ្មែរ
លោក វ៉ែន ពៅ	ខ្មែរ
លោកស្រី ម៉ារី ហ្គ្រីរ៉ូដ៍	បារាំង
កញ្ញា អង់តា ហ្គីសសេ	បារាំង
លោក ជិន សារឿន (2-TCW-1028)	ខ្មែរ

ឯបសម្ព័ន្ធ

ការសួរសំណួរទៅសាក្សី÷ លោក ជិន សារឿន (2-TCW-1028)

សួរដោយលោក វុិចទ័រ ក្ងប៉េ ផ្តើមពី..... ទំព័រ ២

សួរដោយលោក នីកូឡាស គូមជែន ..... ទំព័រ ២៦

សួរដោយកញ្ញា សុង ឆវ៉ន្ត ..... ទំព័រ ៤៨

សួរដោយលោក រ៉ែន ពៅ..... ទំព័រ ៥៣

សួរដោយលោកស្រី ម៉ារី ហ្ស៊ីរ៉ូដ៍ ..... ទំព័រ ៥៧

កិច្ចដំណើរការនីតិវិធី

(ចៅក្រមចូលក្នុងបន្ទប់សវនាការ)

[០៨:៥៩:៥៦]

ប្រធានអង្គជំនុំ៖

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ជិន សារឿន បញ្ចប់។

ក្រឡាបញ្ជីសវនាការកញ្ញា ស៊ីវហ៊ាង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។

ក្រឡាបញ្ជី៖

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក ន្ឋន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក ន្ឋន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តនៅថ្ងៃនេះ គឺលោក ជិន សារឿន។ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះមិនមានសាក្សីបម្រុងទេ លោកប្រធាន។ សូមមអរគុណ។

[០៩:០១:២១]

ប្រធានអង្គជំនុំ៖

អរគុណកញ្ញា ស៊ីវហ៊ាង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ ន្ឋន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ ន្ឋន ជា ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថាដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរ មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦។

មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិ

នេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់នឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ ន្ឋន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក ន្ឋន ជា នៅថ្ងៃនេះថា មានអាការៈឈឺខ្នង ឈឺចង្កេះវាំរ៉ែ អង្គុយឃ្លរមិនបាន និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក ន្ឋន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:០៣:០៥]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ ន្ឋន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ ន្ឋន ជា អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្ត អង្គជំនុំជម្រះផ្តល់វេទិកាដល់មេធាវីការពារក្តីលោក ន្ឋន ជា តាំងសំណួរលើសាក្សី ជិន សារឿន។ សូមអញ្ជើញ!

លោក វ៉ិចទ័រ កូប៉ែ៖

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរសហការីទាំងអស់ ជម្រាបសួរលោកសាក្សី។ លោកប្រធាន តាមធម្មតាពេលចាប់ផ្តើមសួរសំណួរ យើងមិនបានប្រើពេលវេលាពេញលេញទាំងពីរវគ្គនោះទេ។ ហើយបន្ទាប់មកទើបក្រុម ខៀវ សំផន នឹងសួរក្រោយគេ។

ការតាំងសំណួរដោយសហមេធាវីការពារក្តី

សួរដោយលោក វ៉ិចទ័រ កូប៉ែ៖

ស៖ ខ្ញុំគឺជាសហមេធាវីអន្តរជាតិការពារលោក ន្ឋន ជា ខ្ញុំនឹងសួរសំណួរលោកបន្តទៅទៀតនៅ

ព្រឹកនេះ។ ខ្ញុំនឹងសួរបន្តពីសំណួរដែលលោកប្រធានអង្គជំនុំជម្រះបានសួរលោកកាលពីម្សិលមិញរួចមក ហើយនោះ គឺជាពិសេសពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍ជាមួយនឹងសហចៅក្រមស៊ើបអង្កេត ថាតើមានសម្ភាសលោកដែរទេ លោកថា មានសម្ភាសលោក<ប្រហែលនៅឆ្នាំ២០០០>។ បាទ <ប្រហែលមិនមែន>អ្នកស៊ើបអង្កេត<ពីតុលាការនេះទេ ដែលបានសម្ភាសន៍លោកនោះ> ក៏ប៉ុន្តែ<អាចជា>អង្គការមួយហៅថា "អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា" <> អ៊ីចឹងមែនទេ?

[០៩:០៥:២៧]

លោក ជិន សារឿន៖

ជ៖ បាទ បានសម្ភាសដែរហើយ។

ស៖ ក៏ប៉ុន្តែលោកនៅចាំទេ មានមនុស្សម្នាក់ឈ្មោះ ហ៊ុយ វណ្ណៈ នោះ គឺថាបានទៅសម្ភាសលោក គឺគាត់ធ្វើការឲ្យអង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះថា "មជ្ឈមណ្ឌលឯកសារកម្ពុជា" ត្រឹមត្រូវដែរទេ?

ជ៖ បាទ ខ្ញុំមិនចាំឈ្មោះទេ។ គ្រាន់ថា កាលនោះមានខាងអង្គការទៅសម្ភាសជាមួយខ្ញុំដល់កន្លែងមែន។

ស៖ សូមអរគុណលោក។ ម្សិលមិញនេះ នៅពេលប្រធានអង្គជំនុំជម្រះសួរលោកកើតថ្ងៃណា លោកថាកើតនៅថ្ងៃទី០៥<មករា>១៩៥៩ ក៏ប៉ុន្តែនៅទំព័រចុងក្រោយនៃកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ E3/10578 លោកបានឆ្លើយថា អត្តសញ្ញាណប័ណ្ណរបស់លោកនេះ គឺមិនត្រឹមត្រូវទេ លោកមិនមែនកើតនៅឆ្នាំ១៩៥៩ទេ តាមការពិតឆ្នាំកំណើតមែនទែននោះ គឺលោកកើតនៅក្នុង១៩៥៤ ទៅវិញទេ។ ត្រឹមត្រូវដែរទេ?

ជ៖ បាទ សំខាន់គឺអត្តសញ្ញាណរបស់ខ្ញុំជាសញ្ជាតិខ្មែរ កាលជាសញ្ញាសម្គាល់ឆ្នាំថ្ងៃខែឆ្នាំកំណើត គឺលើអត្តសញ្ញាណរបស់ខ្ញុំ។

[០៩:០៧:២៧]

ស៖ ចំណុចនេះ ខ្ញុំយល់ហើយ ក៏ប៉ុន្តែខ្ញុំសួរថាតើលោកពិតជាកើតនៅឆ្នាំ១៩៥៤មែនទេ?

ជ៖ បាទ ខ្ញុំកើតឆ្នាំ១៩៥៩។ ក្រែងថាកាលនោះខាងអ្នកទៅសម្ភាសហ្នឹង គាត់ស្តាប់មិនបានអីមិនដឹងទេ ព្រោះកាលនោះមនុស្សច្រើន។ ប៉ុន្តែខ្ញុំ ខ្ញុំដាក់ថាឆ្នាំ១៩៥៩ ហើយជាភស្តុតាងគឺសំខាន់គឺអត្ត-សញ្ញាណរបស់ខ្ញុំ។

សៈ បាទ ខ្ញុំបន្តទៅមុខទៀតចុះ។ ខ្ញុំ<នឹង>សួរសំណួរជាច្រើន<>អំពីពេលវេលាដែលលោកនៅឯមណ្ឌលគិរី គឺពេលណាមួយនៅក្នុងឆ្នាំ១៩៧៥ ឬក៏អាច១៩៧៦ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះជាសង្ខេបបានទេ មុននឹងលោកទៅមណ្ឌលគិរី តើលោកធ្វើអ្វីដែរ?

ជៈ បាទ ខ្ញុំសូមឆ្លើយលើសំណួរនេះ។ កាលមុនខ្ញុំឡើងមកមណ្ឌលគិរីនេះ ឆ្នាំ១៩៧២-៧៣ មុននឹងរំដោះហ្នឹង គឺខ្ញុំនៅបួស ជាសង្ឃ ជាសង្ឃ។ ហើយដល់ឆ្នាំ៧៥ ត្រូវអង្គការផ្សឹកខ្ញុំឲ្យសឹក ឲ្យសឹកជាឧបាសកហ្នឹងមក។ រួចហើយបានខាងនុំង អង្គការឃុំគេបញ្ជូនខ្ញុំមកមណ្ឌលគិរី។

សៈ ហើយមុនពេលលោកទៅមណ្ឌលគិរី តើលោកមានធ្លាប់ធ្វើការមួយរយៈពេលខ្លីណានៅក្រចេះដែរទេ?

ជៈ បាទ មុននឹងខ្ញុំឡើងទៅមណ្ឌលគិរី គឺខ្ញុំបាននៅហាត់ជាអង្គភាពយោធា ហាត់រយៈ៣ខែដែរ ហាត់នៅនឹងខេត្តក្រចេះហ្នឹង មុននឹងឡើងទៅមណ្ឌលគិរី។

សៈ នៅពេលដែលលោកទៅដល់មណ្ឌលគិរី តើលោកធ្វើអ្វីនៅទីនោះ? តើលោកអាចរៀបរាប់អំពីសកម្មភាពរបស់លោកនៅឯមណ្ឌលគិរីបានទេ ក្រោយពេលលោកទៅដល់ទីនោះ?

[០៩:១០:២៩]

ជៈ បាទ ខ្ញុំសូមបញ្ជាក់អំពីបញ្ហានេះ គឺខ្ញុំធ្វើដំណើរចេញពីខេត្តក្រចេះទៅ គឺទៅដល់ឃុំមួយបាទហៅថា ឃុំសុខសាន្ត។ កាលនោះខ្ញុំជាកងចល័ត គឺមិនអាចទាន់ពេញសិទ្ធិជាអង្គភាពយោធានៅឡើយទេ គឺជាកងចល័ត។ ដូច្នេះក្នុងការកងចល័តនេះ ធ្វើការពលកម្ម ជាស្រែ ជាចម្ការ។ ហើយការធ្វើនេះ គឺវាមានពេលវេលាដូចខាងក្រុមស៊ើបអង្កេតទៅសួរខ្ញុំអ៊ីចឹង គឺថាពេលព្រឹកឡើងគឺហាត់ប្រាណម៉ោងប្រាំ គឺគេផ្លុំកញ្ចែហាត់ប្រាណ។ ម៉ោងប្រាំមួយ គឺចាប់ផ្តើមលុបលាងមាត់ ម៉ោងប្រាំមួយកន្លះ ហូបបាយ អ៊ុំ! ហូបបបរ បាទហូបបបរ។ រួចម៉ោង៧ប្រាំពីរ ចាត់ចុះទៅធ្វើការពលកម្មទៀត។

សៈ តាមលោកនៅចងចាំនោះ តើ<ពេលណា>លោក<>បានក្លាយទៅជាកងទ័ព<>នៅឯមណ្ឌលគិរី?

ជៈ បាទ បញ្ហានេះគឺពេលខ្ញុំក្លាយជាកងទ័ព ដល់ឆ្នាំ១៩៧៩ បានក្លាយជាកងទ័ព។

សៈ ខ្ញុំស្តាប់ឮតាមការបកប្រែ គឺ១៩៧៩។ តើលោកបានក្លាយជាកងទ័ពដែលគេជ្រើសរើសកងទ័ពថ្មី កងពលថ្មី ៩២០ហ្នឹង នៅក្នុងឆ្នាំ១៩៧៦ មែនទេ?

ជៈ បាទ គឺបញ្ហាហ្នឹងខាង៩២០ ជ្រើសរើសជាកងទ័ព ប៉ុន្តែនៅជាមួយកងទ័ព ប៉ុន្តែជា៧កង

ចល័តនៅឡើយទេ។ ឆ្នាំ៧៦ហ្នឹងគឺជាកងចល័ត មិនមានអាវុធកាន់ទេ គ្រាន់តែជានៅក្នុងអង្គភាពកងទ័ព គឺកងទ័ព៩២០ហ្នឹងគេអ្នកគ្រប់គ្រង។ បាទ សូមអស់។

សៈ តើនៅពេលណាដែលលោកក្លាយទៅជាកងទ័ពពេញសិទ្ធិនៃកងពល៩២០នោះ គឺចង់សួរថាតើនៅពេលណាដែលគេប្រគល់អាវុធឲ្យលោកកាន់កាប់នោះ?

[០៩:១៣:២៧]

ឆៈ បាទ នៅក្នុង៩២០ ខ្ញុំអត់ទាន់បានទទួលបានអាវុធទេ។ ទាល់តែខ្ញុំបានទៅដល់ខេត្តមណ្ឌលគិរី បានមានវៀតណាមចូលៗមកដីកម្ពុជា បានអង្គភាពតំបន់ហ្នឹងគេបំពាក់អាវុធឲ្យ។

សៈ មុននឹងខ្ញុំឈានចូលទៅនិយាយអំពីតួនាទីរបស់លោក ដែលជាកងទ័ពតំបន់នោះ ខ្ញុំសូមសួរបន្តអំពីកងពល៩២០ បន្តទៅទៀត។ តើលោកនៅក្នុងវរសេនាធំលេខ៩៣ មែនទេ?

ឆៈ បាទ កាលហ្នឹងខ្ញុំនៅ៩២០ នៅវរសេនាធំលេខ៩៣។

សៈ តើលោកនៅនឹកឃើញទេ អ្នកណាជាមេបញ្ជាការកងពល៩២០?

ឆៈ បាទខ្ញុំនៅចាំច្បាស់ គឺកងពល៩២០ ប្រធានគឺ ឈិន ឈ្មោះ ឈិន ហើយអនុឈ្មោះ សយ។ ៩២០ គេហៅថា តាឈិន, តាសយ ហ្នឹងហើយ។

សៈ តើលោកអាចឆ្លើយបានថា កងពល៩២០ ពីមុនមកគឺជាអតីតកងពលរបស់ភូមិភាគឧត្តរឬក៏អត់ទេ?

ឆៈ បាទ បញ្ហានេះខ្ញុំអត់យល់ អត់យល់ មិនដឹងជាស្ថិតនៅខាងណាទេ ព្រោះកាលខ្ញុំឡើងមកឃើញ ខ្ញុំមកដល់ទីក្រុងភ្នំពេញហ្នឹងគឺឈ្មោះ ឈិន, ឈ្មោះ សយ ហ្នឹងទៅយកមក ហើយក៏ខ្ញុំអត់ដឹងថាកងពល៩២០ស្ថិតនៅភូមិភាគណា ខ្ញុំអត់ដឹង។

សៈ តើលោកដឹងថាទីបញ្ជាការកងពល៩២០ហ្នឹងស្ថិតនៅកន្លែងណាទេ?

[០៩:១៦:១៦]

ឆៈ បាទ កាលហ្នឹងគឺទីបញ្ជាការ៩២០ស្ថិតនៅឃុំសុខសាន្ត។ ឃុំសុខសាន្តក្បែរអូរច្បារ ដែលចំណុច អ៊ុយ.តេ.អឹម ខ្ញុំអត់បានយល់ទេ ប៉ុន្តែកាលដែលខ្ញុំឡើងពីក្រចេះទៅដល់មណ្ឌលគិរី គឺទីបញ្ជាការគេគឺនៅសុខសាន្ត – ឃុំសុខសាន្ត។

សៈ តើកងពល៩២០ហ្នឹងមានទីតាំងរបស់ខ្លួន ឬមូលដ្ឋានរបស់ខ្លួននៅភ្នំពេញដែរទេ?

ឆៈ បាទ បញ្ហាហ្នឹងខ្ញុំអត់ៗយល់ទេ បាទអត់យល់។

សៈ នៅពេលដែលលោកជាកងទ័ពកងពល៩២០ តើលោកមានដឹងថា មានទំនាក់ទំនងអ្វីរវាងកងពល៩២០ ជាមួយកងពល៣១០ ឬក៏និងជាមួយកងពល៤៥០ដែរទេ?

ជៈ បាទ បញ្ហានេះ ក៏ខ្ញុំអត់ៗយល់ដែរ អត់ដឹង អត់ដឹងគាត់ទំនាក់ទំនងខាងណាទេ ព្រោះខ្ញុំជាកម្លាំងថ្មី បាទជាកម្លាំងថ្មី។ និយាយទៅបញ្ជាក់ឲ្យខាងមេធាវីយល់ថា ខ្ញុំចេញមកជាពីប្រជាជន ជា បើនិយាយទៅជាកុមារកាលនុំង ត្រូវវ័យជំទង់ អីចឹងគឺក្នុងចលនានោះ អត់បានធ្វើទ័ពធ្វើអីទេ គឺនៅជាប្រជាជន។ អីចឹងគឺដល់គេយកខ្ញុំមកដល់ភ្នំពេញ -- យកមកដល់មណ្ឌលគិរីគឺអត់ដឹងថា អតីតរបស់កងពលហ្នឹងទំនាក់ទំនងជាមួយកងពលណា ជាមួយកងពលណា ខ្ញុំអត់ដឹងទេបាទ។ សូមជ្រាបបញ្ហា។

សៈ តើលោកចាំឈ្មោះមេបញ្ជាការកងពល៣១០ និងកងពល៤៥០ដែរទេ? គឺមេបញ្ជាការ គឺលេខាកងពលទាំងពីរ <ដែលមានតួនាទីដូច តាឈិន ដែរ>?

ជៈ បាទ ដូចខ្ញុំបានបញ្ជាក់ខាងដើមហើយថា ខ្ញុំអត់បានស្គាល់ទេ។

សៈ ចុះបើខ្ញុំនិយាយពីឈ្មោះមនុស្សពីរនាក់ ឈ្មោះ អឿន និង ឈ្មោះ សឿង តើលោកអាចនឹកឃើញ ឬក៏ស្គាល់ពួកគាត់ទាំងពីរទេ?

[០៩:១៩:០២]

ជៈ បាទ បញ្ហានេះដូចខ្ញុំបញ្ជាក់ខាងដើមហើយថា មិនដែលស្គាល់ មិនដែលទំនាក់ទំនងទេ។

សៈ តើមានពេលណាមួយ លោកបានក្លាយទៅជាមេបញ្ជាការកងអនុសេនាធំចំណុះឲ្យកងពល៩២០នេះដែរទេ?

ជៈ បាទ ខ្ញុំដូចបញ្ជាក់ខាងដើមដែរ កាលនោះខ្ញុំទទួលតែត្រឹមប្រធានអនុសេនាធំ ជាប្រធានអនុសេនាធំរបស់វរសេនាធំ៩៣ហ្នឹង។

សៈ ខ្ញុំសូមអានសម្រង់មួយឲ្យលោកស្តាប់ ដែលលោកឆ្លើយជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/10578 អង់គ្លេស 01249759, ខ្មែរ 00042520, បារាំង 01249782។ លោកបានឆ្លើយថា "<ខ្ញុំ>ស្ថិតនៅក្នុងវរសេនា<តូច>លេខ៩៣។ គឺមានវរសេនា<តូច>៩៣, ៩២ និង៩១។ <វរសេនាធំមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ។> ដោយសារថា ខ្ញុំនេះជាកងទ័ពជ្រើសរើសថ្មី អីចឹងខ្ញុំបានក្លាយត្រឹមតែមេបញ្ជាការកងអនុសេនាធំតែប៉ុណ្ណោះ។" តើចម្លើយរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ត្រឹមត្រូវដែរទេ?

ជៈ បាទ កាលនោះខាងស្រាវជ្រាវ ខ្ញុំ គាត់ទៅសម្ភាសខ្ញុំយូរណាស់ដែរហើយ ក៏ប៉ុន្តែបើតាម

ភារកិច្ចខ្ញុំជាក់ស្តែងហ្នឹង គឺប្រធានអនុសេនាធំ។

សៈ តើលោកនៅនឹកឃើញទេថា មានឃុទ្ធជនប៉ុន្មាននាក់ដែរ ដែលស្ថិតនៅក្រោមការបញ្ជារបស់លោក? ដោយសារថាលោកនេះ គឺជាមេបញ្ជាការកងអនុសេនាធំ តើកងទ័ពនៅក្នុងកងអនុសេនាធំហ្នឹង មានប៉ុន្មាននាក់ដែរ?

[០៩:២២:០២]

ឆៈ បាទ កាលខ្ញុំនៅគ្រប់គ្រងកម្លាំងហ្នឹង គឺចំនួន៨០នាក់។

សៈ តើឋានន្តរសក្តិត្រឹមមេបញ្ជាការកងអនុសេនាធំនេះ គឺថាលោកបានទទួលតំណែងខ្ពស់បំផុតតែត្រឹមហ្នឹងឬ មុននឹងលោកចូលទៅធ្វើជាកងទ័ពតំបន់?

ឆៈ បាទកាលនៅនឹងកងចល័ត៩២០ គឺខ្ញុំទទួលបានតែត្រឹមហ្នឹងឯង ត្រឹមប្រធានអនុសេនាធំ។

សៈ ចម្លើយរបស់លោកគឺ ERN 01249753, ខ្ទែរ 00042514, បារាំង 01249777 ដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺលោកឆ្លើយថា ពីដើមឆ្នាំ១៩៧៧មក គឺលោកបានក្លាយទៅជាកងទ័ពតំបន់នៅក្នុងកងវរសេនាតូច៥៣។ ត្រឹមត្រូវដែរទេ?

ឆៈ បាទ កាលដល់ខ្ញុំឡើងទៅដល់មណ្ឌលគិរី ខ្ញុំ គេត្រូវបញ្ជូនទៅនៅ មិនមែនអនុសេនាធំទេ គឺវរសេនាតូចលេខ៥២ បាទ៥២។

សៈ តើត្រឹមត្រូវដែរទេ <កងកម្លាំង>នៅក្នុងតំបន់<>នេះ គឺថាមានវរសេនាធំទាំងអស់ប្រាំមាន៥១, ៥២, ៥៣, ៥៤ និង ៥៥ តើអ៊ីចឹងមែនទេ?

ឆៈ បាទ ពិតមែនហើយ។ ៥១, ៥២, ៥៣, ៥៤, ៥៥ នេះគឺរយៈកាលដែលខ្ញុំចូលជាកងទ័ពក្នុងឆ្នាំ៩៦, ៩៧ ដែលខ្ញុំត្រៀមនឹងសមាហរណកម្មហើយទេហ្នឹង។ វាមានអង្គភាពមកពីភ្នំដងរែកមក វាមាន៥១, ៥២ មិនមែន -- ៥៣, ៥៤, ៥៥។ ហ្នឹងគឺក្នុងឆ្នាំ៩៦ហើយទេ។

[០៩:២៥:១៥]

សៈ ប្រហែលជាខ្ញុំយល់ចម្លើយលោកមិនបានច្បាស់លាស់ទេ តាមរយៈការបកប្រែនេះ។ លោកទើបតែបញ្ជាក់ថា លោកបានក្លាយទៅជាទ័ពតំបន់នៅដើមឆ្នាំ១៩៧៧ គឺថាលោកជាកងទ័ពចំណុះឲ្យវរសេនាតូច <ឬវរសេនាធំលេខ>៥២។ តើ<ត្រឹមត្រូវទេ ដែលថា>កងទ័ពតំបន់នៅក្នុងឆ្នាំ<១៩៧៧> គឺថាវាមានវរសេនាធំបួនផ្សេងទៀត បន្ថែមទៅលើវរសេនាធំ<លេខ៥២>របស់លោកនេះ។ តើអ៊ីចឹងមែនទេ?

ជៈ បាទ ខ្ញុំសូមឆ្លើយបញ្ជាក់ដល់លោកប្រធាន ហើយនិងការសួរនេះ គឺខ្ញុំសូមឆ្លើយថាអ៊ីចេះ កាលពីឆ្នាំ១៩៧៦, ៧៧នេះ អង្គភាពតំបន់ហ្នឹង គឺមានតែពីរវរសេនាតូចទេ វរសេនាតូច៥០១ និងវរ-សេនាតូច៥០២ ប៉ុន្តែយើញក្នុងឯកសារគឺដាក់វរសេនាតូច៥២។ អ៊ីចឹងខ្ញុំអាន៥២អ៊ីចឹងទៅ។ អ៊ីចឹងកាលពី៧៦ និង៧៧ហ្នឹង មានតែពីរវរសេនាតូចទេក្នុងតំបន់១០៥ ក្នុងខេត្តមណ្ឌលគិរីហ្នឹង។

សៈ ខ្ញុំយល់ហើយ ហើយលោកនៅក្នុងវរសេនាតូច៥០២។ តើនៅក្នុងវរសេនាតូច៥០២នេះ លោកមានតួនាទីអ្វីដែរ ឬគ្រាន់តែជាយុទ្ធជនធម្មតាទេ?

ជៈ បាទ កាលនុ៎ងនៅវរសេនាតូច៥០២ ដែលហៅក្នុងឯកសារហ្នឹងដាក់ថា "៥២"ហ្នឹង គឺខ្ញុំទទួលភស្តុភារអនុសេនាធំ ភស្តុភារៗ ភស្តុភារអនុសេនាធំ គឺអាហ្នឹងគេជូនខាងខ្ញុំទៅនៅព្រំដែនហើយនៅក្រង់តេះ។ បាទ សូមបញ្ជាក់ប៉ុណ្ណឹង។

សៈ ហើយនៅឯព្រំដែននោះ លោកមានតួនាទីធ្វើអ្វីដែរ នៅក្នុងកងវរសេនាតូច៥០២នេះ?

ជៈ បាទ ដូចខ្ញុំបានបញ្ជាក់ខាងដើមដែរហើយ។ ក្នុងចន្លោះហ្នឹង គឺទាំងនៅ៩២០ រហូតមកដល់តំបន់១០៥ គឺមិនទាន់សិទ្ធិកាន់អាវុធទេ គឺខ្ញុំស្ថិតនៅក្នុងកងចល័ត។ កងចល័តហ្នឹង គឺបានន័យថា មាន នារី មានបុរសហ្នឹង គឺសម្រាប់តែបង្កបង្កើនផល សម្រាប់ឲ្យកងទ័ពដែលគេនៅព្រំដែន។ មិនទាន់មានពេញសិទ្ធិថាជាៗយោធាពេញសិទ្ធិទេ ដល់នោះ គ្រាន់តែនៅក្នុងអង្គភាពយោធាហ្នឹង។

[០៩:២៨:៤៣]

សៈ ខ្ញុំនឹងត្រឡប់មកសួរចំណុចនេះនៅពេលក្រោយ។ សំណួរចុងក្រោយ ពាក់ព័ន្ធកងទ័ពតំបន់នេះ តើលោកធ្លាប់ឮមេបញ្ជាការម្នាក់ឈ្មោះ ឡាន់ ដែរទេ?

ជៈ បាទ គ្រាន់តែឮ ប៉ុន្តែអត់ស្គាល់ទេ ព្រោះ ឡាន់ ហ្នឹងគឺប្រធានវរសេនាតូចលេខដែលគេអានថា "៥០១"។ ហើយដូចខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹងថា ក្នុងតំបន់១០៥នេះ ខេត្តមណ្ឌលគិរីនេះ វាមានពីរវរសេនាតូច ហើយ ឡាន់ ហ្នឹងគឺនៅវរសេនាតូច៥០១។

សៈ ចុះអ្នកណាជាមេបញ្ជាការកងវរសេនាតូចរបស់លោក? ឬសួរម្យ៉ាងទៀត ថាតើអ្នកណាដែលមានឋានៈស្មើនឹង ឡាន់ ដែរ ដែលគ្រប់គ្រងអង្គភាពរបស់លោកនោះ?

ជៈ បាទ ខ្ញុំសូមបញ្ជាក់ថា ប្រធានអង្គភាពរបស់ខ្ញុំហ្នឹងគឺឈ្មោះ ខាំ វៀង។ ហើយសូមនិយាយឲ្យច្បាស់ទៅដើម្បីកុំឲ្យអង្គប្រជុំចេះឆ្ងល់ច្រើន គឺថា កាលពីមុនខ្ញុំឡើងមកលើ មកនៅមណ្ឌលគិរីហ្នឹង តំបន់១០៥ មានតែមួយវរសេនាតូចទេ គឺ ឡាន់ ប្រធាន, ខាំ វៀង ហ្នឹងអនុ។ ដល់តែកម្លាំងខ្ញុំឡើងមក

ថែមមក ឡាន់ ហ្នឹងប្រធានវរសេនាតូច៥០១, ខាំ វៀង ដែលជាអនុហ្នឹងគឺឡើងប្រធានវរសេនាតូច៥២ បាទ៥២។ គ្រាន់តែខ្ញុំកាលមុន ខ្ញុំដូចមិនចាំដែរ ខ្ញុំថា៥០២ ប៉ុន្តែដល់ឃើញក្នុងឯកសារដាក់ ៥២ អីចឹងថា ៥២ តែម្តងទៅ។

សៈ សូមអរគុណដែលលោកបានបញ្ជាក់បំភ្លឺ។ លោកសាក្សី លោកបានលើកឡើងអំពីតំបន់<១០៥ ដែលជាតំបន់ស្វយ័តនៅខេត្ត>មណ្ឌលគិរី។ តើអ្នកណាគេជាប្រធានតំបន់<១០៥>? តើអ្នកណាគេគ្រប់គ្រងខេត្តមណ្ឌលគិរី នៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩?

[០៩:៣១:១៧]

ជៈ បាទ តាមខ្ញុំឡើងមកដល់ដំបូង គឺមានឈ្មោះ ហំ ប៉ុន្តែពាក្យក្រៅគេហៅ ហម ដល់តែអក្សរឃើញថាឈ្មោះ ហម បាទហម។ ហម ជាប្រធាន, ខាំ ភូន ជាអនុប្រធាន។ ហើយក្រោយមក ទៀត បានឈ្មោះ សៅ សារុន ប្រធាន ហើយនិង អន ស៊ី អនុ រហូតមកដល់៧៩ គាត់។

សៈ តើលោកធ្លាប់ឮឈ្មោះ បុគ្គលម្នាក់ឈ្មោះ យ៉ា ហៅ ណៃ សារ៉ាន់ ដែរឬទេ?

ប្រធានអង្គជំនុំ៖

លោកសាក្សីចាំភ្លើងមីក្រូហ្វូនប្រតិបត្តិការសិន ចាំឆ្លើយ។

លោក ជិន សារឿន៖

ជៈ បាទ ឈ្មោះហ្នឹង គឺខ្ញុំដូចមិនដែលបានស្គាល់ទេ។

សួរដោយលោក វ៉ិចទ័រ ភូប៉ែ៖

សៈ ដើម្បីឲ្យខ្ញុំយល់ឲ្យបានត្រឹមត្រូវ តើ ហម ជាប្រធានតំបន់នោះរួចហើយឬនៅ<>ពេលដែលលោកទៅដល់មណ្ឌលគិរី<ជាលើកដំបូងនោះ>?

ជៈ បាទ មុនខ្ញុំទៅដល់មណ្ឌលគិរី ពេលខ្ញុំឡើងពីក្រចេះទៅដល់ខេត្តមណ្ឌលគិរីហ្នឹងគឺ ហម ហ្នឹងជាប្រធាន ដឹងថាឈ្មោះ ហម ហ្នឹងជាប្រធាន ប្រធានតំបន់ កាលនោះគេហៅថា “ប្រធានតំបន់”។

សៈ សូមអរគុណដែលលោកបានបញ្ជាក់បំភ្លឺ។ នៅពេលនេះខ្ញុំសួរឋានៈក្រោមៗអីវិញម្តង នៅក្នុងតំបន់<១០៥>។ តើលោកអាចជម្រាបអង្គជំនុំជម្រះបានដែរឬទេ នរណាទទួលបន្ទុកកោះញែកនៅក្នុង <តំបន់ ១០៥>នេះ?

[០៩:៣៣:៥៨]

ជៈ បាទ ក្នុង៥០១ហ្នឹងគឺចំពោះឈ្មោះ ខ្ញុំអត់ដឹងទេ ក៏ប៉ុន្តែគ្រាន់ថា ភារកិច្ចរបស់វរសេនាតូច

៥០១ហ្នឹង ទទួលការពារស្រុកកោះញែកតែម្តង។ ឈ្មោះ ឡាន់ ហ្នឹងទទួលខុសត្រូវ។

សៈ ប្រហែលជាអាចមានបញ្ហានៃការបកប្រែ។ ក៏ប៉ុន្តែខ្ញុំសូមសួរបញ្ជាក់ តើនរណាជាប្រធាន <ស្រុក>កោះញែក? ខ្ញុំអត់បានលើកឡើងអំពីមេបញ្ជាការនៅក្នុងផ្នែកយោធានោះទេ គឺខ្ញុំចង់សួរខាងអ្នកគ្រប់គ្រងស្រុកកោះញែកនេះ តើនរណាជាប្រធានស្រុក<ឬអភិបាលស្រុក>កោះញែកនៅពេលដែលលោកទៅដល់ទីនោះ?

ជៈ បាទ អាហ្នឹងគឺផ្នែកខាងរដ្ឋបាល គឺតាមខ្ញុំដឹងកាលនោះ គឺឈ្មោះ ស្វាយ ប្រធាន ប្រធានស្រុក។ ប្រធានស្រុក គ្រប់គ្រងស្រុកគឺឈ្មោះ ស្វាយ តែត្រកូលខ្ញុំអត់ស្គាល់ដឹងទេ ព្រោះខ្ញុំជាខ្មែរ ហើយគាត់ជាជនជាតិ។ អ៊ីចឹងហើយទើបតែមកស្គាល់គ្នា ប៉ុន្តែគ្រាន់ដឹងថាឈ្មោះ ស្វាយ ហ្នឹងប្រធានស្រុកកោះញែក។

សៈ មុននេះបន្តិច លោកលើកឡើងបុគ្គលម្នាក់ឈ្មោះ ខាំ ភូន ដែលថាជាអនុប្រធានតំបន់ <១០៥>។ តើ ខាំ ភូន នេះមានទំនាក់ទំនងសាច់ញាតិគ្រួសារជាមួយនឹង ស្វាយ ហ្នឹងយ៉ាងម៉េចដែរ? តើអ្នកទាំងពីរ ស្វាយ និង ខាំ ភូន នេះមានជាប់សែស្រឡាយនឹងគ្នាដែរឬទេ?

ជៈ បាទ បញ្ហាហ្នឹងតាមខ្ញុំដឹងគឺ ខាំ ភូន ហ្នឹងជាឪពុកមារបស់ ស្វាយ ហ្នឹង។ អ៊ីចឹងគឺទំនាក់ទំនងគ្នាជាក្មួយនិងពូ។ ខ្ញុំមិនច្បាស់ដែរទេ ប៉ុន្តែខ្ញុំឮអង្គភាពខ្ញុំនិយាយអ៊ីចឹង ថា ខាំ ភូន ហ្នឹងជាឪពុកមា ស្វាយ ហ្នឹងគឺក្មួយ។

[០៩:៣៦:៣៧]

សៈ ខ្ញុំយល់ ក៏ប៉ុន្តែខ្ញុំនឹងមកសួរចំណុចនេះហ្នឹងឡើងវិញ។ ជាពិសេស ថាតើមានអ្វីកើតឡើងចំពោះ តាហម, ខាំ ភូន និង ស្វាយ។ មុនពេលខ្ញុំសួរសំណួរទាំងអស់នោះ ខ្ញុំសូមអនុញ្ញាតសួរលោកសំណួរមួយចំនួនជាមុនសិន អំពីទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាមនាពេលនោះ។ តើលោកអាចជម្រាបប្រាប់អង្គជំនុំជម្រះបានដែរឬទេ តើស្ថានការណ៍នៅតាមព្រំដែនកម្ពុជាវៀតណាមនាពេលនោះ មានអ្វីកើតឡើង ជាពិសេសនៅចុងឆ្នាំ៧៦ និងដើមឆ្នាំ៧៧ ពាក់ព័ន្ធទៅនឹងបញ្ហាកងទ័ពនាពេលនោះ? តើលោកនៅចាំទេ មានអ្វីកើតឡើង?

ជៈ បាទ បញ្ហានេះ គឺក្នុងឆ្នាំ៧៦ និង៧៧ហ្នឹង គឺដូចមិនទាន់មានបញ្ហាអីទេ គឺខាងព្រំដែន។ បើខាងទីរួមស្រុក អាហ្នឹងគឺអាចមានបញ្ហាខ្លះមិនដឹងទេ ប៉ុន្តែព្រំដែនអត់ទាន់មានបញ្ហាទេ គឺក្នុងដើមឆ្នាំ៧៦ និងដើម អ៎ា! ចុងឆ្នាំ៧៦ និងដើមឆ្នាំ៧៧។

ស: តើលោកនៅចាំទេ ស្ថានការណ៍ហ្នឹងកាន់តែវាដុនដាប និងធ្ងន់ធ្ងរនៅពេលណាទៅ? ហើយការប៉ះទង្គិចរវាងកងទ័ពរបស់ខ្មែរកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមនេះ គឺស្ថានភាពហ្នឹងដុនដាបនាពេលណា?

ឆ: បាទ ស្ថានភាពរវាងកម្ពុជាប្រជាធិបតេយ្យ និងខាងកងទ័ពវៀតណាមហ្នឹង គឺចាប់ពី៧៩ ឡើងទៅ។

[០៩:៣៩:០១]

ស: នៅក្នុងការសម្ភាស ឌី.ស៊ី.ខេម ជាមួយលោក អង់គ្លែស <01249767>, ខ្មែរ 00042 526 អត់មានជាភាសាបារាំងទេ។ គេសួរសំណួរទៅកាន់លោក អ្នកសម្ភាសបានសួរសំណួរលោក ហើយសំណួរនោះគឺ: "រវាងកម្ពុជានិងវៀតណាម តើអ្នកណាគេវ៉ៃគេមុន ហើយដែលនាំទៅដល់មានសង្គ្រាមនោះ?" តើលោកនៅចាំថា <លោកឆ្លើយយ៉ាងម៉េចទេ ពេល>គេសួរលោកសំណួរហ្នឹង<>?

ឆ: បាទ កាលហ្នឹង គឺអត់មានសួរឿងចាប់ផ្តើមអ្នកណាមុនអីទេ ប៉ុន្តែក្នុងពេលនេះ ខ្ញុំឆ្លើយទៅ ព្រោះគ្រាន់ថា កាលហ្នឹងគឺវៀតណាមចូលមក ចូលមក។ដីខ្មែរយើងហ្នឹង គឺដល់អ៊ីចឹង គឺកម្លាំងគឺត្រូវបំពាក់អាវុធសម្រាប់តទល់នឹងខ្មាំងដែលយកទឹកដីរបស់កម្ពុជា។ សូមមានប៉ុណ្ណឹង។

ស: ខ្ញុំសូមអានសំណួរ និង ចម្លើយជូនលោកស្តាប់តែម្តង ដើម្បីឲ្យលោកនឹកឃើញ ឲ្យលោកស្តាប់ទៅ តើនឹកឃើញដែរទេ។ "សំណួរ: តើរវាងកម្ពុជា និង វៀតណាមអ្នកណាវ៉ៃគេមុន នាំទៅដល់សង្គ្រាមនោះ? ចម្លើយ លោកឆ្លើយថា: ខាងកម្ពុជានេះអត់មានធ្វើសកម្មភាពអ្វីនោះទេ វៀតណាមនោះគេធ្វើសកម្មភាពមុន។ នៅខាងយើង គឺការរៀបចំហ្នឹងគឺចាប់ផ្តើមពី<ចលនា>របស់ ខាំ ភួន <នៅក្នុងអង្គភាពយើង>។ នៅពេលនោះ គឺមានវៀតណាមបំពាក់អាវុធ ក៏ប៉ុន្តែគេមិនបង្ហាញជាសាធារណៈនោះទេ។ អាវុធទាំងអស់នោះ គឺគេទុកនៅក្នុងឃ្លាំង។" តើលោកនៅចាំថាបានឆ្លើយចម្លើយ ឆ្លើយទៅនឹងសំណួរនាពេលនោះដែរឬទេ ចម្លើយដែលខ្ញុំអានអម្បាញ់មិញ?

ឆ: បាទ បញ្ហាហ្នឹង គឺខ្ញុំដូចមិនសូវច្បាស់សំណួរ សូមបញ្ជាក់ម្តងទៀត។

[០៩:៤១:៣២]

ស: ខ្ញុំអានចម្លើយដែលលោកឆ្លើយកាលពីលើកមុន ខ្ញុំសូមអានម្តងទៀត។ អ៊ីចឹងចាំលោកស្តាប់ ខ្ញុំអានជូនឲ្យលោកស្តាប់។ ខ្ញុំអានចម្លើយផ្ទាល់ដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា: "ខាងកម្ពុជានេះ អត់មានធ្វើសកម្មភាពអ្វីនោះទេ ខាងវៀតណាមចូលមកមុន។ នៅខាងយើងការរៀបចំ

នេះ ចាប់ផ្តើមពីចលនារបស់លោក ខាំ ភួន នៅក្នុងអង្គភាពរបស់យើង។ តាំងពីពេលនោះមកវៀតណាមគឺបំពាក់អាវុធ ក៏ប៉ុន្តែអាវុធនោះ គឺមិនបំពាក់បង្ហាញជាសាធារណៈនោះទេ គឺគេយកទៅទុកនៅក្នុងឃ្លាំង។" តើលោកនៅចាំថាបាននិយាយ ឆ្លើយបែបនេះដែរឬទេ?

ជ៖ បាទ បញ្ហានេះ គឺជា ដូចខ្ញុំបានបញ្ជាក់ខាងដើមអំមិញអីចឹងថា ខាងព្រំដែន គឺមិនទាន់មានបញ្ហាទេ គឺមានតែក្នុងទីរួមស្រុក ចន្លោះឆ្នាំ៧៦ និង៧៧ហ្នឹង គឺមានវៀតណាមចូលទៅក្នុងកោះញែកហ្នឹង គឺចំនួនមួយក្រុម ប្រហែលជា១០ ទៅ១២នាក់។ ហើយអ្នកនាំចូលហ្នឹង គឺការឆ្លើយរបស់ខ្ញុំកាលហ្នឹងគឺ ស្វាយ អ្នកយកចូលទៅ។ ស្វាយ ជាចៅហ្វាយស្រុកហ្នឹងយកវៀតណាម យកទៅលាក់ក្បែរផ្ទះរបស់ ស្វាយ ហ្នឹង។

ស៖ ខ្ញុំនឹងសួរលោកអំពីទាហានវៀតណាម១២នាក់ហ្នឹងឡើងវិញ។ ក៏ប៉ុន្តែខ្ញុំចង់ឲ្យលោករំឭកការចងចាំរបស់លោក ហើយខាងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺគាត់សួរសំណួរ និង ចម្លើយខាងក្រោមបន្តទៀត។ គឺគេបានសួរបន្តទៀតថា--

ប្រធានអង្គជំនុំ៖

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[០៩:៤៣:៤៣]

លោក នីកូឡាស គូមជែន៖

លោកប្រធាន <ការអនុវត្តនោះ>គឺ<ថា ដំបូងឡើយត្រូវសួរសាក្សីពីការ>ចងចាំ<របស់គាត់> មុនពេលដែលយើងយកកំណត់ហេតុណាមួយ យកមកលើកឡើង ជាពិសេស<ក្នុងករណីនេះ សាក្សីមិនត្រូវបានគេផ្តល់បរិបទនូវអ្វីដែលគេបានពិភាក្សានោះភ្លាមៗទេ មុនពេលគេ>អាន<ចម្លើយ ដែលជា> ចលនាហ្វុលរ៉ូ។ ជាទូទៅខ្ញុំស្នើសុំលោកប្រធានថា ភាគីគួរតែ<>សួរទៅកាន់សាក្សីថាចាំដែរឬទេ <បើមានភាពផ្ទុយគ្នា ឬក៏ត្រូវការរំឭកការចងចាំឡើងវិញ នោះជាការពិត គឺគាត់អាច>អាន<ចម្លើយរបស់>សាក្សី<បាន>។

លោក វ៉ិចទ័រ ភូប៉ែ៖

ខ្ញុំគិតថា ខ្ញុំបាន<ធ្វើដូច្នោះ>ហើយ<> ក៏ប៉ុន្តែនៅពេលនេះ ខ្ញុំសូមបញ្ជាក់ឡើងវិញ។

សួរដោយលោក វ៉ិចទ័រ ភូប៉ែ៖

ស៖ លោកសាក្សី តើលោកនៅចាំទេ ថាតើស្ថានការណ៍ដែលមានការកើតឡើងកាន់តែខ្លាំងក្លា

រវាងកងទ័ពវៀតណាម និងកម្ពុជាប្រជាធិបតេយ្យនៅសម័យនោះៗ កើតឡើងក្នុងឆ្នាំណាដែរ ដែលស្ថានភាពនេះ កាន់តែមានភាពដុនដាបឡើង?

លោក ជិន សារឿន:

ជ: បាទ សូមបញ្ជាក់ម្តងទៀតចុះ លោកប្រធាន គឺថាបញ្ហាហ្នឹង គឺព្រំដែននៅទេ គឺក្នុងចន្លោះ ៧៦, ៧៧ហ្នឹងគឺសង្គ្រាមខាងក្នុងតែម្តង។ អ៊ីចឹងគឺតាមចម្លើយរបស់ខ្ញុំ ដែលបានឆ្លើយជាមួយខាងស្រាវជ្រាវហ្នឹង គឺវាមានបញ្ហា។ មានបញ្ហា ដល់ខាង ហម, ខាង ហម ហ្នឹងគេដឹងថា ស្វាយ ហ្នឹងយកវៀតណាមមកលាក់អ៊ីចឹង គឺគេមានវិធានចាប់ ស្វាយ ហ្នឹង ចាប់ ស្វាយ។ អ៊ីចឹងកាលនោះ គាត់បានសួរដេញដោលទៀតដែរ។ អ៊ីចឹងគឺគេដឹងថាចាប់ ស្វាយ, ខាំ ភូន ហ្នឹងគឺអន់ចិត្ត អត់ចិត្តតាមឮថា ហម ត្រូវចាប់ក្មួយរបស់គាត់ហើយ។ អ៊ីចឹងវាមានបញ្ហាឈ្លោះប្រកែកផ្ទៃក្នុង ក្នុងគណៈតំបន់ហ្នឹង។

[០៩:៤៦:១៧]

ស: ដូចដែលខ្ញុំជម្រាបលោកខាងដើម ខ្ញុំនឹងសួរប្រធានបទនេះនាពេលក្រោយ។ ដោយសារវាមានលក្ខណៈសំខាន់ ក៏ប៉ុន្តែនៅពេលនេះ ខ្ញុំ<សូមរំឭកការចងចាំរបស់លោក ដោយការអានចម្លើយរបស់លោក ដែលលោកបានផ្តល់ឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកថា> សមរភូមិ<ក្តៅបំផុត គឺនៅព្រៃចាស់ និងព្រៃថ្មោល នៅហួស>ស្រុកកោះញែក<បន្តិច>។ លោកបានលើកឡើងអំពីសមរភូមិក្តៅនាពេលនោះដែលបានកើតឡើង។ លោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយលោកក៏បានឆ្លើយថា មានអង្គភាពកងទ័ពរបស់វៀតណាមចូលមកដោយផ្ទើរជើងផងដែរ។ <ដូច្នេះ ក្រៅពី> ស្វាយ និង ខាំ ភូន <>តើលោកអាចជម្រាបទេ ការប៉ះទង្គិចរវាងកម្ពុជាប្រជាធិបតេយ្យ <-->កងទ័ពកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមនៅពេលនោះ គឺមានស្ថានការណ៍យ៉ាងម៉េចដែរ?

ជ: បាទ កាលពីក្នុងចន្លោះនោះ គឺខាងទ័ពព្រំដែន គឺអត់ទាន់មានទេ។ ចង់និយាយថា មកចំនួន ១២នាក់ហ្នឹង គឺគេមកដោយស្ងាត់។ ដល់តែផ្ទុះពីក្នុងវិញបានដឹងថា វៀតណាមចូល។ អ៊ីចឹង គឺមកអត់មានកម្លាំងធំទេ កម្លាំងមួយក្រុម គឺមិនអាច។ដឹងទេ នៅអត់ -- មិនអាចប៉ះជាមួយកងទ័ពការពារនៅខាងមុខទេ។

ស: សូមអរគុណ។ នៅពេលនេះខ្ញុំសួរអំពីទាហាន១២នាក់មកពីខាងវៀតណាម តើមានអ្វីកើតឡើងចំពោះទាហាន<វៀតណាម>ទាំង១២នាក់នោះ? តាមលោកចាំ តើមានអ្វីកើតឡើងចំពោះគាត់ទាំង ១២នាក់?

[០៩:៤៨:២២]

ជ៖ បាទ ចំពោះទាហានវៀតណាម១២នាក់ហ្នឹង ក្រោយពីគេចាប់ ស្វាយ ហ្នឹងបានហើយ គឺវៀតណាមត្រូវដកទៅប្រទេសគេវិញ។ ដល់ពេលក្រោយដែល។ចាប់បាន ស្វាយ ហ្នឹងហើយ គេដឹងថាចាប់បាន ស្វាយ ហើយកម្លាំងវៀតណាម គឺដកទៅស្រុកគេវិញទៅ។ នេះគឺចំពោះកម្លាំង១២នាក់។

ស៖ ធ្វើម្តេចទើបលោកដឹងថា អ្នកទាំង១២នោះជាទាហានវៀតណាម? តើលោកបានឃើញពួកគាត់ផ្ទាល់ ហើយឃើញពួកគាត់ស្លៀកពាក់ឯកសណ្ឋានកងទ័ពវៀតណាម? តើលោកធ្វើយ៉ាងម៉េចទើបដឹងថា ជាទាហានវៀតណាមទាំង១២នាក់ដែល ស្វាយ នាំមក?

ជ៖ បាទ ខ្ញុំគឺនៅអង្គភាពព្រំដែន ខ្ញុំមិនឃើញ មិន។អាចជួប ហើយនិងស្គាល់ទេ។ ក៏ប៉ុន្តែខាងមេខ្ញុំនោះ ខាំ វៀង គាត់មកធ្វើការនៅក្នុងហ្នឹង គាត់ទៅវិញ គាត់ផ្សព្វផ្សាយ។ ផ្សព្វផ្សាយថាមានវៀត-ណាមចូលទៅដល់កោះញែក១២នាក់ ហើយអ្នកដែលនាំចូលគឺ ស្វាយ ដោយខ្ញុំអត់បានឃើញទេ ប៉ុន្តែគាត់ជាប្រធានអង្គភាពដែលខាងតំបន់ គេហៅទៅធ្វើការហ្នឹង មកវិញគាត់ផ្សព្វផ្សាយអ៊ីចឹង។

ស៖ តើ ខាំ វៀង គាត់មានលើកឡើងថា អ្នកទាំង១២នាក់នោះ ស្លៀកពាក់ឯកសណ្ឋានយោធាវៀតណាម ហើយប្រាប់ពួកទាំង១២នាក់នោះមកពីអង្គភាពណា ពីវៀតណាម? តើលោកអាចជួយជម្រាបទេ ថាតើមេរបស់លោកនិយាយរៀបរាប់យ៉ាងម៉េចខ្លះអំពីអ្នកទាំង១២នាក់ជាកងទ័ពវៀតណាមនោះ?

ជ៖ បាទ ត្រង់រឿងឯកសណ្ឋាន ឬក៏ជាអ្វីគាត់អត់បានជម្រាបទេ ប៉ុន្តែគ្រាន់តែពេលគាត់ទទួលផែនការ ហើយនិងការផ្សព្វផ្សាយរបស់គណៈតំបន់ គាត់ប្រាប់ខាងអង្គភាពខ្ញុំដែលនៅព្រំដែននេះ ដូចខាងដើមអ៊ីចឹង ត្រង់ថាខោអាវ និងឯកសណ្ឋានគាត់អត់បានប្រាប់ គាត់ដឹងថាកម្លាំងវៀតណាម។

[០៩:៥១:០២]

ស៖ តើទាហានទាំង១២នាក់នោះ មកធ្វើសកម្មភាពអ្វីដែរនៅក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ? តើមេរបស់លោកមានរៀបរាប់ប្រាប់ទេ?

ជ៖ បាទ កាលនោះ គឺមិនទាន់មានធ្វើសកម្មភាពអីទេ។ គ្រាន់តែគេក្តាប់កម្លាំងបានថាមានវៀតណាមចូលមកដល់ក្នុងស្រុកអ៊ីចឹង គឺគេមានវិធានការចាប់អ្នកនាំហ្នឹងបានហើយ អាហ្នឹងគឺវាទៅវិញដោយឯកឯងតែម្តង ព្រោះមេខ្លោងអ្នកនាំមកហ្នឹងគេចាប់បានហើយ។

ស៖ តើទាហានវៀតណាមទាំង១២នាក់នោះ ស្ថិតនៅកន្លែងណាដែរ នៅពេលដែលគេរកឃើញគេ

ឃើញ? តើ<>អ្នកទាំង១២នាក់នោះស្ថិតនៅក្នុងភូមិណា ទីតាំងកន្លែងណា? តើលោកនៅចាំទេ?

ជ៖ តាមខ្ញុំដឹង និងគាត់ផ្សព្វផ្សាយប្រាប់ខ្ញុំ គឺនៅឃុំដែល ស្វាយ រស់នៅហ្នឹងគឺឃុំរយ៉ ឃុំរយ៉ ដឹងទេ ខ្ញុំមិនសូវចាំទេ សូមអធ្យាស្រ័យ ព្រោះវា។ឃ្លេរពេកហើយ។

ស៖ ខ្ញុំសាកព្យាយាមមើល ថាតើលោកនៅចាំដែរទេ។ អង់គ្លេស ERN គឺទំព័រ 01249763, បារាំង 01249784, ខ្មែរ <00042523>។ សំណួរដែលគេសួរលោកគឺ "តើភូមិណាដែរដែល ស្វាយ ទៅយកឃ្លួននោះមក? ហើយលោកឆ្លើយថា៖<>ភូមិ<ក>, <ឃុំអូរ>ប្លួន ហើយនិងស្រុកកោះញែក។ គាត់លាក់ទាហានឃ្លួនហ្នឹងនៅ<ក្បែរ>ផ្ទះរបស់គាត់ប្រហែលជា១២នាក់។" តើលោកនឹកឃើញទេ គឺភូមិខា?

[០៩:៥៣:៣០]

ជ៖ បាទ អាហ្នឹងហើយភូមិ បើខាងខ្មែរគេហៅ "ភូមិក" ហៅ "ភូមិក" នៅជិតក្បែរផ្ទះ ស្វាយ ហ្នឹង។ ភូមិ "ក"ហ្នឹងគឺនៅ វាមិនលាក់ក្នុងផ្ទះទេ គឺព្រៃក្បែរផ្ទះ ស្វាយ បាទប៉ុណ្ណឹង។

ស៖ តើ ស្វាយ នេះមានគោលបំណងអ្វី? ហេតុអ្វីចាំបាច់លាក់វៀតណាម ទាហានវៀតណាមទាំង១២នាក់នោះនៅក្នុងព្រៃ? តើគាត់មានចេតនាអ្វីដែរ?

ប្រធានអង្គជំនុំ៖

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

លោក នីកូឡាស គូមជែន៖

<ការ>សួរថាតើ ស្វាយ មានចេតនាអ្វីនោះ ខ្ញុំមិនដឹងថាតើមេធាវីចង់ឲ្យសាក្សីនេះឆ្លើយអំពីចេតនារបស់ ស្វាយ ហ្នឹងយ៉ាងម៉េច<ទេ គាត់អាចសួរថា តើ>ស្វាយ<បានឆ្លើយសារភាពយ៉ាងម៉េចក្រោយពីគេចាប់ខ្លួន និងធ្វើទារុណកម្ម>។ ជាពិបាក វាជាការមួយមិនត្រឹមត្រូវដែលស្នើសុំឲ្យបង្ហាញចេតនារបស់ ស្វាយ។

លោក វ៉ិចទ័រ ក្លូប៉ែ៖

ខ្ញុំសូមព្យាយាមសួរ ថាតើសាក្សីគាត់នៅចាំដែរឬទេ លោកប្រធានខ្ញុំសូមអនុញ្ញាត។

សួរដោយលោក វ៉ិចទ័រ ក្លូប៉ែ៖

ស៖ តើលោកប្រធានរបស់លោក កងរវសេនាធំរបស់លោកនោះ បានប្រាប់លោកអំពីចេតនារបស់ ស្វាយ ដែរឬទេនៅពេលនោះ? ហេតុអ្វីបានជា ស្វាយ នោះគាត់លាក់ទាហានវៀតណាមទាំង

១២? តើប្រធានរបស់លោកមានប្រាប់អំពីចេតនារបស់ ស្វាយ ដែរឬទេ?

[០៩:៥៥:០៨]

លោក ជិន សារឿន៖

ជ៖ បាទ សុំគោរពលោកប្រធាន គឺបញ្ហានេះខ្ញុំមិនបានដឹងជ្រៅជ្រះទៀតទេ គ្រាន់ថាគាត់ទៅពីទទួលផែនការពីគណៈតំបន់ទៅ គាត់ផ្សព្វផ្សាយអីចឹង។ កើតហេតុនៅស្រុកយើងហ្នឹង គឺមានគេនាំវៀតណាមមក បាទតែប៉ុណ្ណឹងទេ។ ត្រង់ថាចេតនាអី គេនាំមកធ្វើអីៗ គឺគាត់អត់បានផ្សព្វផ្សាយឲ្យខ្ញុំទេ។ បាទ សុំឆ្លើយបំភ្លឺប៉ុណ្ណឹង។

ស៖ តើលោកដឹងដែរឬទេ តើ ខាំ ភូន ក៏មានការជាប់ពាក់ព័ន្ធនៅក្នុងការលាក់ទាហាន១២នាក់នៅក្នុងព្រៃផងដែរ?

ប្រធានអង្គជំនុំ៖

លោកសាក្សី លោកយល់សំណួរទេ?

លោក ជិន សារឿន៖

ជ៖ បាទ សួរ សុំៗបញ្ជាក់ឡើងវិញ។

ប្រធានអង្គជំនុំ៖

សុំលោកមេធាវី សំណួរម្តងទៀត ឲ្យសាក្សីបានស្តាប់បាន។

សួរដោយលោក វ៉ិចទ័រ ក្លូប៉ែ៖

ស៖ បាទ អាចសួរបាន លោកប្រធាន។ តើលោកដឹងទេ ថាតើ ខាំ ភូន នោះមានពាក់ព័ន្ធអ្វីដែរឬទេ នៅក្នុងការលាក់ទាហានវៀតណាមទាំង១២នាក់នោះ?

[០៩:៥៦:៥៣]

លោក ជិន សារឿន៖

ជ៖ បាទ បញ្ហាហ្នឹង ខ្ញុំសុំឆ្លើយបញ្ជាក់ថា រឿង ខាំ ភូន និងពាក់ព័ន្ធនឹងទាហានវៀតណាម ក៏ខ្ញុំអត់ដឹងដែរ ប៉ុន្តែគ្រាន់ថា កាលហ្នឹងគឺ ខាំ ភូន និង ស្វាយ ហ្នឹងវាត្រូវជាសាច់ញាតិ។ អ៊ីចឹងជំនាន់នោះដឹងហើយ តែមានបញ្ហាក្បួយគឺពូគឺនៅក្នុងហ្នឹងដែរហើយ។ អ៊ីចឹងគឺបញ្ហានេះ ខ្ញុំអត់បានយល់អីជ្រៅជ្រះពេកទេ ព្រោះសូមបញ្ជាក់លោកប្រធានថា ជំនានន៎ុងចម្ងាយពីកោះញែកទៅតំបន់កងចល័តខ្ញុំនៅព្រំដែនហ្នឹងតែជាង១០០គីឡូទេ ប៉ុន្តែបើប្រៀបធៀបប្រហែលនៅអាមេរិកនោះ។ បាទ អត់ចេញចូលអី ដើរបាន

រហេតរហូតអីទេ គឺអ្នកណានៅណា នៅហ្នឹងហើយ។ បើគាត់កងទ័ពគឺ អានេះសុំបន្ថែមបន្តិចចុះ កងទ័ពគឺនៅព្រំដែនគឺវាព្រំដែនហើយ។ មានតែមេទេ ដែលឆ្លងទៅមកបាន។ បាទ សុំបញ្ជាក់ខ្លីប៉ុណ្ណឹង។

ស៖ ខ្ញុំនឹងសួរបញ្ជានេះឡើងវិញ។ ក៏ប៉ុន្តែខ្ញុំសូមសួរលម្អិតទៅលើចំណុចមួយចំនួនជាមុនសិន។ ចាតើកងអនុសេនាធំ <ឬ>វរសេនាធំ<លេខ៥០២>របស់លោកមានជាប់ពាក់ព័ន្ធនៅក្នុងការដេញចាប់ ស្វាយ ដែរឬទេ? តើអង្គភាពទ័ពរបស់លោក មានចូលរួមពាក់ព័ន្ធនៅក្នុងការព្យាយាមចាប់ ស្វាយ ដែរឬទេ?

ឆ៖ បាទ បញ្ជានេះគឺខ្ញុំសូមឆ្លើយបញ្ជាក់។ សភាពការណ៍នៅក្នុងស្រុកមានព្រឹត្តិការណ៍កើតឡើង ខាងតំបន់គឺបានរាយការណ៍ និងជូនព័ត៌មានទៅឲ្យខាងទ័ពព្រំដែន ស្នាក់ ៗក្រែងលោ ស្វាយ ហ្នឹងរត់ទៅច្រកខេត្ត ខេត្តមណ្ឌលគិរីហ្នឹង។ ដល់តែខ្ញុំបានរៀបចំ -- មេគាត់បានឲ្យខ្ញុំរៀបចំកម្លាំង និងឡានពីរគ្រឿងដែរទៅស្នាក់ តែអត់ឃើញ ស្វាយ ហ្នឹងទៅទេ ព្រោះគេចាប់ ស្វាយ បាននៅនឹងកោះញ្ញែកនេះទេ។

[០៩:៥៩:៣១]

ស៖ តើកងវរសេនាធំ ឬក៏ក្រុមរបស់លោក<ឬ>ដែល<ត្រូវបានគេចាត់តាំងឲ្យ>ចាប់ខ្លួន ស្វាយ<>? ឬក៏មានតែកងវរសេនាតូចរបស់លោកតែប៉ុណ្ណោះ ដែលត្រូវទទួលភារកិច្ចទៅចាប់ ស្វាយ ឬក៏មានក្រុមផ្សេងទៀត អង្គភាពផ្សេងទៀតចូលរួមជាមួយលោកដែរ?

ឆ៖ បាទ បញ្ជានេះ គឺខាងខ្ញុំកងទ័ពការពារព្រំដែន កាលណាមានបញ្ជា គឺគេឲ្យស្នាក់ខាងព្រំដែនហើយ ក្រែងលោអ្នកពាក់ព័ន្ធហ្នឹង វារត់ទៅតាមៗច្រកនោះ។ តែកាលជំនាន់នោះ បើសិនជាកងទ័ពតំបន់មានបញ្ជា គឺខាង៩២០ គឺអន្តរាគមន៍។ ហ្នឹងសូម បើតាមខាងក្រុមស្រាវជ្រាវឯកសារសួរខ្ញុំកាលមុនគឺអ៊ីចឹង ហើយខ្ញុំក៏បានឆ្លើយអ៊ីចឹងដែរ។ តែកាលណាមានបញ្ជាខាងកងតំបន់ គឺ១០៥ អ្ហ៉ា! ខាង៩២០ គឺគេមានសិទ្ធិចាប់។ បើខាង៩២០មានបញ្ជា អាហ្នឹងបានគេស្នើកម្លាំងខាងទ័ពតំបន់អន្តរាគមន៍។ បាទ លោកប្រធាន ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

ស៖ តើ ខាំ ភូន និង ស្វាយ ត្រូវបានគេចាត់ទុកថា ជាផ្នែកមួយនៃចលនាបះបោរ<ឬ? តើពួកគេ>ត្រូវបានចោទប្រកាន់ថា បានដឹកនាំការបះបោរដោយមានការឃុបឃិតជាមួយនឹងកងទ័ពវៀតណាមទាំងអស់នេះទេ?

[១០:០១:២៨]

ជៈ បាទ ខ្ញុំសូមបញ្ជាក់បញ្ហាហ្នឹង គឺដូចខ្ញុំបានជម្រាបលោកប្រធានពីមុនហើយថា ការផ្ទៃក្នុងខាងក្នុង គឺខ្ញុំមិនបានដឹងជ្រៅជ្រះទេ គ្រាន់ថា ពេលប្រធានខ្ញុំគាត់ចុះមកធ្វើការ គាត់ទៅផ្សព្វផ្សាយទេ។ ត្រង់ថា ជាក់ស្តែងគឺអត់ទេ។ នេះខ្ញុំនិយាយហើយអ៊ីចឹង គេសួរខ្ញុំ ហើយនិងខ្ញុំឆ្លើយ ឆ្លើយតាមមតិផ្សព្វផ្សាយរបស់មេរបស់ខ្ញុំ។ អ៊ីចឹងគឺជំនាន់ហ្នឹង មានបញ្ហា ហម និង ខាំ ភូន មែនហើយ ព្រោះត្រង់ថាទំនាស់គ្នារឿងអី គឺខ្ញុំអត់យល់ទេ ក៏ប៉ុន្តែគាត់អត់ផ្សព្វផ្សាយថា ហម និង ខាំ ភូន ស្លាប់ហើយ គឺស្លាប់នៅទីក្រុងភ្នំពេញ ដឹងត្រង់ណាៗ ខ្ញុំអត់យល់ដែរ គ្រាន់គាត់ផ្សាយថា គណៈតំបន់ទាំងពីរហ្នឹងស្លាប់ៗទាំងពីរនាក់។ ថា ខាំ ភូន នេះវាយ ហម នឹងដែកចន្ទាស់។ ហើយរួចហើយ ខាំ ភូន ហ្នឹងធ្វើឃាតខ្លួនឯង។ គ្រាន់តែដឹងតែប៉ុណ្ណឹងទេ។

សៈ លោកសាក្សី ខ្ញុំសូមសួរបញ្ចប់មុនពេលឈប់សម្រាក ដោយខ្ញុំអានអ្វីដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំនឹងសួរលោក ថាតើមានអ្វីខ្លះដែលមិនត្រឹមត្រូវនៅក្នុងចម្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជានេះ គឺថាចម្លើយនេះវែងឆ្ងាយដែរ ប៉ុន្តែ<ទាំងអស់នេះជាអ្វីដែលលោកបាននិយាយ>។ លោកប្រធាន ខ្ញុំនឹងអានចេញពីឯកសារ គឺអង់គ្លេស 01249763 ដល់ 64, ខ្មែរ 00042522 ដល់ 23, បារាំង 01249783 ដល់ 84។ លោកសាក្សី បើសិនណាខ្ញុំអានឲ្យលោកស្តាប់ហើយ លោកយល់ថា មានអ្វីមិនត្រឹមត្រូវ សូមលោកអាចបញ្ឈប់ខ្ញុំបាន។ សូមដកស្រង់៖ “ខាំ ភូន បានអនុញ្ញាតឲ្យវៀតណាមចូលមកក្នុងទឹកដីកម្ពុជាតាមរយៈ ស្វាយ ដែល ស្វាយ នេះជាក្បួយបង្កើតរបស់ខាំ ភូន។ ពួកគេលាក់បំពួនវៀតណាមទាំងអស់នេះនៅក្បែរភូមិរបស់ពួកគេ។ ពួកគេជាអ្នកដឹកនាំចលនាបះបោរ។ ក្រោយមក ហម បានដឹងរឿងនេះ។ ហើយដល់អ៊ីចឹងទៅ ហម លែងទុកចិត្ត ខាំ ភូន ហើយហៅ ខាំ ភូន មកប្រជុំ។ ខាំ ភូន ជាសាច់ឈាមរបស់ ស្វាយ។ ខ្ញុំគិតថា ពួកគេស្គាល់ ខាំ ភូន ហើយអ៊ីចឹងហើយ ខ្ញុំក៏ឆ្ងល់ថា ម៉េចក៏បានគេមិនចាប់ ស្វាយ។ ខ្ញុំតាមដេញចាប់ ស្វាយ រហូតដល់ភ្នំដោះក្រមុំ។ ក្រោយបន្ទាប់មក គេបានយកអ្នកទាំងនោះឲ្យមកចូលរួមប្រជុំនៅភ្នំពេញ”។ ក្រោយបន្តិចមកទៀត <គេសួរថា>៖ “តើគេបញ្ជូន ស្វាយ មកប្រជុំនៅភ្នំពេញឬ?” <ឆ្លើយ៖> “ស្វាយត្រូវបានគេចាប់ខ្លួនហើយនិងសម្លាប់ចោលនៅទីនេះតែម្តង មិនបានបញ្ជូនទៅភ្នំពេញទេ”។ សួរ៖ “តើភូមិណាដែល ស្វាយ លាក់កងទ័ពយួន?” <ឆ្លើយ៖> “គឺភូមិក <ឃុំអូរបួន> ស្រុកកោះញែក។ គាត់លាក់កម្លាំងវៀតណាមនៅក្បែរផ្ទះរបស់គាត់ គឺមានចំនួន១២នាក់”។ សួរ៖ “ថាតើ ស្វាយ ត្រូវបានចាប់ខ្លួននៅពេលណា?” <ឆ្លើយ៖> “គឺនៅចុងឆ្នាំ៧៦ ឬក៏ដើមឆ្នាំ៧៧។ <គេបាន>ប្រើកម្លាំងវរសេនាតូច៥២ហ្នឹងដើម្បីធ្វើអន្ត

រាគមន៍<នៅស្រុកកោះញែក>។ អាវុធរបស់មេបញ្ជាការនៅកោះញែកហ្នឹង គឺរឹបអូសទាំងអស់។ គឺមានតែក្រុមខ្ញុំទេ ដែលអាចកាន់អាវុធដើម្បីបង្ក្រាបចលនាបះបោរនេះ។ កងទ័ពវៀតណាមនេះ គឺបានចាកចេញទៅវិញបាត់ហើយ។ ខ្ញុំ<បានមកដល់ក្រោយពេល> ខាំ ភួន <និង ហម ស្ពាប់>។" បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំសួរទៅលោក ថាអ្វីដែលខ្ញុំអានចេញពីចម្លើយ<ដែលលោកឆ្លើយ>ជូនមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ត្រឹមត្រូវដែរឬទេ?

[១០:០៦:០៥]

ជៈ បាទ ខ្ញុំសូមឯកភាពទៅតាមចម្លើយរបស់ខ្ញុំដែលបានឆ្លើយឱ្យខាងស្រាវជ្រាវកាលពីពេលមុនហើយ គឺអត់មានខុសទេ។ ក៏ប៉ុន្តែការខ្ញុំឆ្លើយឥឡូវនេះវា ពីនោះមក និងឥឡូវ វាយូរពេកហើយ គឺវាមិនអាចចាំអស់។ អ៊ីចឹងគឺសូមឯកភាពទៅតាមចម្លើយដែលខ្ញុំឆ្លើយជាមួយក្រុមស្រាវជ្រាវ។ បាទសូមអស់។

សៈ ខ្ញុំសុំសួរបន្តបញ្ជាក់ចំណុចនេះ បន្តែមទៀត។ ពាក់ព័ន្ធទៅនឹងស្វាយគឺ អង់គ្លេស ERN 01249765, ខ្មែរ 00042524, បារាំង 01249789 -- 88 សុំទោស។ លោកបានឆ្លើយថា៖ "ហេតុផលដែលគេចាប់ខ្លួន ស្វាយ នេះ ដោយ ស្វាយ នេះជាប់ពាក់ព័ន្ធជាមួយចលនាឃ្លួន។ ហើយសំណួរសួរថា៖ តើអ្នកណាដែលផ្តល់ព័ត៌មាននេះ នាំឱ្យចាប់ខ្លួន ស្វាយ? លោកឆ្លើយថា៖ នៅពេលនោះ ថ្នាក់ភូមិ និងថ្នាក់ឃុំបានស៊ើបអង្កេតអំពីស្ថានការណ៍នេះ រកឃើញថាមានវៀតណាមនេះ ត្រូវបានលាក់ខ្លួននៅខាងក្រោយផ្ទះ ស្វាយ។" សួរ ថាតើលោកចង់និយាយយ៉ាងដូចម្តេច នៅពេលនិយាយថា គឺមានការជាប់ពាក់ព័ន្ធជាមួយចលនាឃ្លួន? តើលោកចង់និយាយថាម៉េចលោក ដែលលោកថា ស្វាយ ជាប់ពាក់ព័ន្ធជាមួយចលនាឃ្លួននេះ?

ជៈ បាទ គឺបញ្ហាហ្នឹងដែលបានចោទថា បានលើកថា ស្វាយ ពាក់ព័ន្ធជាមួយឃ្លួនហ្នឹង ព្រោះប្រធានខ្ញុំបានមកផ្សព្វផ្សាយថា ស្វាយ ហ្នឹងគឺយកឃ្លួនហ្នឹងយកមកលាក់ក្បែរផ្ទះគាត់ ក្បែរផ្ទះគាត់។

[១០:០៨:១២]

សៈ មិនថ្វីទេ។ តើលោកដឹងទេ ពីថ្នាក់ភូមិ និងថ្នាក់ឃុំដែលជាអ្នកទទួលបន្ទុកស៊ើបសួរហើយរកឃើញថា កងទ័ពវៀតណាមគេលាក់នៅខាងក្រោយផ្ទះ ស្វាយ ហ្នឹង លោកចង់និយាយថា អាជ្ញាធរភូមិ អាជ្ញាធរឃុំហ្នឹងជាអ្នកណាហ្នឹង?

ជៈ បាទ ខ្ញុំបានបញ្ជាក់ខាងដើមដែរហើយថា ខ្ញុំអត់ដឹងអីច្រើនជាងចម្លើយនៅក្នុងឯកសារ

1 របស់ខាងក្រុមស្រាវជ្រាវនោះទេ។ បាទ រឿងអាជ្ញាធរភូមិ អាជ្ញាធរឃុំ ក៏ខ្ញុំអត់បានស្គាល់ដែរ ដូចខ្ញុំបាន
2 បញ្ជាក់ខាងដើមថា ខ្ញុំនៅតែព្រំដែននោះទេ ដឹងសភាពការណ៍ ក៏ដឹងមកពីការផ្សព្វផ្សាយរបស់មេ
3 បញ្ជាការខ្ញុំដែរ។

4 **ប្រធានអង្គជំនុំ៖**

5 អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០
6 នាទី ចាប់ពីពេលនេះតទៅ។

7 មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នក
8 ជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់
9 សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ មុនពេលចាប់ផ្តើមសវនាការ។

10 សូមអញ្ជើញសម្រាក!

11 *(សវនាការសម្រាកពីម៉ោង ១០:០៩ នាទី ដល់ម៉ោង ១០:៣០ នាទី)*

12 [១០:៣០:៣៥]

13 **ប្រធានអង្គជំនុំ៖**

14 សូមអញ្ជើញអង្គុយ!

15 ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាដល់លោកមេធាវីការពារក្តីលោក ន្ឈន ជា ប្រសិនបើលោកមាន
16 សំណួរបន្ត។ តើលោកមេធាវី មានបានពិភាក្សាជាមួយលោកមេធាវីការពារក្តីលោក ខៀវ សំផន ហើយ
17 នៅអំពីការបែងចែកពេលវេលាសម្រាប់ការតាំងសំណួរ?

18 **លោក វ៉ិចទ័រ ក្លូប៉ែ៖**

19 បាទ យើងខ្ញុំបានពិភាក្សា។ ក្រុមមេធាវីការពារក្តី ខៀវ សំផន ត្រូវការ៣០ ឬក៏៤០នាទី ហើយ
20 ចំពោះខ្ញុំ គឺនឹងបញ្ចប់មុនពេលម៉ោងដប់មួយ ប្រហែលជាកន្លះម៉ោងទៀត លោកប្រធាន។

21 **ស្នូរដោយលោក វ៉ិចទ័រ ក្លូប៉ែ៖**

22 **ស៖** លោកសាក្សីអរុណាសួស្តីសាជាថ្មី។ ខ្ញុំសូមសួរបន្តទៅលើចម្លើយ ឬក៏សក្ខីកម្មរបស់លោក
23 ក្រោយពេលដែលខ្ញុំអានន្ទូវសក្ខីកម្ម ឬក៏ចម្លើយសាក្សីចំនួនពីរដែលបានលើកឡើងអំពីហេតុការណ៍
24 ពាក់ព័ន្ធនឹង ស្វាយ និង ខាំ ភូន។ ខ្ញុំនឹងអានចម្លើយពីសាក្សីទាំងពីរនោះ ហើយបន្ទាប់មកខ្ញុំឲ្យលោក
25 ប្រតិកម្ម។ ជាបឋមខ្ញុំសូមលើកឡើងអំពីមេបញ្ជាការកងវរសេនាធំ<មួយទៀត មិនមែនមេបញ្ជាការ

លោកឈ្មោះ ខាំ វៀង ទេ គឺឈ្មោះ> ឡាន់ <គាត់>ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាស <ក្រោយលោកបន្តិច គឺនៅខែកុម្ភៈ ឆ្នាំ២០០៥ គឺឯកសារ E3/7822> <ខ្ញុំចាប់អារម្មណ៍>ជាពិសេស <នូវអ្វីដែលគាត់បាននិយាយត្រង់> ERN ជាភាសាអង់គ្លេស <00667375>, <ភាសាបារាំង> 006 65353, ខ្មែរគឺ 00229230។ សាក្សីនោះ បានលើកឡើងអំពី<ហេតុការណ៍ដូចគ្នា គឺមាន>ទាហាន វៀតណាម១២នាក់។ សំណួរដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសួរទៅកាន់គាត់នោះ៖ “គឺលោកឃើញដាន” <ឆ្លើយ៖> “ក្រោយមក គឺមានការរាយការណ៍អំពីដាន” <សួរ៖> “តើ<ដាន>អ្វី<ដែលលោកបានឃើញនោះ>? <ឆ្លើយ៖> “<គឺដាន>កន្លែងដែលជួបជុំគ្នា<ជាមួយវៀតណាម”>។ <សួរ៖> “តើនៅផ្ទះ ស្វាយ ឬយ៉ាងម៉េច?” <ឆ្លើយ៖> “នៅ<សាំងឌី>”។ សំណួរ៖ <“តើផ្ទះស្វាយមែនទេ?” ឆ្លើយ៖> “នៅជិតផ្ទះ ស្វាយ”។ <សួរ៖ “នៅជិតផ្ទះស្វាយ> នៅកែវសីមា ឬក៏យ៉ាងម៉េច?” <ឆ្លើយ៖> “គឺនៅក្រោយផ្ទះ ស្វាយ តែម្តង នៅស្រុកកោះញែក។”

[១០:៣៣:៥៦]

ក្រោយមកទៀត បុគ្គលនេះបានឆ្លើយថា៖ “យើងបានដេញពួកវៀតណាម<>។ ខ្ញុំប្រើប្រាស់ឡានទាហានពីរ<> ជាមួយនឹងកងទ័ពរបស់យើងដេញចាប់<ពួកគេ ប៉ុន្តែតាមមិនទាន់>។ បន្ទាប់មក ពួកយើងទៅដល់អូរទែន ហើយពួកយើងមិនបានតាមទាន់ទេ ដូច្នេះហើយយើងត្រឡប់មកវិញ។ នៅពេលដែលខ្ញុំត្រឡប់មកវិញហ្នឹង ខ្ញុំឮថា <ពួកគេបានសម្លាប់គ្នាទៅវិញទៅមករួចហើយ”>។ ឡាន់ គឺបានលើកឡើងអំពីដាន <វត្តមាន>វៀតណាម<>។ តើលោកបានដឹងអំពីហេតុការណ៍ហ្នឹងដែរឬទេ?

លោក ជិន សារឿន៖

ជ៖ បាទ ខ្ញុំសូមឆ្លើយលើបញ្ហានេះ គឺខ្ញុំអត់បានដឹងទេ ព្រោះនេះជាការងារខាងក្នុង។ បាទ សូមបញ្ជាក់ជូនអង្គជំនុំ។

ស៖ នៅពេលដែលបុគ្គលនេះលើកឡើងអំពីឡាន កងទ័ពពីរឡានដេញវៀតណាម។ តើលោកមាននៅលើឡានណាមួយក្នុងចំណោមឡានទាំងពីរ ដេញតាមទាហានកងទ័ពវៀតណាមនោះដែរឬទេ?

[១០:៣៥:២៩]

ជ៖ បាទ បញ្ហាសំណួរហ្នឹង ភាពដូចផ្សេងគ្នា។ ខាងខ្ញុំឆ្លើយកាលពីក្នុងឯកសារគឺ ខ្ញុំអ្នកស្នាក់ទេ គេបញ្ជាឲ្យខ្ញុំស្នាក់ រឿងខ្ញុំតាមអត់មានទេ។ ខ្ញុំស្នាក់ខ្ញុំនៅក្រង់តេះ ហើយខ្ញុំស្នាក់នៅទីរួមខេត្តមណ្ឌលគិរី ព្រោះកាលនោះខេត្តមណ្ឌលគិរីអត់មាននៅទីរួមខេត្តឥឡូវនេះទេ នៅកោះញែក។ អ៊ីចឹងនេះ គឺអត់មាន

តាមទេ ខាងខ្ញុំអត់មានតាមទេ ខ្ញុំគេបញ្ជាឲ្យស្នាក់ ឡានពីរដែរ ប៉ុន្តែគេឲ្យស្នាក់ ប៉ុន្តែអត់បានជួបហេតុភេទអីទេ។ បាទ សូមឆ្លើយ។

សៈ តើលោកនឹកឃើញទេ នៅចាំទេថាគេដេញតាមវៀតណាមហ្នឹង ទៅដល់អូរទែន ប្រហែលជាខ្ញុំអានឈ្មោះហ្នឹងមិនត្រឹមត្រូវ តើលោកចាំទេថា ដេញរហូតទៅដល់អូរហ្នឹង ឈ្មោះ អូរទែន ប៉ុន្តែប្រហែលជាឈ្មោះ ខ្ញុំអានមិនត្រូវទេ?

ជៈ បាទ សូមជម្រាបជូនលោកប្រធាន គឺថាខ្ញុំបាទឆ្លើយហើយថាអត់ៗដឹងទេ ខាងក្រោយដែលក្នុងចម្លើយរបស់ខ្ញុំក្នុងឯកសារគឺ ស្កាត់ទេ ស្កាត់ ខាងខ្ញុំស្កាត់ តែគេអ្នកតាមខ្ញុំអត់ដឹងទេ មិនដឹងដល់ណា ដល់ណាទេ។

សៈ មិនជាថ្មីទេ សំណួរចុងក្រោយ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាស ឡាន់ នៅឆ្នាំ <២០០៥>។ តើលោកដឹងទេ ឡាន់ ហ្នឹងនៅរស់ទេសព្វថ្ងៃ?

ជៈ បាទ ខ្ញុំសូមឆ្លើយ ខ្ញុំថា ដូចបញ្ជាក់ជូនលោកប្រធានអំមិញអ៊ីចឹងថា តំបន់១០០គីឡូជាងទេ ប៉ុន្តែរឿងដំណឹងអី បើក្រៅពីមេបញ្ជាការគាត់ទៅផ្សព្វផ្សាយ អត់ដឹងអីទាំងអស់។ ឥឡូវនេះចំពោះ ឡាន់ ហ្នឹងក៏អត់ដឹងថានៅរស់ ឬក៏ស្លាប់ អត់ដឹងទេ។

សៈ ខ្ញុំហាក់ដូចជាមិនយល់លោក។ ក៏ប៉ុន្តែសំណួរដែលខ្ញុំចង់សួរលោកនេះ តើលោកដឹងទេ ឡាន់ ហ្នឹងគាត់ស្លាប់ហើយ ឬក៏សព្វថ្ងៃនៅរស់នៅឡើយទេ?

[១០:៣៨:២៦]

ជៈ បាទ ខ្ញុំសូមជម្រាបជូនថា ខ្ញុំអត់ៗដឹង មិនដឹងជាគាត់នៅរស់ ឬក៏គាត់ស្លាប់ ព្រោះអត់ៗដឹង។

សៈ ខ្ញុំសូមអានទូរព័ត៌មានមួយ ដែលវាពាក់ព័ន្ធទៅនឹងបញ្ហាវៀតណាមហ្នឹង វៀតណាមទាហានវៀតណាមទាំង១២នាក់។ គឺចម្លើយរបស់សាក្សីដែលលោកស្គាល់ ហើយសាក្សីនេះបានប្រាប់អង្គជំនុំជម្រះនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦*(ស៊ីក)* <ម៉ោងប្រហែល០៩:២៨នាទី>។ សៅ សារុន បានជម្រាបអង្គជំនុំជម្រះដូចតទៅ ខ្ញុំសូមដកស្រង់ប្រតិចារឹកដែលគាត់ឆ្លើយៈ "គេអញ្ជើញខ្ញុំឲ្យចូលរួមប្រជុំនៅថ្នាក់តំបន់ ហើយគេប្រាប់ខ្ញុំថា វៀតណាមចូលមកទឹកដីរបស់យើង។"

ប្រធានអង្គជំនុំ៖

សូមអញ្ជើញលោកមេធាវី!

កញ្ញា សុង រវ៉ន្ត៖

ចាស លោកប្រធាន។ ស្នើសុំឲ្យមេធាវីជួយផ្តល់លេខឯកសារ ឬក៏កាលបរិច្ឆេទ និងម៉ោងពេលឲ្យបានច្បាស់លាស់ផង។

ប្រធានអង្គជំនុំ៖

សូមអញ្ជើញលោកមេធាវី ផ្តល់លេខឯកសារឲ្យបានត្រឹមត្រូវ។

[១០:៣៩:៥៨]

សួរដោយលោក វ៉ិចទ័រ ក្រូប៉ែ៖

ស៖ បាទ លោកប្រធាន គឺប្រតិចារឹក ឯកសារលេខ E1/411.1 ចុះថ្ងៃទី៣០ មីនា ឆ្នាំ២០១៦ នៅម៉ោងប្រហែលជា០៩:២៨នាទីនាពេលព្រឹក។ ខ្ញុំអានចេញពីប្រតិចារឹករបស់ សៅ សារុន៖ “គេអញ្ជើញខ្ញុំឲ្យទៅចូលរួមថ្នាក់តំបន់ ហើយគេជម្រាបខ្ញុំថា វៀតណាមបានចូលមកទឹកដីរបស់យើងខ្ញុំ។ ហើយត្រីខកំប៉ុង អង្ករ ហើយនិងមីបានផ្តល់ជូនទៅដល់វៀតណាមនោះ នៅជិតផ្ទះរបស់ ខាំ ភូន និងស្វាយ។ នេះជាប្រធានបទដែលគេពិភាក្សាក្នុងពេលប្រជុំពេលនោះ។ មនុស្សជាច្រើនបានទៅមើលកន្លែងដែលគេទុកវៀតណាមនោះ គឺមាន<កញ្ចប់>មី <និងសម្ភារៈផ្សេងទៀតនៅទីនោះ ហើយអ្នកជិតខាងក៏បានឃើញដែរ>។ គេប្រាប់ថា មានអង្គការថ្មីមកដល់ ដើម្បីជួយកម្ពុជា។ <គេបាននិយាយជាមួយប្រជាជន ប៉ុន្តែ>ខ្ញុំខ្លួនឯងអត់ទៅមើលទេ <និយាយតាមត្រង់ចុះ ខ្ញុំមិនបានឃើញដោយផ្ទាល់ភ្នែកទេ>។” បញ្ចប់ការដកស្រង់។ តើលោកធ្លាប់ឮទេ ឮទេព័ត៌មានហ្នឹង គឺមានត្រីខកំប៉ុង អង្ករ រួមទាំងមីនោះ គេយកមកទុកឲ្យវៀតណាមទាំងអស់នោះ?

លោក ជិន សារឿន៖

ឆ៖ បាទ ចំពោះសំណួរហ្នឹង ខ្ញុំថាអត់នេះទេ ព្រោះខ្ញុំអត់ដឹង។ ក្រៅពីខ្ញុំឮប្រធានខ្ញុំផ្សព្វផ្សាយជាដំណឹង ដូចខ្ញុំបានជម្រាបជូនខាងដើមហើយ ក្រៅពីហ្នឹង គឺអត់ដឹងទេ រឿងត្រីខកំប៉ុង រឿងកន្លែងគេឃើញនៅអី គឺអត់ៗដឹងទេ។

[១០:៤២:១៤]

ស៖ សូមអរគុណដែលលោកបានឆ្លើយ។ នៅពេលនេះ ខ្ញុំសូមបន្តទៅចំណុចបន្តទៀត។ ខ្ញុំសូមលើកឡើងនូវព័ត៌មានដែល សុន សេន និងមេបញ្ជា៩២០ បានពិភាក្សាគ្នា គឺការពិភាក្សានេះ នៅក្នុងពេលដែលលោកស្ថិតនៅក្នុងក្រុមកងពល៩២០។ ឯកសារE3/799 លោកប្រធាន កំណត់ហេតុកិច្ចប្រជុំ

1 របស់កងពល៩២០ កិច្ចប្រជុំនេះ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ<១៩៧៦> ម៉ោងដប់បួន។ អង់គ្លេសគឺ
2 00184781, ខ្មែរគឺ 00083160, បារាំង 00323917។ លោកសាក្សី លោកមិនចូលរួមប្រជុំនាពេល
3 នោះទេ ក្នុងកិច្ចប្រជុំហ្នឹង ក៏ប៉ុន្តែមេបញ្ជារបស់លោកគឺ តាឈិន គាត់ទៅចូលរួម ហើយ សុន សេន ក៏
4 ចូលរួមប្រជុំដែរនៅពេលនោះ។ ណាត, ស៊ុំ ហើយបង៨១ ក៏ចូលដែរ ចូលប្រជុំដែរ។ ក្រោយពេល ឈិន
5 ពិពណ៌នាអំពីស្ថានការនៅមណ្ឌលគិរី ហើយនិងបញ្ហានៅព្រំដែនជាមួយនឹងវៀតណាម សុន សេន បាន
6 លើកឡើងដូចខាងក្រោម។ ខ្ញុំសូមដកស្រង់សម្តីរបស់ សុន សេន៖ “បដិវត្តន៍របស់យើង គឺជាបដិវត្តន៍
7 សង្គមនិយម ហើយគឺជាបដិវត្តន៍ស៊ីជម្រៅផងដែរ។ ចំពោះវៀតណាម យើងត្រូវមានជំហរដូចខាង
8 ក្រោម។ ១) យើងមិនមែនជាអ្នកដែលបង្កបញ្ហានោះទេ។ ២) តែយើងត្រូវការពារទឹកដីដាច់ខាត មិនឲ្យ
9 អ្នកណាយក ឬរំលោភជាដាច់ខាត។ ៣) ប្រសិនបើវៀតណាមឈ្លានពាន យើងសុំឲ្យថយ បើមិនថយ
10 យើងវាយ។ ទិសយើង គឺតស៊ូទាំងផ្លូវនយោបាយ ទាំងផ្លូវយោធា។” សំណួររបស់ខ្ញុំគឺចង់សួរអំពីចំណុច
11 ទាំងបីដែលពាក់ព័ន្ធទៅនឹងជំហរចំពោះវៀតណាម។ តើជំហរទាំងបីនេះមានបានណែនាំទៅដល់កងពល
12 ៩២០នាពេលនោះ ក្នុងពេលដែលលោកស្ថិតនៅក្នុងកងពលនោះដែរឬទេ?

13 **ជៀង** បាទ សូមឆ្លើយថា បញ្ហាហ្នឹងគឺអត់បានទទួលទេ ព្រោះការខ្ញុំបាន:ត្រឹមអនុសេនាធំអី
14 ការងារសំខាន់ៗ គឺអត់បានដឹង ហើយអត់បានឮទេ។ សរុបមួយម៉ាត់ គឺបញ្ហាដែលលោកមេធាវីសួរហ្នឹង
15 គឺអត់ៗបានទទួលដំណឹងអីទេ។ បាទសូមអស់។

16 [១០:៤៦:១២]

17 **សេ** តើលោកដឹងអំពីវៀតណាម កងទ័ពវៀតណាមនេះចូលលុកលុយកម្ពុជាប្រជាធិបតេយ្យ
18 ដែរឬទេ? ខ្ញុំមិននិយាយអំពីទាហាន១២នាក់នោះទេ។ តើនៅក្នុងឆ្នាំ៧៦ និង៧៧ និងឆ្នាំក្រោយៗមក
19 ទៀត តើលោកមានដឹងអំពីការលុកលុយផ្នែកយោធារបស់វៀតណាមចូលកម្ពុជាដែរឬទេ? កុំឆ្លើយពាក់
20 ព័ន្ធនឹងទាហាន១២នាក់ និងបញ្ហា ស្វាយ។ ខ្ញុំចង់ឲ្យលោកបង្ហាញស្ថានការណ៍ជាក់ស្តែងនៅក្នុងសមរភូមិ
21 ឆ្នាំ៧៦, ៧៧ និងក្រោយៗមកទៀត។

22 **ជៀង** បាទ បញ្ហាកងទ័ពវៀតណាមដែលចូលទឹកដីខ្មែរនេះ គឺខ្ញុំបានដឹង បាទ អ៊ីចឹងគឺជំនាន់៧៨
23 ចុងឆ្នាំ -- ដើមឆ្នាំ៧៨ និងចន្លោះហ្នឹងគឺកម្លាំងវៀតណាមច្រើនណាស់ ប៉ុន្តែវាអត់បុកចំមុខសញ្ញាដែលខ្ញុំ
24 នៅទេអត់នៅទេ។ ប៉ុន្តែគ្រាន់ថាដឹងថាកម្លាំងគេច្រើន បុកសំដៅទៅស្រុកកោះញែកធ្លាយទៅព្រៃឃ្មុនហ្នឹង
25 និយាយកម្លាំង តែមានកម្លាំងតស៊ូ ត្រង់ណាគេទៅត្រង់ហ្នឹងហើយ។ ខុសតែចំមុខអង្គភាពខ្ញុំដែលការពារ

ព្រំដែនផ្នែកខាងក្រង់តេះហ្នឹងគឺអត់មកចំទេ។ ហើយគ្រាន់តែស្នើកម្ពាំងទៅ គឺឃើញដាន ឃើញស្នាមគេដើរហ្នឹងគឺតាម ប៉ុន្តែកម្ពាំងវា បើនិយាយទៅប្រៀបធៀបទៅច្រើនកងពលណាស់។ សូមជម្រាបជូនប៉ុណ្ណឹង។

ស៖ ខ្ញុំយល់លោក។ គឺស្ថានការណ៍ឆ្នាំ៧៨ តើលោកដឹងស្ថានការណ៍ឆ្នាំ៧៦ ចុងឆ្នាំ៧៦ និងដើមឆ្នាំ៧៧? តើលោកដឹងស្ថានការណ៍អំពីការលុកលុយរបស់វៀតណាមនៅកើតឡើងក្នុងឆ្នាំ៧៦ ដើមឆ្នាំ -- ចុងឆ្នាំ៧៦ និងដើមឆ្នាំ៧៧ដែរឬទេ?

[១០:៤៨:៣៦]

ឆ៖ បាទ បញ្ហាហ្នឹងដូចខ្ញុំបានឆ្លើយម្តងហើយថា ៧៦ ដើមឆ្នាំ៧៧នេះអត់ទាន់មានបញ្ហាទេ។ មានដែលវៀតណាមមកខ្ពាំង គឺកណ្តាលឆ្នាំ៧៧ -- ៧៨ ពាក់កណ្តាលឆ្នាំ៧៨ អាហ្នឹងកម្ពាំងវាធំ។ រវាង ៧៧ និង៧៦ ក្រៅពីសភាពការណ៍១២នាក់ហ្នឹង គឺអត់មានៗសកម្មភាពអីទេ។

ស៖ ដូច្នេះខ្ញុំសូមសួរលោកបញ្ចប់ ដោយអានទូវចំណុចដកស្រង់មួយពីចម្លើយរបស់ សៅ សារុន ប្រតិចារឹកដដែលដែលខ្ញុំលើកឡើងពីខាងដើម។ ប្រតិចារឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ត្រង់ម៉ោង ០៩:០៩ នាទីនាពេលព្រឹក។ លោក សៅ សារុន បានឆ្លើយដូចខាងក្រោម៖ "តើលោកអាចបញ្ជាក់ទេនរណាចាប់ផ្តើមការលុកលុយ? អ្នកណាគេចាប់ផ្តើមវៃមុននៅខេត្តមណ្ឌលគិរី និងឆ្នាំ៧៦ និងឆ្នាំក្រោយៗមកទៀត? សៅ សារុន ឆ្លើយថា៖ វៀតណាម ជាអ្នកចាប់ផ្តើម។ វៀតណាមចាប់ផ្តើមវៃនៅតាមព្រំដែនមុន។ ហើយបន្ទាប់មកវារីកទៅជាការវៃគ្នាធំតែម្តង។ ហើយដោយសារថាហេតុនេះហើយ គឺការរំដោះប្រទេសនេះកើតឡើងនៅក្នុងឆ្នាំ១៩៧៩ ខែមករា។" តើលោកអាចបង្ហាញជំហរ ឬក៏យ៉ាងម៉េចដែរចំពោះការលើកឡើងរបស់ សៅ សារុន?

ឆ៖ បាទ ខ្ញុំអត់មានចម្លើយទេ ខ្ញុំសុំឯកភាពទៅតាមចម្លើយរបស់គាត់ហើយ ព្រោះគាត់តួនាទីធំ ជាគណៈតំបន់ ជាប្រធានហើយ គឺគាត់ដឹងការងារច្រើន។ សុំឯកភាពទៅតាមចម្លើយរបស់គាត់។ ឯរឿងការយល់ដឹងរបស់ខ្ញុំ គឺអត់មានអីក្រៅពីចម្លើយក្នុងឯកសារហ្នឹងទេ។

លោក វ៊ុចទ័រ កូប៉េ៖

ខ្ញុំបញ្ចប់ហើយការសួរសំណួរទៅកាន់លោកសាក្សី។ ខ្ញុំសូមអរគុណលោកសាក្សី ហើយសូមអរគុណលោកប្រធាន។

[១០:៥១:១៦]

ប្រធានអង្គជំនុំ៖

សូមអរគុណលោកមេធាវីការពារក្តីលោក ឆួន ជា។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាដល់តំណាងសហព្រះរាជអាជ្ញាដើម្បីតាំងសំណួរទៅលើសាក្សី។ សុំអញ្ជើញ!

លោក នីកូឡាស គូមជែន៖

សូមអរគុណលោកប្រធាន។ អរុណសួស្តីលោក លោកស្រី លោកសាក្សី។

ការតាំងសំណួរដោយសហព្រះរាជអាជ្ញា

សួរដោយលោក នីកូឡាស គូមជែន៖

ស៖ លោកសាក្សី លោកបានឆ្លើយកាលពីព្រឹកមិញ ថានៅពីក្មេងលោកជាព្រះសង្ឃ ហើយក្រោយមកត្រូវបានគេផ្សឹក គេផ្សឹកលោក។ តើលោកអាចរៀបរាប់បន្តិចទេ ថាតើមានអ្វីកើតឡើងនៅពេលដែលគេចាប់លោកផ្សឹកនោះ?

លោក ជិន សារឿន៖

ជ៖ បាទ ខ្ញុំសុំបញ្ជាក់ជូនសំណួរ គឺកាលពីហ្នឹងខ្ញុំបានបួសជាព្រះសង្ឃ ប៉ុន្តែក្នុងបួសហ្នឹងក៏ការធ្វើការពលកម្ម ក៏ដូចជាឧបាសកដែរ។ ប៉ុន្តែដល់ពេលគេផ្សឹកមកហ្នឹង គឺផ្សឹកជាឧបាសកមក ខាងអង្គការហ្នឹងយកខ្ញុំចូលធ្វើស្មៀនឃុំ បាទស្មៀនឃុំ។

ស៖ តើគេផ្សឹកលោកនៅឆ្នាំណាដែរ?

ជ៖ បាទ ផ្សឹកខ្ញុំក្រោយគេរំដោះ ក្រោយគេរំដោះ។

[១០:៥២:៥០]

ស៖ លោកបានន័យថា រំដោះហ្នឹងរំដោះ គឺនៅពេលដែលគេចាប់យកទីក្រុងភ្នំពេញឆ្នាំ៧៥ហ្នឹងមែនដែរឬទេ?

ជ៖ បាទ ក្រោយពីថ្ងៃ១៧ មេសា ហ្នឹងហើយ គេចាប់ផ្សឹកពួកខ្ញុំ។

ស៖ តើគេមានប្រាប់លោកដែរឬទេ ហេតុអ្វីបានជាអង្គការបង្ខំលោកឲ្យដោះស្បង់ចីពរចេញនោះ?

ជ៖ បញ្ហាហ្នឹងគឺខ្ញុំមិនយល់អីជ្រៅជ្រះដែរទេ គ្រាន់ថា បង្ខំថាឲ្យខ្ញុំផ្សឹកគឺសម័យនេះគឺអត់មានលោកទៀតទេ។ បាទ គ្រាន់តែប៉ុណ្ណឹង។

ស៖ នៅតាមទីកន្លែងផ្សេងៗដែលលោករស់នៅក្រោយ<ខែមេសា> ឆ្នាំ៧៥ <រួមទាំងខេត្ត

1 មណ្ឌលគិរី> តើវាដូចគ្នាចំពោះព្រះសង្ឃដែរឬទេ? បាននិយាយថា តើអង្គការបានផ្សឹកគ្រប់ព្រះសង្ឃផ្សេង
2 ទៀតដែរឬទេ?

3 **ជៈ** បាទ ចំពោះស្រុកឆ្ងាយៗ ខ្ញុំបាទអត់បានយល់ទេ។ តែចំពោះវត្តដែលខ្ញុំបាទបួសហ្នឹង គឺ
4 ផ្សឹកទាំងអស់ ទាំងសាមណេរ ទាំងភិក្ខុ ទាំងចៅអធិការ និយាយមួយមាត់គឺទាំងអស់។ លោកចៅ
5 អធិការអី ក៏ត្រូវផ្សឹកទាំងអស់ដែរ អត់មានទេ។

6 **សៈ** តើក្នុងចិត្តរបស់លោកហ្នឹង លោកនៅជា គិតថានៅតែជាអ្នកគោរពសាសនាហ្នឹងជាព្រះ
7 សង្ឃដដែល ឬក៏យ៉ាងម៉េច ក្រោយពេលគេផ្សឹកលោក?

8 [១០:៥៤:៥១]

9 **ជៈ** បាទ សូមឆ្លើយ បញ្ហានេះគួរឲ្យស្តាយណាស់ ព្រោះថា ជាគោលគំនិតរបស់ខ្ញុំ គឺពេលខ្ញុំ
10 បួសហ្នឹង គឺមិនចង់សឹកទេ មិនចង់សឹកទេ។ តែធ្វើម៉េចបើគេ សភាពការណ៍ វាត្រូវតែសឹកហើយ គឺត្រូវ
11 តែសឹកអ៊ីចឹងឯង។ តែដែលរឿងការស្តាយស្រណោះ ហើយនិងជឿជាក់ចំពោះសាសនា ព្រោះខ្ពែរជា
12 សាសនារបស់ព្រះពុទ្ធ គឺនៅតែស្តាយ។

13 **សៈ** តើគេបើកឲ្យលោកគោរពសាសនា ដូចជាធ្វើអធិដ្ឋានដោយចំហដែរឬទេ ឬក៏រៀបចំជាពិធី
14 តាមសាសនាទៅលើការរៀបអាពាហ៍ពិពាហ៍ និងពិធីបុណ្យសពអីផ្សេងទៀតដែរឬទេ?

15 **ជៈ** បាទ ជំនាន់ហ្នឹង គឺអត់មានរឿងដុតធូប ដុតអីទៀតទេ គឺបើថាមានបងប្អូនស្លាប់ គឺបើ
16 និយាយទៅ ដូចអត់មានឃើញធ្វើបុណ្យ ធ្វើអីទេ ឃើញប្លែកផ្សេង គឺអត់មានថា ពេលដូចសម័យយើង
17 ឥឡូវ ពេលស្លាប់ទៅ មានធ្វើបុណ្យធ្វើទាន គគ្រឹកគគ្រាក់ទេ អត់ទេ។ ហ្នឹងគឺក្រោយពីខ្ញុំសឹកហើយ។
18 សូមឆ្លើយខ្លី។

19 **សៈ** តើលោក<យល់ឃើញ>យ៉ាងម៉េចដែរ <ចំពោះមេដឹកនាំនៃរបប>៣ឆ្នាំ ៨ខែ ២០ថ្ងៃ
20 នាពេលនោះ <គឺមេដឹកនាំអង្គការ>?

21 **ជៈ** បាទ ក្នុងៗរយៈកាលពាឆ្នាំហ្នឹង គឺដូចខ្ញុំបានជម្រាបហើយ។ ក្រោយពីខ្ញុំសឹកហើយ គេត្រូវ
22 យកខ្ញុំបញ្ជូលធ្វើស្មៀន ស្មៀនឃុំ។ ដល់ពេលគេយកខ្ញុំធ្វើស្មៀនឃុំហើយ ខ្ញុំ គេ ឃុំគេនឹងជ្រើសរើសយក
23 យុវជន គេហៅថា កាលនុំងគេផ្សព្វផ្សាយថា យុវជនល្អ អត់មានពាក់ព័ន្ធនិន្នាការ យកទៅធ្វើរោងចក្រ
24 ធ្វើជាកម្មករនៅរោងចក្រ។ តែដល់ក្រោយមក មានណា ខ្ញុំត្រូវ កម្លាំងខ្ញុំទាំងអស់ត្រូវបញ្ជូនមកភ្នំពេញ។
25 មកភ្នំពេញហើយ ដល់វ៉ារទេះភ្លើងហ្នឹង ឃើញឈ្មោះ ឈិន ៗហ្នឹង ទៅយកកម្លាំងខ្ញុំដូចបានឆ្លើយពីព្រឹក

1 មិញអ៊ីចឹង។

2 [១០:៥៧:៣៥]

3 **សៈ** អ្វីដែលខ្ញុំសូមសួរលោក គឺការយល់ឃើញលើរបបហ្នឹងជារួម ហើយនិងមេដឹកនាំ។ <តើ
4 លោកចូលចិត្តពួកគេទេ? តើលោកមានអារម្មណ៍យ៉ាងណាចំពោះពួកគេ?> លោកបានឆ្លើយនៅក្នុង
5 កំណត់ហេតុសម្ភាស ឬស្តាប់ចម្លើយរួចមកហើយ ក៏ប៉ុន្តែខ្ញុំចង់ឱ្យលោកជួយពន្យល់ ថាតើលោកយល់
6 ឃើញយ៉ាងម៉េចចំពោះមេដឹកនាំ និងរបបនាសម័យនោះ?

7 **ជៈ** បាទ របបក្នុងសម័យនោះ បើតាមខ្ញុំយល់ឥឡូវ ព្រោះថា ទី១ គឺអត់ៗមានសាសនា ហើយ
8 ប្រើកម្លាំងៗ គឺអត់គិតពីពលកម្មដូចសម័យឥឡូវ ថាពលកម្មកុមារនោះ។ សូម្បីតែមុនខ្ញុំបួស -- មុនខ្ញុំ
9 សឹក ក៏គេប្រើខ្ញុំទាំងព្រះសង្ឃដែរ ជីក។ប្រឡាយ លើកទំនប់ លើកទំនប់។ ពេលសឹកហើយហ្នឹង ដែល
10 នៅឃុំហើយហ្នឹង ក៏យកទៅជីកប្រឡាយ លើកទំនប់ដែរ។ ហ្នឹងគឺបញ្ហាមួយ។ បញ្ហាពីរ ការហូបចុក ក៏
11 ។មានការខ្វះខាតដែរ។ ធ្វើការអ៊ីចឹងទៅ ចេញមកហូបបបរណាយនឹងត្រកួន ហ្នឹងគឺសម័យហ្នឹង។ អ៊ីចឹង
12 យើញថា ទារុណកម្មរឿងខាងកម្លាំងពលកម្ម ហើយនិងសាសនាហ្នឹង គឺវាអត់មាន។សោះតែម្តង។
13 ប្រើ។កម្លាំងមិនគិត មិនគិតរឿងការហូបចុកអីទេ គឺចេញពីធ្វើការមកហូបបបរ។ បបរហ្នឹងណាយ
14 ត្រកួនទៀត។ បាទ នេះសូមបញ្ជាក់។

15 **សៈ** ព្រឹកមិញ លោកបានឆ្លើយអំពីរបៀបដែលរបបនោះប្រព្រឹត្តចំពោះគ្រួសារណាមួយ ដែល
16 ត្រូវបានគេរកឃើញថា មានកំហុស។ តើលោកជួយពន្យល់បន្ថែម លើចំណុចនេះបានដែរឬទេ?

17 **ជៈ** បាទ សម័យនោះ។ គឺបើសិនជា ខ្ញុំសូមឧទាហរណ៍មួយ ឧបមាថា ខ្ញុំជាកងទ័ពអ៊ីចឹង បើខ្ញុំ
18 ផ្តាច់ខ្លួនមកខាងរដ្ឋកម្ពុជាអ៊ីចឹង ប្រពន្ធកូនខាងក្រោយ គេចាប់ដាក់ក្នុងឃុំឃាំងទាំងអស់។ បាទ នេះគឺជា
19 ចំណុចមួយដែលគួរយើងចាប់អារម្មណ៍។ ពិសេសខ្លួនខ្ញុំផ្ទាល់ក៏។ចាប់អារម្មណ៍បញ្ហានេះដែរ។ បើថាប្តី
20 ខុសហើយ ប្រពន្ធអត់មានបញ្ហាអីទៅ គឺអត់អីទេ។ តែអានេះតែប្តីខុស គឺប្រពន្ធកូនហ្នឹងគឺមានបញ្ហា
21 តែម្តង។ សូមអស់។

22 [១១:០០:៣៩]

23 **សៈ** លោកបាន<>ប្រើពាក្យ<នៅក្នុងការសម្ភាសរបស់លោក អំពីបដិវត្តន៍។ លោក>ថា "ការ
24 ជាប់ពាក់ព័ន្ធទៅនឹងបដិវត្តន៍"។ ថាតើ លោកចង់និយាយថាដូចម្តេចដែរ ចំពោះការចូលរួមពាក់ព័ន្ធ
25 ជាមួយបដិវត្តន៍នេះ? ហើយតើវាប៉ះពាល់ទៅ ដល់អាយុជីវិតប្រជាជនដោយរបៀបណាដែរ?

ប្រធានអង្គជំនុំ៖

សូមអញ្ជើញលោកមេធាវី!

លោក វ៉ិចទ័រ កូប៉េ៖

ខ្ញុំសូមជំទាស់លោកប្រធាន។ សាក្សីអាចផ្តល់សក្ខីកម្មតែថា -- អាចឆ្លើយបានចំពោះតែខ្លួនគាត់ ហើយនិងអ្នកដែលគាត់ស្គាល់ជិតដិតទេ គាត់មិនអាចឆ្លើយទៅនឹងសំណួរព្រះរាជអាជ្ញាក្នុងន័យទូទៅបានទេ។

លោក នីកូឡាស គូមជែន៖

<វាគួរឱ្យចាប់អារម្មណ៍ណាស់។> គឺថានៅពេលដែលមេធាវីសួរ<អំពីអ្វីដែលបានកើតឡើង> នៅជុំវិញប្រទេស ជម្លោះជាមួយវៀតណាមជាដើម។ល។ ហើយ<និងប្រតិកម្មរបស់គាត់ចំពោះអ្វីដែល>ហ្វាយស្រុកពេលនោះ និយាយ<>។ ប៉ុន្តែខ្ញុំកែសំណួរទៅចុះ។

[១១:០១:៤៨]

សួរដោយលោក នីកូឡាស គូមជែន៖

ស៖ លោកសាក្សី នៅក្នុងអំឡុងនៃរបបនោះ លោកបានរៀនសូត្រអ្វីខ្លះ? ហើយថាតើរបបនោះបានប្រើប្រាស់ពាក្យហ្នឹង ហើយប្រព្រឹត្តចំពោះមនុស្សដែលរបបនោះ ចាត់ទុកថាជាខ្មាំងដោយរបៀបណាដែរ?

លោក វ៉ិចទ័រ កូប៉េ៖

ខ្ញុំគិតឃើញថា សំណួរនេះគឺសំណួរតែមួយ គួរតែមានសេចក្តីសម្រេចពីអង្គជំនុំជម្រះ។ <គាត់អាចឆ្លើយនូវអ្វីដែលបានកើតឡើងចំពោះខ្លួនគាត់ និងមនុស្សដែលគាត់ស្គាល់។ ប៉ុន្តែគាត់មិនអាចឆ្លើយនឹងសំណួរទូទៅ អំពី>អ្វី<ដែលបាន>កើតឡើង<ក្នុង>របបនោះទេ។

លោក នីកូឡាស គូមជែន៖

ប្រសិនជាយ៉ាងដូច្នេះ គឺថាត្រូវតែតវ៉ារាល់សំណួរដែលសួរតាំងពីព្រឹកមិញ <ជាពិសេសអំពីស្វាយ ដែលនៅឆ្ងាយពីគ្នាដល់ទៅ១០០គីឡូម៉ែត្រ ហើយដែល>សាក្សី<អត់បានដឹងឮអ្វីសោះ ហើយមេធាវីបានសួរ>គាត់ <សួរពីការយល់ឃើញរបស់គាត់>។

ចៅក្រម ក្លូឌា ហ្វេនស៍៖

ខ្ញុំគិតឃើញថា សំណួរនេះអាចសួរទៅបាន។ <នៅពេលដែលមានចម្លើយចេញមក យើងពិតជា

អាចសួរគាត់បាន> ដោយ<អនុញ្ញាតឲ្យវាទៅឆ្ងាយពីការដឹងរបស់គាត់> ថាតើការដែលគាត់ដឹងនោះគាត់ដឹងមកពីណាដែរ។ <យើងបានជជែកគ្នារួចហើយពីមុនមកនោះ។>

សួរដោយលោក នីកូឡាស គូមជែន៖

ស៖ តើពាក្យថា "ការជាប់ទាក់ទងជាមួយនឹងបដិវត្តន៍" នេះមានន័យយ៉ាងដូចម្តេចដែរ? តើលោកអាចពន្យល់បានទេ?

[១១:០៣:១៨]

លោក ជិន សារឿន៖

ជ៖ បាទ បញ្ហាទាក់ទងនឹងបដិវត្តន៍ហ្នឹងគឺ ខ្ញុំមិនសូវដឹងជាជ្រៅជ្រះអីទេ គ្រាន់ថា ជំនាន់ហ្នឹងគឺដូចខ្ញុំបានបញ្ជាក់ខាងដើមហើយ ថាប្រទេសរួចពីសង្គ្រាមមកគឺកសាង កសាងប្រទេសជាថ្មី បាទ កសាងប្រទេសថ្មី។ អីចឹងគឺពាក់ព័ន្ធនឹងនយោបាយអីៗ គឺខ្ញុំអត់យល់ទេ។

ស៖ ឥឡូវខ្ញុំសូមអានចម្លើយរបស់លោក ហើយសូមសួរលោកនូវសំណួរមួយចំនួន តើលោកយល់ដូចម្តេច។ នេះគឺខ្មែរ 00042517, បារាំង 01249779 ហើយអង់គ្លេស 01249757 ម្តងទៀត បាទ 01249757។ លោកបានឆ្លើយថា៖ "ខ្ញុំស្នាក់មេដឹកនាំក្នុងរបបពន្លាំ ៨ខែនេះណាស់។ រឿងដែលខ្ញុំស្នាក់នេះ គឺដោយសារថា ពួកគេ<ប្រមូលផ្តុំ>ប្រជាជន<គ្រប់ភូមិទាំងអស់ឲ្យ>ធ្វើការ <ប៉ុន្តែគេ>អត់ឲ្យអីហូបទេ។ <មូលហេតុទី២ ព្រោះ>ការជាប់ពាក់ព័ន្ធជាមួយនឹងបដិវត្តន៍នេះឯង។ ឧទាហរណ៍ បើសិនណាជាយើងមានបងប្រុស ហើយបើគេរកឃើញប្អូនប្រុស ឬឪពុកណាមួយជាប់ពាក់ព័ន្ធទៅជាមួយនឹងខ្មាំង សមាជិកគ្រួសារទាំងអស់ហ្នឹង ត្រូវបានគេចាត់ទុកថា ជាខ្មាំងហើយ។ នេះគឺជាកំហុសធ្ងន់ធ្ងរ <>។ ហើយលោកបានបន្តឆ្លើយថា នៅពេលបុគ្គលណាម្នាក់ធ្វើអ្វីខុស គឺថាគេនឹងយកទៅសម្លាប់ចោលហើយ។" បញ្ចប់ការដកស្រង់។ តើលោកអាចពន្យល់ជូនតុលាការបានទេ ថាមូលហេតុអ្វីបានជានាំឲ្យលោកយល់ឃើញថា នេះលោកស្នាក់មេដឹកនាំរបបនោះណាស់?

[១១:០៥:៤៨]

ជ៖ បាទ សូមឆ្លើយលើបញ្ហារបបនុ៎ងបាទ។ ស្នាក់របបនោះ គឺមូលហេតុទី១ គឺខ្ញុំបានបញ្ជាក់ហើយ ទី១ គឺប្រទេសដែលធ្លាប់មានសាសនា គឺត្រូវអត់មាន ជាលោកសង្ឃជាអីហ្នឹង។ ទី២ គឺប្រើធ្វើការពលកម្ម ហើយគ្មានស្បៀងអាហារគ្រប់គ្រាន់។ ទី៣ បើមានបញ្ហាបង ឬក៏ប្អូនហើយ យកកំហុសនិងយកតែបុគ្គលហ្នឹងទៅមានអី បើបង ឬក៏ឪពុកមានបញ្ហា ប្រពន្ធកូនក៏ជាលើកកំហុសដាក់គ្នាដែរ។

1 នេះដែលខ្ញុំមិនៗពេញចិត្ត។ ហើយមូលហេតុអីដែលមិនពេញចិត្តហើយ ដល់ខ្ញុំនៅតស៊ូដល់ៗថ្ងៃរំដោះនេះ
2 ទៀត គឺមូលហេតុវៀតណាមចូលក្នុងប្រទេសយើងទេ។ កុំអីហ្នឹង ខ្ញុំទៅនៅភូមិស្រុកខ្ញុំវិញហើយបាទ។
3 សូមឆ្លើយប៉ុណ្ណឹង។

4 **សៈ** ខ្ញុំមិនសួរលោកអំពីបញ្ហានេះទេ។ នៅក្នុងរបបនោះ គឺថាលោកនៅជាយុវជននៅឡើយ។ ខ្ញុំ
5 សួរទៅលោក ឲ្យលោកពន្យល់ជូនតុលាការថាតើលោកធ្លាប់បានឃើញអ្វីកើតឡើងទេ ក្នុងរឿងថា បើ
6 សិនណាជាមានបុគ្គលណាម្នាក់ត្រូវបានគេចោទប្រកាន់ថា ក្បត់បដិវត្តន៍ គឺថាសមាជិកគ្រួសារដទៃទៀត
7 ហ្នឹងក៏ត្រូវគេចាប់ខ្លួនដែរ? តើលោកអាចពន្យល់ជូនករណី ហើយធ្លាប់ជួបប្រទះករណីនេះទេ?

8 **ជៈ** បាទ សូមទោសដែលចម្លើយខ្ញុំអំមិញមិនសូវច្បាស់។ អ៊ីចឹងខ្ញុំសូមជាឧទាហរណ៍មួយ គឺខ្ញុំ
9 នៅព្រំដែនខាងលិច អ៊ីចឹងមានឈ្មោះ រ៉ែត ។ហ្នឹងជាកងពល៩១៦ អាហ្នឹងខ្ញុំឃើញ អ្វីដែលថាខ្ញុំឃើញគឺ
10 ខ្ញុំនិយាយបាន។ ហើយឯអ្វីដែលថា ខ្ញុំអត់ឃើញ គ្រាន់តែឮ ខ្ញុំអត់ប៉ាននិយាយទេ។ បាទ អ៊ីចឹងគឺ រ៉ែត
11 ហ្នឹងគាត់ទៅសារភាពជាមួយរដ្ឋកម្ពុជានៅសៀមរាប។ អ៊ីចឹងគឺគាត់រួចខ្លួនទៅ ឯប្រពន្ធកូននៅក្រោយ គឺ
12 យកទៅដាក់មន្ទីរឃុំឃាំង មួយកន្លែង។ អាហ្នឹងគឺ ប្តីមានបញ្ហា គឺប្រពន្ធត្រូវជាប់ឃុំឃាំង គឺគេត្រូវយក
13 ដាក់កន្លែងការឃុំឃាំងមួយ កាលនុំងគឺគេហៅថា “អូរកេងកង”។ អូរកេងកង អាហ្នឹងគឺនៅខាងម្តុំអន្លង់
14 វែង។ បាទ សូមឆ្លើយតាមសំណួរ សូមអស់។

15 [១១:០៩:១៤]

16 **សៈ** លោកសាក្សី ខ្ញុំសូមសួរទៅលោក ថាតើលោកធ្លាប់បើកឡានដែលមានស្លាកលេខ៥០២
17 ដែរទេ? គឺនៅពេលដែលលោកនៅមណ្ឌលគិរីនោះ លោកធ្លាប់បើកឡានពាក់ស្លាកលេខ៥០២ដែរទេ?

18 **ជៈ** បាទ ខ្ញុំមិនបានបើកទេ ប៉ុន្តែអង្គភាពនៅព្រំដែនហ្នឹង ស្លាកលេខឡានហ្នឹងគឺ៥០២។ កាល
19 នុំងឡាន គេហៅឡានអាកាត់ អាកាត់ព្រិច ដាក់ស្លាកលេខ៥០២ ឯបើកបរ មានគេបើកបរទេ។ គ្រាន់តែ
20 ថាអង្គភាពហ្នឹង ជាឡានរបស់អង្គភាព៥០២ ដែលក្នុងឯកសារខ្ញុំដែលដាក់ថា “៥២” នោះ តាមពិតគឺ
21 “អង្គភាព៥០២”។ គឺមានៗឃើញ ប៉ុន្តែរឿងបើកបរ ខ្ញុំអត់បានបើកទេ។

22 **សៈ** លោកសាក្សី តើប្រជាជនធម្មតានោះណ៎ា គាត់មានប្រតិកម្មយ៉ាងម៉េចដែរ ឬក៏គាត់មាន
23 អារម្មណ៍យ៉ាងម៉េចដែរ នៅពេលគាត់ឃើញឡានពាក់ស្លាកលេខ៥០២នេះបើកទៅ?

24 **ជៈ** បាទ ចំពោះប្រជាជននៅក្នុងស្រុក មិនថាមន្ត្រី មិនថាប្រជាជនទេ សំខាន់ប្រជាជនគឺតែ
25 ឃើញឡានហ្នឹងទៅហើយ គឺដឹងថាក្នុងភូមិឃុំស្រុកហ្នឹងមានបញ្ហាហើយ ព្រោះឡានហ្នឹងគឺទៅអត់សូវឮ

ទេ។ បើថាចង់រត់ៗអត់ទាន់ទេ។ គ្រាន់តែងឹត គឺដល់មុខផ្ទះតែម្តង។ បាទអាហ្នឹងគឺឡានហ្នឹង ខ្ញុំសំដៅត្រង់ថាឡានវាអត់ស្ងរឮ។ អ៊ីចឹងគឺគាត់ភ័យណាស់។ ចង់និយាយថា បើគាត់ណាមួយមានបញ្ហាអី គឺៗខ្លាចឡានហ្នឹងតែម្តង ខ្លាចត្រង់ថាវាអត់ឮ ទាល់ដល់បានឮតែម្តង។ បាទ អាហ្នឹងគឺអស់។

សៈ ហេតុអីបានឡាននេះធ្វើឲ្យប្រជាជនខ្លបខ្លាច? តើប្រជាជនគាត់ខ្លាចអ្នកដែលជិះនៅក្នុងឡានហ្នឹង ឬក៏យ៉ាងម៉េច? ម៉េចបានជាប្រជាជនពេលឃើញឡានហ្នឹងបើកទៅដល់កន្លែងគាត់ហ្នឹង គឺថាមានការភ័យខ្លាច?

[១១:១១:៥៤]

ជៈ បាទ ព្រោះបញ្ហាឡាននេះគឺអ៊ីចេះ ត្រង់ថាឡានហ្នឹងគឺទទួលបញ្ហាពីគណៈតំបន់។ តែឡានហ្នឹងចេញទៅ គឺមានបញ្ហាត្រូវហៅពីណា ឬបុគ្គលណាមានកំហុសអីហ្នឹង គឺគេយកឡានហ្នឹង។ បាទយកឡានហ្នឹងទៅៗហៅដល់ៗផ្ទះតែម្តង។ អាហ្នឹង គឺសូមបញ្ជាក់ប៉ុណ្ណឹង។ អ៊ីចឹងហើយបានតែប្រជាជនគាត់ចេះតែខ្លាច ព្រោះសម័យហ្នឹង ម្នាក់ៗគឺស្ថិតក្នុងការព្រួយបារម្ភណាស់។ ការព្រួយបារម្ភចង់និយាយថា បើមានបញ្ហាអីបន្តិចបន្តួចហ្នឹង គឺក្រែងលោខាងអង្គការគេចាត់ថ្នាក់អ៊ីចឹង ដោយមិនដឹងខ្លួន ខុសដោយៗអចេតនាទៅ គឺអត់ដឹងខ្លួន។ អ៊ីចឹងហើយបានថា ឃើញតែឡានហ្នឹងទៅ គឺភ័យមិនដឹងជាមានហេតុការណ៍កន្លែងណាទៀតហើយ។ អាហ្នឹងគឺដែលៗខ្ញុំបំភ្លឺហ្នឹងឯកសារហ្នឹង គឺមានប៉ុណ្ណឹងទេ។

សៈ នៅពេលដែលលោកនៅឯមណ្ឌលគិរី តើគេមានបានចាប់ខ្លួនប្រជាជនច្រើនទេ? ហើយឥឡូវយើងនិយាយអំពីប្រជាជនស៊ីវិល តើមានគេចាប់ខ្លួនជនស៊ីវិលច្រើនទេ?

ជៈ បាទ ខ្ញុំសូមឆ្លើយជូនលោកមេធាវី លោកប្រធានថា ដូចខ្ញុំបានបញ្ជាក់ពីដើមហើយថា ខាងស៊ីវិល ខ្ញុំអត់ស្ងរយល់ស្ងរដឹងអីទេ ព្រោះខ្ញុំនៅព្រំដែន នៅព្រំដែនវៀតណាមខាងកើតឯណោះ។ អ៊ីចឹងគឺខាងស៊ីវិល ខាងៗភូមិឃុំស្រុកនេះ គឺខ្ញុំអត់ស្ងរបានដឹងទេ។

សៈ បាទ សូមអរគុណលោកសាក្សី។ ឥឡូវខ្ញុំសួរអំពីកងទ័ពវិញម្តង តើគេមានបានចាប់កងទ័ពច្រើនទេ ទោះជាកងទ័ពតំបន់ក្តី កងទ័ពពីអង្គភាពណាក្តី <និងអ្នកដែលគេចោទថាជាខ្មាំង>?

[១១:១៤:១៣]

ជៈ បាទ ខ្ញុំសូមឆ្លើយបញ្ហានេះមួយគឺត្រង់ថា ខ្ញុំដឹងតែអង្គភាពខ្ញុំ ដូចខ្ញុំបានជម្រាបជូននៅអង្គប្រជុំ ពិសេសគឺសូមលោកប្រធានជ្រាបថា ពីកោះញែកទៅកន្លែងខ្ញុំនៅក្រង់តេះហ្នឹងគឺ ជាង១១០០គីឡូបន្តិចទេ ប៉ុន្តែមិនងាយ មិនងាយដឹង ហើយមិនងាយទៅដល់ដូចសម័យឥឡូវវាមានតេអូ មានទូរស័ព្ទទេ

អត់ៗដឹង។ ប៉ុន្តែចំពោះអង្គភាពខ្ញុំអត់មានបាត់បង់អីទេ ហូបក៏គ្រប់គ្រាន់ ធ្វើការពលកម្មតាមម៉ោងធម្មតា គឺអត់មានទេអង្គភាព។ និយាយមួយម៉ាត់ខ្ញុំរស់នៅ គឺជាមួយអង្គភាពការពារព្រំដែន។

សៈ ចុះអង្គភាពលោក ឬក៏ថាកងទ័ពមួយចំនួនណានោះ នៅក្នុងអង្គភាពលោកនោះ ចូលរួមពាក់ព័ន្ធក្នុងការដើរចាប់មនុស្សទេ?

ជៈ បាទ អង្គភាពខ្ញុំ គឺអត់មានទេ អត់មានទេ។ គឺចង់និយាយថា ពាក់ព័ន្ធចាប់មនុស្ស ចាប់អី ព្រោះវាដាច់ឡែកពីគ្នា ដាច់ឡែកពីគ្នា។ ព្រោះវានៅខាង គេថាខេត្ត ខេត្តហ្នឹងគឺនៅនឹងកោះញែកណោះ។ ឯខ្ញុំនេះនៅព្រំដែនណោះ។ អ៊ីចឹងគឺអត់មានបញ្ហាពាក់ព័ន្ធទេ បើមានសភាពការណ៍ព្រំដែន អាហ្នឹងគេបញ្ជាខាងខ្ញុំតែម្តង។

សៈ ឥឡូវនេះ ខ្ញុំសូមប្តូរប្រធានបទ ដោយចូលទៅនិយាយអំពីរឿងផ្សេងវិញម្តង។ លោកនោះបាននិយាយថា ប្រជាជនបានមកចូលនៅក្នុងខេត្តមណ្ឌលគិរី គឺមកពីវៀតណាម។ ដំបូងគឺប្រជាជនភាគច្រើននៅមណ្ឌលគិរីហ្នឹង តើពួកគាត់មានជាតិសាសន៍អ្វីដែរ? តើពួកគាត់ភាគច្រើនជាជនជាតិខ្មែរ ឬក៏ជនជាតិភាគតិច?

[១១:១៦:៤៦]

ជៈ នៅក្នុងមណ្ឌលគិរីហ្នឹង គឺជនជាតិភាគច្រើន គឺជនជាតិនៅមណ្ឌលគិរីនោះ វាមាន១១ជនជាតិឯណោះ ប៉ុន្តែខ្ញុំអត់ស្ទាវចាំទេ វាមានតែ ព្នង, ចារ៉ាយ, ឡាវ, ការ៉ែត, ទំពួន, កួយ, ទៀង ដែលចាំខ្លះ។ អ៊ីចឹងខ្មែរជនជាតិភាគតិចនេះ គឺតិចតួចទេ។ ច្រើនទើបតែពួកខ្ញុំឡើងមកហ្នឹង គឺបានច្រើនៗបន្តិច។ សំខាន់គឺជនជាតិភាគតិចរបស់គាត់ គឺច្រើន។ អាហ្នឹងអស់។

សៈ ចុះតើលោកដឹងថា ជនជាតិដើមភាគតិចនេះ ក៏មានរស់តាមព្រំដែនកម្ពុជាវៀតណាម<នៅក្នុងប្រទេសវៀតណាម>ដែរទេ?

ជៈ បាទជនជាតិដើមភាគតិចនេះ គឺកាលពីសម័យពន្ធាំនោះគឺអត់មានទេ អត់នៅទេ គឺប្រមូលមកនៅនឹងស្រុកកោះញែកទាំងអស់។ គឺតាមព្រំដែនមានតែកងទ័ព មានតែកងទ័ពទេ។ បាទ សូមអស់សំណួរ។

សៈ ប្រហែលជាមានការយល់ច្រឡំទៅនឹងសំណួររបស់ខ្ញុំ។ សំណួររបស់ខ្ញុំសួរដូចជា ចារ៉ាយ ព្នងជាដើមនេះ តើពួកគាត់នេះ <មាន>រស់នៅក្នុងទឹកដីវៀតណាមដែរទេ <ក្រៅពីរស់នៅខេត្តមណ្ឌលគិរី>? <បើលោកមិនដឹងទេ លោកថាមិនដឹងទៅ។>

ជ៖ បាទ ចំពោះឯប្រទេសវៀតណាម ខ្ញុំអត់ដឹងទេ។ ប៉ុន្តែដឹងថា ក្នុងប្រទេសយើង ប្រទេសកម្ពុជានេះ ដោយឡែកនៅនឹងខេត្តមណ្ឌលគិរីនេះគឺមាន។ នេះខ្ញុំចង់និយាយៗឲ្យដាច់ដោយឡែកពីគ្នា។ ពីសម័យមុនសង្គ្រាម គឺគាត់នៅតាមភូមិជនបទគាត់ ជំនឿរបស់គាត់ គឺគេហៅថា ចម្ការវិលជុំឯណោះទេ។ តែដល់សម័យ៣ឆ្នាំនេះ គឺខាងអង្គការត្រូវប្រមូលតាមភូមិឃុំ គឺមករស់នៅនឹងស្រុក នឹងស្រុកកោះញែកទាំងអស់។ អត់មាននៅតាមភូមិចាស់ៗទេ គឺមកនៅតាមទីរួមស្រុកនៅ និងខេត្តទាំងអស់គ្នា។

[១១:១៩:៣៣]

ស៖ នៅក្នុងឆ្នាំ១៩៧៦ និង៧៧ តើលោកមាននឹកឃើញថា មានកម្លាំងមួយក្រុម ឬចលនាមួយក្រុម គេហៅថា “ចលនាហ្វុលរ៉ូ” <បានចូលមកខេត្តមណ្ឌលគិរី> លោកធ្លាប់ឮទេ?

ជ៖ បាទ ចំពោះកម្លាំងចលនា គេហៅថាចលនាតស៊ូរបស់ហ្វុលរ៉ូហ្នឹង គឺមិនថាឮទេ គឺឃើញតែម្តង។ កាល៧៦, ៧៧ ដើមឆ្នាំ៧៨នេះគឺ កម្លាំងហ្នឹងគឺមកពីប្រទេសវៀតណាមហ្នឹងតែម្តង គេហៅថា “ចលនាហ្វុលរ៉ូ”។

ស៖ តើអ្នកនៅក្នុងចលនាហ្វុលរ៉ូនេះជាអ្នកណា?

ជ៖ បាទ ចលនាហ្វុលរ៉ូនេះគឺខ្ញុំ ជាប្រធានរបស់គេ ខ្ញុំអត់ស្គាល់ ហើយអត់ដឹងទេ ប៉ុន្តែគេហ្នឹងគេមានសាសន៍គេ វាមានចារ៉ាយ វាមានរដែ ហើយវាមានកាហាទៀត មានកាហា ហើយក្រៅពីហ្នឹងគឺមានទៀត ប៉ុន្តែខ្ញុំអត់ស្ទាវចាំទេ គឺដឹងថាចារ៉ាយ កាវ៉ែត ហើយនិងកាហា។

ស៖ លោកសាក្សី ពេលខ្លះលោកចាត់ទុកអ្នកទាំងនោះថាជាកងទ័ពវៀតណាមដែរទេ?

ជ៖ បាទ កាលដំបូងកម្លាំងហ្នឹងមក ខាងពួកខ្ញុំនៅព្រំដែន គឺដឹងថាកម្លាំងវៀតណាមដែរម្តង អត់ដឹងថាកម្លាំងហ្វុលរ៉ូ ជាកម្លាំងតស៊ូអីទេ ជាដំបូង គឺថាៗវៀតណាមចូលទឹកដីតែម្តង។ តែដល់ពេលមានការទាក់ទងជាមួយប្រធានខ្ញុំដែលឈ្មោះ ខាំ វៀង ហ្នឹងដែលចេះភាសាគ្នាគាត់ទៅ គាត់ប្រាប់ថាកម្លាំងហ្នឹង គឺកម្លាំងតស៊ូ ជាកម្លាំងរបស់ជនជាតិភាគតិចរបស់វៀតណាម ដែលថាតស៊ូរំដោះទឹកដីគេ។ អ៊ីចឹងបានៗដឹងថាកម្លាំងហ្វុលរ៉ូនោះ។ កាលពីដំបូងមក ចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧អីនេះ គឺស្មានថាវៀតណាម ប៉ុន្តែបើរូបរាងនោះវៀតណាមហើយ ប៉ុន្តែជនជាតិរដែ ជនជាតិអីហ្នឹងទេ។ បាទសូមអស់។

[១១:២២:២៩]

ស៖ លោកសាក្សី នៅពេលគេប្រាប់លោកអំពី ស្វាយ នេះ គឺថាលោករស់នៅ១០០គីឡូម៉ែត្រពីនេះ ហើយលោកថាលោកមិនដែលបានឃើញកម្លាំងកងទ័ពវៀតណាម១២នាក់នេះទេ ត្រឹមត្រូវដែរទេ?

ជ៖ បាទ អត់ៗបានឃើញទេ ដែលចង្ហើយខ្ញុំថាមាន១២នាក់នេះ គឺការផ្សព្វផ្សាយរបស់មេដែលគាត់ឡើងទៅប្រជុំ បានមកវិញគាត់ផ្សាយ ផ្សព្វផ្សាយទៅ ដែលឃើញគឺខ្ញុំអត់បានឃើញទេ។

ស៖ តើលោកដឹងថាមេបញ្ជាការរបស់លោកនោះ ប្រាប់ការពិត ឬក៏អត់ទេ?

ជ៖ បាទ លោកមេបញ្ជាការខ្ញុំ គឺតាមខ្ញុំក្តាប់មើលទៅវាជាការពិតហើយ ព្រោះគាត់ផ្សព្វផ្សាយអ៊ីចឹង ហើយក្រោយមកទៀតដែលវៀតណាមចូលទឹកដីកម្ពុជាមកនេះ ហើយខាងខ្ញុំបានជួបជាមួយបងប្អូនដែលនៅកោះញែកហ្នឹងគេនិយាយដូចគ្នាអ៊ីចឹងដែរ អ៊ីចឹងបានន័យថាគាត់ផ្សព្វផ្សាយជាការពិត។

ស៖ អ្វីដែលយើងបានស្តាប់ឮព្រឹកមិញនេះមានភស្តុតាងបង្ហាញថា មានមនុស្សគាត់ហូប<មី> ហើយក្រោយមកក៏រត់ចូលទៅវៀតណាមវិញ ហើយអត់បានវាយប្រយុទ្ធគ្នាអីទេ។ តើ<នេះជាអ្វីដែល> លោក<បានឮនៅពេលនោះទេ? លោកមិនបានឮអ្វីទេអំពីការប្រយុទ្ធគ្នា ការធ្វើវិទ្ធង្សនាទេ ក្រៅតែអំពី> ការជួបជុំគ្នាហូបចំណីអាហារ ហើយចូលទៅវៀតណាមវិញ អត់មានការធ្វើវិទ្ធង្សនា ឬក៏វាយប្រយុទ្ធគ្នាអីទេ តើអ៊ីចឹង ឬក៏យ៉ាងណា?

ជ៖ បាទ បញ្ហាហ្នឹងខ្ញុំអត់ៗដឹងទេ ខ្ញុំអត់ដឹងទេ។

ស៖ តើលោកដឹងថា ស្វាយ មានជនជាតិដើមជាអ្វីទេ? តើគាត់ជាជនជាតិចារ៉ាយ ឬក៏ជាជនជាតិអ្វី?

[១១:២៤:៥៨]

ជ៖ តាមខ្ញុំឮតៗ គាត់ហ្នឹងជនជាតិចារ៉ាយលាយទំពួន ត្រង់ថាម៉ែទំពួន ឪចារ៉ាយអី អត់ដឹងទេ ប៉ុន្តែគ្រាន់ឮគេនិយាយអ៊ីចឹង។

ស៖ នៅពេលមេបញ្ជាការរបស់លោកប្រាប់លោកអំពីកងទ័ពទាំង១២នាក់នេះ <គាត់បាន> ប្រាប់លោកថា ហេតុអ្វីបានជា<គេ>សម្លាប់<អភិបាលស្រុកឈ្មោះ> ស្វាយ <តើមែនទេ>? <តើគាត់បានព្យាយាមពន្យល់លោកថាហេតុអីបានជាគេសម្លាប់អភិបាលស្រុកនោះទេ?>

ជ៖ បាទ ការផ្សព្វផ្សាយរបស់មេបញ្ជាការខ្ញុំត្រូវផ្សព្វផ្សាយនៅអង្គភាពខ្ញុំ គឺអត់មែនថា វៀត-ណាមហ្នឹងមកសម្លាប់ ស្វាយ ទេ ថា ស្វាយ ហ្នឹងជាខ្សែរបស់ -- វៀតណាមហ្នឹងជាខ្សែរបស់ ស្វាយ។ អ៊ីចឹងអ្នកផ្សេងទៀតទេ គេសម្លាប់ ស្វាយ នោះ។ អាហ្នឹងគឺតាមការផ្សព្វផ្សាយរបស់គាត់គឺអ៊ីចឹង។

ស៖ មេបញ្ជាការរបស់លោកបានប្រាប់លោកថា អង្គការហ្នឹងគឺតាមដេញចាប់ ស្វាយ ហើយក៏ប្រាប់ពីមូលហេតុដែលគេព្យាយាម ហេតុអ្វីបានជាគេតាមចាប់គាត់ អ៊ីចឹងមែនទេ?

ជៈ បាទ បញ្ហាហ្នឹងគឺខ្ញុំអត់ដឹងដែរ។ ដឹងថាពេលគាត់ត្រឡប់ទៅវិញ គាត់ផ្សព្វផ្សាយថា ឥឡូវនេះ ស្វាយ លាក់វៀតណាម១២នាក់ជិតផ្ទះ គ្រាន់ប៉ុណ្ណឹងទេ។ ត្រង់ថាតាមតែអី អាហ្នឹងគឺដោយឡែក ព្រោះវាមានចែកគ្នាដាច់ដោយឡែកពីគ្នា។ ៥០១ គេទទួលខាងខេត្តទៅ ខាង៥០២ ឬក៏៥២ហ្នឹងគេទទួលព្រំដែន។ អ៊ីចឹងខាងខ្ញុំ ខាងព្រំដែន មិនសូវដឹងផ្នែកក្នុងខាងក្នុងទេ។ បាទ សុំអស់។

សៈ <ហើយ>លោកមិនដឹង<ទេ> ឬក៏<បើ>លោក<ដឹងសូម>ប្រាប់មកយើង។ <តើ>លោកដឹងថា <វៀតណាម>ទាំង១២នាក់<>ហ្នឹង ជាសមាជិករបស់ចលនាហ្វុលរ៉ូ ឬក៏អត់ទេ ពីព្រោះពួកទាំង១២នេះគឺបានចូលមកមណ្ឌលគិរី ហើយហូបចុកអីជាមួយប្រជាជន?

[១១:២៧:៣១]

ជៈ បាទ ខ្ញុំបានស្បថជាមួយលោកតាហើយ។ ខ្ញុំថារឿងអ្វីដែលខ្ញុំដឹង គឺខ្ញុំប្រាប់។ បើឃើញ ខ្ញុំថាឃើញ បើឮ ខ្ញុំបានបញ្ជាក់ជាមួយកន្លែងជំនុំជម្រះនេះថាឮ។ អ៊ីចឹងគឺគ្រាន់តែឮទេ ត្រង់ថាដឹងជាយ៉ាងម៉េច១២នាក់ហ្នឹងគឺជាហ្វុលរ៉ូ គឺជាវៀតណាម គឺខ្ញុំអត់ដឹងទេ។ ក៏ប៉ុន្តែដូចខ្ញុំបានជម្រាបខាងដើមអ៊ីចឹងកាលពីមុន មិនទាន់ដឹងថាហ្វុលរ៉ូទេ ទាល់តែយូរក្រោយមកបានជួបគ្នាទៅ បានដឹងចលនាហ្វុលរ៉ូ ចលនាតស៊ូរបស់ជនជាតិភាគតិចរបស់វៀតណាម។

សៈ ខ្ញុំគិតថាខ្ញុំមានពេលវេលាសួរសំណួរលោកតែមួយសំណួរទៀតទេ។ <ព្រឹកមិញនេះមេធាវីគាត់បានអានឲ្យលោកស្តាប់ នូវកិច្ចសម្ភាសន៍រវាង>មជ្ឈមណ្ឌលឯកសារកម្ពុជា<ជាមួយ>ឈ្មោះ ឡាន់ គឺ E3/7822។ ហើយខ្ញុំសុំអានឲ្យលោកស្តាប់<បន្តែមទៀត>។ នោះជាកិច្ចសម្ភាសន៍ខ្សែរ 00229231, បារាំង <00665354>, អង់គ្លេស 00667377។ ឡាន់ បានប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា សុំដកស្រង់៖ “គេបានចោទ ស្វាយ ថាបាន<បណ្តោយឲ្យប្រជាជន>ទាក់ទងជាមួយវៀតណាម។ តាមការពិត អ្នកទាំងអស់គឺថាមានការទាក់ទងជាមួយវៀតណាម។ គេចង់បិទបាំងភស្តុតាងមិនឲ្យអ្នកណាដឹងទេ។ ស្វាយ គាត់មិនយល់ទេ ហើយគាត់ខឹងសម្បាណាស់ គាត់ខឹងមែនទែន ពីព្រោះថាអ្នកណាក៏ដោយ ម្នាក់ៗគឺថាបានចូលរួមនៅក្នុងអង្គប្រជុំនេះ។”

ហើយប្រាំពីរទំព័រមកក្រោមទៀតនោះថា <គាត់>បានឆ្លើយថា<>៖ “<គឺ> ឡាំង ដែលមានហេតុផលជួបជាមួយនឹងវៀតណាម។ ប៉ុន្តែដោយសារហេតុតែការជួបនោះ ជួបនៅខាងក្រោយផ្ទះ <> ស្វាយ អ៊ីចឹង ស្វាយ ក៏ត្រូវគេចោទប្រកាន់តែម្តងទៅ។” តើលោក<ដឹងទេ ថាតើ ឡាន់ និយាយអំពី> ការជួបប្រជុំក្នុងចំណោមថ្នាក់ដឹកនាំទាំងអស់ គឺថ្នាក់ដឹកនាំស្រុក និងថ្នាក់ដឹកនាំតំបន់ជាមួយនឹងចលនា

ហ្វុលរ៉ូ <ឬសមាសធាតុផ្សេងទៀត ឬ>ជួបជាមួយនឹងជនភៀសខ្លួនពីវៀតណាម <អាចថា អ្នកប្រឆាំងនឹងរបបវៀតណាម>? បើសិនណាជាលោកដឹង<>សូមលោកជម្រាបជូនតុលាការ។ បើមិនដឹង ឆ្លើយថាមិនដឹង។

[១១:៣០:២៦]

ជៀ៖ បាទ ខ្ញុំ បញ្ហានេះគឺមិនដឹងអីទាំងអស់។ គឺដឹងតែ ដូចខ្ញុំបញ្ជាក់ខាងដើមហ្នឹង ដឹងតែពេលមេខ្ញុំទៅផ្សព្វផ្សាយថា ស្វាយ លាក់ជនជាតិវៀតណាមទេ។ ត្រង់ថាលាក់ហ្វុលរ៉ូលាក់អី គឺអត់ដឹងទេ គ្រាន់ដឹងថា គាត់ទៅពីប្រជុំវិញ គាត់ប្រាប់ថា ស្វាយ យក។វៀតណាម១២នាក់នៅក្បែរផ្ទះ។ គ្រាន់តែប៉ុណ្ណឹងទេ រឿងដឹងអីទៀត អត់ដឹងអីទាំងអស់។

ប្រធានអង្គជំនុំ៖

អរគុណលោកព្រះរាជអាជ្ញា។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះឈប់នៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣១ នាទី)

[១៣:៣១:០៨]

ប្រធានអង្គជំនុំ៖

សូមអញ្ជើញអង្គុយ!

ជាបន្តសូមអញ្ជើញលោកព្រះរាជអាជ្ញាមានសំណួរបន្តទៀត លើសាក្សីរូបនេះ។

សួរដោយលោក នីកូឡាស គូមជែន៖

ស៖ សួស្តីលោកសាក្សី។ ខ្ញុំចង់ត្រឡប់ទៅលើកឡើងឯកសារមួយដែលមេធាវីការពារក្តីបានលើកឡើងកាលពីព្រឹកមិញជូនលោក ឯកសារ E3/799។ មេធាវីបានពន្យល់<ថាគាត់អានសុន្ទរកថារបស់> សុន សេន ដែលវាពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ៧៦ គឺភាសា<ទាំងបីនៅ>ត្រង់ទំព័រ<ដូចគ្នាគឺ> 00184780 សុន សេន បានលើកឡើងដូចតទៅ៖ "វៀតណាមមានភាពលំបាកលំបិនក្នុងផ្ទៃក្នុងខ្លួនឯង។ <សម្បុរស្រីរកស៊ីផ្លូវភេទ។> ប្រជាជនគ្មានការងារធ្វើ គ្មានថវិកា <ដើរសុំ>លុយ និងមានជម្លោះផ្ទៃក្នុងខ្លួនឯង។" ដូច្នេះអ្វីដែលខ្ញុំចង់សួរលោក ដោយសារតែលោកជាសមាជិករបស់កងទ័ពតំបន់ តើលោកបានដឹងពីមេរបស់លោកដែរឬទេ ថាមានជម្លោះផ្ទៃក្នុងនៅប្រទេសវៀតណាមនាពេលនោះ?

លោក ជិន សារឿន៖

ជ៖ ស្តាប់អត់បាន ស្តាប់អត់បាន។

ស៖ សូមអធ្យាស្រ័យ ខ្ញុំព្យាយាមពន្យល់លោក ព្យាយាមសម្រាយជូនលោក។ សូមអរគុណ។ តើលោកឮខ្ញុំទេលោក? សួស្តីលោកសាក្សី។ ខ្ញុំអម្បាញ់មិញសួរអំពីសុន្ទរកថារបស់ សុន សេន ដែលមេធាវីការពារក្តីសួរលោក។ នៅក្នុងសុន្ទរកថានោះ គាត់លើកឡើងនៅចុងឆ្នាំ៧៦ថា៖ "វៀតណាម ខ្លួនឯងមានបញ្ហាផ្ទៃក្នុង ហើយមានជម្លោះផ្ទៃក្នុងចំណោមប្រជាជនវៀតណាមគ្នាឯង។" ក្នុងនោះក្នុងនាមលោកជាសមាជិកកងទ័ពតំបន់នៅតាមព្រំដែន តើលោកមានរកឃើញភស្តុតាងដែលបង្ហាញ ឬក៏អាចដឹងតាមរយៈជនភៀសខ្លួនដែលចូលមកក្នុងប្រទេសកម្ពុជា ដែលជាជនជាតិភៀសខ្លួនវៀតណាមនោះអាចលើកឡើងអំពីបញ្ហាដែលខ្ញុំលើកឡើងអម្បាញ់មិញនេះ នៅក្នុងប្រទេសវៀតណាម?

[១៣:៣៤:៣២]

ជ៖ បាទ សូមគោរពលោកប្រធាន។ សូមឆ្លើយលើសំណួរនេះ គឺថា ខ្ញុំនៅការពារព្រំដែន អ៊ីចឹង គឺព្រឹត្តិការណ៍ដែលដឹងថា កម្លាំងចូលមកគឺក្នុងចន្លោះឆ្នាំ៧៧, ៧៨។ បាទ សូមបន្តែម។

ស៖ ខ្ញុំសូមសួរអំពីជនភៀសខ្លួនអម្បាញ់មិញនេះដែលមកពីប្រទេសវៀតណាម។ ឯកសារមួយ -- ខ្ញុំសូមសួរឯកសារមួយ ឯកសារ E3/1664 ជាសៀវភៅចំណងជើងថា "ការបោសសម្អាតខ្មែរក្រហមនៅខ្ពង់រាប មណ្ឌលគិរី" <និពន្ធដោយ> សារ៉ា ខូម និង សុរិយ៉ា សឹម។ <ខ្ញុំសូមអាននៅទំព័រ ៩៨> សៀវភៅនេះគឺមិនបានបកប្រែជាភាសាខ្មែរនោះទេ <ដូច្នេះខ្ញុំគ្រាន់តែប្រាប់លេខទំព័រសៀវភៅនេះ

តែប៉ុណ្ណោះ> គឺបានលើកឡើងថា--

ចៅក្រម ក្លូឌា ហ្វេនស៍៖

សូមបញ្ជាក់ឯកសារឡើងវិញ លេខប៉ុន្មាន?

សួរដោយលោក នីកូឡាស គូមជែន៖

ស៖ <00397671> <ទំព័រ៩៨> ឯកសារនេះអត់មានជាភាសាខ្មែរនោះទេ។ <>នៅក្នុងជំពូកទី១០ ខ្ញុំអានចេញពីជំពូកទី១០ ចំណងជើងថា "ការបោសសម្អាត<ជនជាតិព្នងអ្នកឆ្លងកាត់> ព្រំដែន<>"។ <ឯកសារនេះសរសេរថា> "<ជនជាតិព្នង>ផ្សេងទៀត គឺថាត្រូវបានគេសម្លាប់ចោលដោយសារតែមានសាច់ញាតិនៅវៀតណាម។ <ការស្នើសុំទៅលេងបងប្អូននៅវៀតណាម> អាចឲ្យមានការសង្ស័យ<>។ ឪពុករបស់ជនជាតិ<ព្នងម្នាក់ ឈ្មោះ> ព្រាល ដែលរស់នៅប្រទេសកម្ពុជាក្រោយពេលប្រពន្ធរត់ទៅវៀតណាម ត្រូវបានគេសម្លាប់ចោល ក្រោយពេលស្នើសុំអនុញ្ញាត<ទៅ>លេងប្រពន្ធ។" តើលោកបានឃើញ ឬបានដឹងទេពីការចាប់ខ្លួនប្រជាជនពីក្រុមជនជាតិភាគតិចនោះដោយសារតែពួកគាត់មានសាច់ញាតិនៅប្រទេសវៀតណាម ឬក៏ស្នើសុំទៅលេងសាច់ញាតិនៅប្រទេសវៀតណាម?

[១៣:៣៦:៥៩]

លោក ជិន សារឿន៖

ឆ៖ បាទ បញ្ហាហ្នឹងខ្ញុំអត់ដែលបានយល់ ហើយបានដឹងទេ។

ស៖ បាទ មិនអ្វីទេ។ <តើ>លោក<បានទទួលបញ្ជាបែបណា បើលោកបាន>ឃើញជនជាតិស៊ីវិលឆ្លង<ពីវៀតណាម>មកចូលប្រទេសកម្ពុជា<>?

ឆ៖ បាទ ខ្ញុំអត់ដែលបានឃើញទេ។

ស៖ តើលោកមានដែលបានទទួលបញ្ជា<ឲ្យ>ធ្វើអ្វី ចំពោះអ្នកទាំងឡាយដែលគាត់ចូលមកប្រទេស កម្ពុជា ឬក៏ឆ្លងចូលទៅប្រទេសគេដែរឬទេ?

ឆ៖ បាទ បញ្ហាហ្នឹងមិនដែលមានហេតុភេទអីទេ។ គ្រាន់ថាបើសិនជាមានជំនាន់៧៨នេះ បើមានប្រជាជនមកពីវៀតណាម ឃើញខាងអង្គការគេបញ្ជូនទៅភ្នំពេញ។ អត់មានធ្វើទុក្ខបុកម្នេញអីគាត់ទេ។ តែបញ្ជូនដល់ណាៗខ្ញុំអត់ដឹងដែរ គ្រាន់ថាមកតាមរយៈឆ្លងដែនមកម្នាក់ពីរម្នាក់អ៊ីចឹង សួរទៅថាជាហ្នុលរ៉ូអ៊ីចឹង គឺបញ្ជូនទៅតាមរយៈឃុំស្រុក។

[១៣:៣៨:២៥]

សៈ សូមអរគុណ។ ខ្ញុំសូមសួរអំពីហ្វុលរ៉ូ ដែលលោកបានឆ្លើយនៅព្រឹកមិញ ជាពិសេសហើយនិងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកផងដែរ។ ខ្ញុំអានចេញមកពីជំពូកសៀវភៅដែល ពាក់-ព័ន្ធនឹងបញ្ហាហ្វុលរ៉ូ ទំព័រ<១១១> <ERN ជាភាសាអង់គ្លេស>00397684។ "ពាក់ព័ន្ធនឹងបញ្ហា <បង្ក្រូបបង្ក្រូម>វៀតណាមនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ៧៥ អ្នក<រស់នៅតំបន់ខ្ពង់រាបក្នុងប្រទេសវៀត-ណាម> ដែល<ធ្លាប់>ធ្វើការងារជាមួយនឹងកម្លាំងពិសេស<សហរដ្ឋអាមេរិក> ឬ<ហៅថា>ហ្វុលរ៉ូ <>ត្រូវបានបញ្ជូនទៅ<>ជំរំ<រៀនសូត្រ>។ <អ្នករស់នៅតំបន់ភ្នំជាច្រើននៅក្នុងប្រទេសវៀតណាម បានខូចទឹកចិត្តជាមួយនឹង>របបថ្មី<យ៉ាងឆាប់រហ័ស> ដោយសារតែ<>គោលនយោបាយនៃការដាក់ ប្រមូលផ្តុំប្រជាជនមួយកន្លែង <ការ>អប់រំ និងការបញ្ជ្រាបចំណេះដឹងទៅដល់ប្រជាជនជនជាតិភាគ តិច ហើយបង្កើតតំបន់សេដ្ឋកិច្ចថ្មី <និង>ការជម្លៀសប្រជាជនភាគតិចវៀតណាម<មកកាន់>ដែនដី ជីដូនជីតារបស់ពួកគេ។"

តើលោកធ្លាប់ឮជនជាតិភាគតិច<>រស់នៅក្នុងមណ្ឌលគិរី <ធ្លាប់>លើកឡើងអំពីបញ្ហា<ទាំង អស់នេះទេ ជាពិសេសការធ្វើទុក្ខបុកម្នេញដែល>សាច់ញាតិរបស់ពួកគាត់រងគ្រោះនៅក្នុងប្រទេសវៀត ណាម? តើធ្លាប់ឮជនជាតិភាគតិចទាំងអស់នោះលើកឡើងបញ្ហានេះដែរឬទេ?

ជៈ បាទ បញ្ហាហ្នឹងក៏ខ្ញុំអត់ដែលដឹង ដែលឮដែរ។

សៈ ដើម្បីឲ្យច្បាស់ទាំងអស់គ្នា តើត្រឹមត្រូវដែរឬទេ លោកជាជនជាតិខ្មែរ ហើយលោកមិន ចេះនិយាយភាសារបស់ជនជាតិភាគតិច ឬជនជាតិដើមភាគតិចណាមួយនោះទេ។ លោកចេះតែនិយាយ ភាសាខ្មែរតែប៉ុណ្ណោះ។ មែនដែរឬទេ?

ជៈ បាទ ខ្ញុំអត់ចេះភាសាជនជាតិភាគតិចទេ។ អ៊ីចឹងក្នុងអង្គភាពហ្នឹងមានគេចេះដែរ យើង និយាយទៅ គេបកប្រែឲ្យមក។

[១៣:៤០:៥៧]

សៈ សូមអរគុណ។ ទំព័របន្ទាប់ទៀតនៅក្នុងសៀវភៅហ្នឹង សៀវភៅដែលខ្ញុំអានអម្បាញ់មិញ ជំពូកទី១០ ពាក់ព័ន្ធនឹងហ្វុលរ៉ូ។ "វាមិនយូរ<ប៉ុន្មាន>មុនពេល<>កងកម្លាំងហ្វុលរ៉ូ <>អ្នកភាគច្រើន <ដែល>រត់ចូលព្រៃ ក្រោយពេលដែលវៀតណាមខាងត្បូងនោះចុះចាញ់ អ្នកទាំងអស់នោះ <អ្នកទាំង អស់នោះបាន>បង្កើតចលនា<តស៊ូទ័ពព្រៃ>ឡើងវិញ។ នៅពេលនោះចលនាហ្វុលរ៉ូនោះ គឺធ្វើឡើង

ដើម្បីប្រឆាំងទីក្រុងហាណូយ។ នៅពេលដែលគេរំដោះវៀតណាមបាន ហ្វុលរ៉ូស្ថិត<មានទីតាំង>នៅតាមទីកន្លែងនានា <>ជាក្រុមតូចៗ <>នៅ<តាមភូមិព្នង នៅ>ប្រទេសវៀតណាម។ ពួកគាត់គិតថាចលនាគាត់នឹងអាចផ្ទួលរំលំរដ្ឋាភិបាលវៀតណាមបាន។”

ខ្ញុំសូមបញ្ចប់ចំណុចដកស្រង់របស់ខ្ញុំនៅទំព័រដដែលនោះទេ។ ខ្ញុំសូមអានបន្ត គឺបានបញ្ជាក់ថា៖ “នៅក្នុងត្រឹមឆ្នាំ១៩៧៧ ហ្វុលរ៉ូព្យាយាមស្នើសុំការគាំទ្រពីខ្មែរក្រហមក្នុងការតស៊ូប្រដាប់អាវុធ ដើម្បី<តស៊ូប្រដាប់អាវុធប្រឆាំងនឹង>របបថ្មីនៅក្នុងប្រទេសវៀតណាម។ <ពួក>គេ<មិនបាន>ដឹងថា ខ្មែរក្រហមបានសម្លាប់មេៗរបស់គេកាល២ឆ្នាំមុន<ទេ>។ ឆ្នាំ៧៧ ក្រុម<ចំនួនពីរ>បានចុះកិច្ចសន្យាធ្វើការផ្លាស់ប្តូរព័ត៌មាន និងបណ្តុះបណ្តាលគ្នា។ ឆ្នាំ១៩៧៨ <យុទ្ធជន>ហ្វុលរ៉ូបានប្រកាសតាមវិទ្យុ<ក្រុងភ្នំពេញបរិហារ>ហូជីមិញ។ អៀង សារី <នៅពេលនោះជារដ្ឋមន្ត្រីការបរទេសរបស់ខ្មែរក្រហម>បានលើកឡើងនៅក្នុងឆ្នាំ១៩៧៩ថា “ហ្វុលរ៉ូមកទាក់ទងយើង សុំសហប្រតិបត្តិការដើម្បីធ្វើការផ្លាស់ប្តូរព័ត៌មានគិញសម្ងាត់ ហើយនិងធ្វើការបណ្តុះបណ្តាលផ្នែកយោធា”។

លោកសាក្សី តើលោកបានទទួលព័ត៌មានណាមួយដែរឬទេ នៅពេលដែលលោកនៅព្រំដែននោះ ក្នុងពេលដែលលោកជាវ័យជំទង់ មានវ័យជំទង់ -- តើលោកបានដឹងអំពីការចរចា និងការចុះកិច្ចសន្យារវាងហ្វុលរ៉ូ និងរបបខ្មែរក្រហមនាពេលនោះដែរឬទេ?

[១៣:៤៣:១១]

ឆ៖ បាទ ខ្ញុំសូមឆ្លើយបញ្ជានេះ។ ការទំនាក់ទំនង និងមុនពេលដែលស្គាល់គ្នា ខ្ញុំអត់បានដឹងរឿងរាក់ជ្រៅអីទេ ដឹងតែត្រឹមពេលមកដល់សួរថា ជាជនជាតិហ្វុលរ៉ូហើយ អាហ្នឹងគឺចាប់បញ្ជូនតាមភូមិ តាមឃុំទៅដល់ខេត្ត។ ហ្នឹងរឿងដែលកាលនៅជំនុំជម្រះគ្នា ចរចាគ្នា និយាយគ្នា ទំនាក់ទំនងគ្នា ខ្ញុំអត់ៗយល់ទេ។ ដឹងតែត្រឹមពេលមក សួរថា បើសិនជាជនជាតិហ្វុលរ៉ូឲ្យបញ្ជូនទៅខេត្ត។ អរគុណ។

ស៖ សូមអរគុណ។ តើលោកអាចពន្យល់បន្តិចបានដែរឬទេ អំពី<>ហ្វុលរ៉ូដែលត្រូវបានគេចាប់ខ្លួននៅកន្លែងរបស់លោកនោះ ហើយគេបញ្ជូនទៅ តើបញ្ជូនទៅណាដែរលោក?

ឆ៖ បើកាលណាបានទទួលកម្លាំងហ្នឹងហើយ ម្នាក់ក៏ដោយពីរនាក់ក្តី គឺបញ្ជូនទៅកោះញ្ជែកកោះញ្ជែក ព្រោះកោះញ្ជែកនេះ ជាតំបន់ បើនិយាយទៅដូចឥឡូវនេះជាខេត្ត ទីរួមខេត្ត ត្រូវបញ្ជូនទៅនុំង។ ឯខាងថាទៅណាៗទៀត ខ្ញុំអត់បានដឹងទេ គឺដឹងតែបានទទួលពីព្រំដែនទៅ ជូនទៅខេត្ត។

ស៖ សូមអរគុណ។ មានរូបថតមួយ<សន្លឹក> ដែលខ្ញុំចង់បង្ហាញសាក្សី <គឺឯកសារដែល

1 មានលេខ> E3 <គឺ> 8639.3944 លោកប្រធាន។ ខ្ញុំមានរូបថតនេះជារូបថតផ្ទាល់តែម្តង ហើយ
2 សូមអនុញ្ញាតពីលោកប្រធាន បញ្ចាំងនៅលើ អេក្រង់ផងដែរ តាមបច្ចេកទេសរបស់យើង យើងអាច
3 បញ្ចាំងបានលោកប្រធាន។

4 **ប្រធានអង្គជំនុំ៖**

5 សូមអញ្ជើញលោកព្រះរាជអាជ្ញា!

6 **លោក នីកូឡាស គូមជែន៖**

7 ខ្ញុំមានបន្ថែមទៀតដែរ រូបថតហ្នឹង បើសិនជាមេធាវីការពារក្តីចង់បាន បានខ្ញុំអាចចែកជូនបាន។
8 [១៣:៤៥:៤២]

9 **សួរដោយលោក នីកូឡាស គូមជែន៖**

10 **ស៖** លោកសាក្សី រូបថត<>នេះ គឺជារូបថតបុរសម្នាក់ឈ្មោះ ប៊ិញហ៊ី បាន ចេញមកពី
11 កំណត់ហេតុស-២១ គឺរូបថតនេះចេញមកពីស-២១។ តើលោកមើលឃើញស្ពាកដែលនៅខាងឆ្វេង
12 ហោប៉ៅរបស់គាត់ទេ ហាក់ដូចជាមានសញ្ញាទង់ជាតិនោះ? តើលោកស្គាល់ទេ?

13 **លោក ជិន សារឿន៖**

14 **ជ៖** បាទ ក្នុងរូបភាពនេះ ខ្ញុំផ្ទាល់អត់ដែលឃើញ ដែលស្គាល់ទេ។ អត់ទេ អត់ដែលស្គាល់ទេ។

15 **ស៖** តើលោកធ្លាប់ដែលឃើញទង់ជាតិរបស់ចលនាហ្វូលរ៉ូទេ?

16 **ជ៖** បាទ ទង់ជាតិរបស់ហ្វូលរ៉ូ មិនដឹងទេ គ្រាន់តែស្គាកសញ្ញាគេដូចហ្នឹង ផ្គាកសញ្ញាដែលខ្ញុំ
17 បានឃើញនៅនឹងអាវរបស់គេពាក់ ឃើញ មិនដឹងជាទង់ជាតិ មិនដឹងជាស្គាកអីទេ ប៉ុន្តែឃើញដូចហ្នឹង
18 បាទ។

19 **ស៖** សូមអរគុណ។ ខ្ញុំត្រឡប់ សូមត្រឡប់ទៅវិញ<និយាយអំពី ស្វាយ> លោកនិយាយថា មេ
20 របស់លោកប្រាប់ថា គេចាប់ <ស្វាយ ដោយសារតែមានជនជាតិវៀតណាម>១២នាក់ <>ក្នុងភូមិ
21 ហ្នឹង។ ហើយ<គេបានអានឲ្យលោកស្តាប់>ថា គាត់ចូលរួម<ក្នុងការប្រជុំមួយ ដែលមានចែកមីឲ្យ
22 ប្រជាជនហូប>។ ខ្ញុំចង់លើកឡើងនូវសក្តីកម្មនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ ឆ្នាំហ្នឹង គឺសក្តីកម្មរបស់
23 សាក្សី។ ឯកសារ E3/409--
24 [១៣:៤៧:៣៥]

25 **អ្នកបកប្រែ៖**

បាទ លោកប្រធាន សូមអនុញ្ញាតឱ្យព្រះរាជអាជ្ញាបញ្ជាក់លេខ ERN ឡើងវិញ។

ប្រធានអង្គជំនុំ៖

សូមលោកព្រះរាជអាជ្ញាបញ្ជាក់លេខ ERN ឡើងវិញ ដើម្បីឱ្យអ្នកបកប្រែបកបាន។

សួរដោយលោក នីកូឡាស គូមជែន៖

ស៖ គឺប្រតិចារឹករបស់អង្គជំនុំជម្រះ ឯកសារគឺ E1/409.1។ សាក្សី ប៊ុន ឡឹងចួយ បានផ្តល់ចម្លើយមុនម៉ោង៣:៣០នាពេលរសៀលថ្ងៃនុំង ថ្ងៃទី២៨ ខែ៣ ឆ្នាំ២០១៦ បានលើកឡើងថា៖ “ហម, តាសារុន ហើយនិង ខាំ ភូន បានចោទ <ស្វាយ> ថាលាក់គិញវៀតណាម។ ហើយបន្ទាប់មក <ស្វាយ> ហ្នឹង ត្រូវបានយកមកសួរចម្លើយ ហើយពេលនោះ គេនិយាយថា អត់មានលាក់<គិញវៀត-ណាមមួយណា>នោះទេ។ <ជាការពិត> ស្វាយ <មានទំនាក់ទំនងជាមួយសមាជិក>ចលនាហ្វូលរ៉ូ <ហើយមិនមែនជាវៀតណាមបច្ចុប្បន្នទេ>។ ខ្ញុំបានដឹងអំពីបញ្ហានេះ<ពីអ្នកដែលធ្លាប់រស់នៅជាមួយស្វាយ>។” តើលោកធ្លាប់បានឮថា ស្វាយ ធ្លាប់ជជែកនៅក្នុងកិច្ចសន្ទនាណាមួយជាមួយនឹងចលនាហ្វូលរ៉ូទេ? តើលោកធ្លាប់ឮទេ?

លោក ជិន សារឿន៖

ឆ៖ បាទ ចំពោះខ្ញុំមិនអាចដឹងដល់រឿងនេះទេ អត់ដឹងសោះ។

ស៖ ព្រឹកមិញ ខាងសហសេវិករបស់ខ្ញុំ ជាមួយខ្ញុំ ឮខុសគ្នាបន្តិច។ ខ្ញុំចង់សួរលោកអំពី ស្វាយ ហើយនិងអ្នកដែលជា១២នាក់ហ្នឹង តើជាជនជាតិអ្វី? ហើយលោកបានលើកឡើងថា ក្រោយមក លោកដឹងថា អ្នកទាំង១២នាក់នោះ គឺជាជនជាតិ ជនជាតិអីដែរ សូមលោកបញ្ជាក់ឡើងវិញ?

[១៣:៤៩:៥០]

ឆ៖ បាទ ចំពោះ១២នាក់នេះ គឺខ្ញុំអត់បានឆ្លើយថា ជាជនជាតិអីទេ ក៏ប៉ុន្តែគ្រាន់តែថា សួរថា ស្វាយ ហ្នឹងជាជនជាតិអី អ៊ីចឹងព្រឹកមិញនេះ ខ្ញុំឆ្លើយថាជនជាតិចារ៉ាយ ទំពួន។ ឯ១២នាក់ អត់ៗដឹងទេ។

ស៖ <តើ>លោកបានលើកឡើង<ទេ>ថា អ្នកទាំង១២នាក់នោះ ក្រោយមកនោះលោកដឹងថាជាពួកហ្វូលរ៉ូ តើអ៊ីចឹងដែរឬទេ?

ឆ៖ កាលពីខ្ញុំទទួលពីមេរបស់ខ្ញុំគាត់មកផ្សព្វផ្សាយ អត់ថាហ្វូលរ៉ូទេ គាត់ថាយួន១២នាក់មកអីចឹងហ្នង។ ទាល់តែក្រោយទៀតទេ បានដឹង អ្នកផ្សេងទេ ចំពោះអ្នក១២នាក់ហ្នឹងគឺគាត់ថាយួន។

ស៖ ខ្ញុំយល់។ តែព្រឹកមិញនេះ តើលោកមានបាននិយាយថាក្រោយមក លោកដឹងព័ត៌មាន

ផ្សេងៗអំពីបញ្ហាអ្នក១២នាក់នោះ ថាគាត់ជាជនជាតិអឺ ជាក្រុមអឺ តើលោកបាននិយាយទេ? ក្រោយមក តើលោកដឹងថាទាំង១២នាក់ហ្នឹងស្ថិតនៅក្នុងក្រុមណាដែរឬទេ?

ជៈ បាទ ខ្ញុំព្រឹកមិញ ខ្ញុំដូចអត់បាននិយាយទេ១២នាក់ហ្នឹង ប៉ុន្តែគ្រាន់តែខ្ញុំនិយាយថាពីមុនៗនឹងដឹងដំណឹងថាហ្វុលរ៉ូហ្នឹង គឺពួកខ្ញុំគឺដឹងថាឃួនតែម្តង។ ដល់ក្រោយមកមិនដឹងគេចរចាយ៉ាងម៉េចទេ មេគាត់ណែនាំថា បើមក គេឆ្លើយថាចលនាហ្វុលរ៉ូកុំធ្វើអីគេ ជូនគេទៅតាមខ្សែរយៈចុះ។ តែប៉ុណ្ណឹងទេ។

[១៣:៥២:០០]

សៈ ខ្ញុំយល់ហើយ សូមអរគុណលោកច្រើន។ តែពេលនេះ ខ្ញុំចង់សូមសួរលោកអំពីឯកសារមួយចំនួនដែលយើងមានជាភាសាផ្សេងៗ គឺឯកសារ E3/1022 ជាទូរលេខទៅបង៨៩ ដែលយើងជឿជាក់ថាជា សុន សេន។ នៅក្នុងឯកសារនេះ កថាខណ្ឌទី១បានលើកឡើងថា៖ “ខ្ញុំសូមរាយការណ៍អំពីស្ថានការណ៍នៅព្រំដែន។ ពួកគេបានពង្រាយ<កម្លាំងជួរមុខរបស់ពួកគេ>នៅតាមអូរដាក់ដាំ ទំនប់អូរដាក់ដាំ ដែលមានអាវុធយុទ្ធភណ្ឌគ្រប់ប្រភេទ ហើយគេលើកឡើងថា៥ថ្ងៃទៀត គេនឹងពង្រាយនៅក្នុងទឹកដីរបស់យើង៥គីឡូម៉ែត្រពីព្រំដែន។ ពួកគេបានលើកឡើងថាកងទ័ពហ្នឹងគឺជាកងទ័ពរបស់ធីវ ហើយប្រាប់យើងឲ្យដកថយ។” តើលោកស្គាល់ទេក្រុម<កងទ័ព>ធីវនោះ<ជាអ្វី? តើនោះជាអតីតប្រធានាធិបតី>វៀតណាមខាងត្បូងនោះ<ដែលប្រឆាំងនឹងពួកកុម្មុយនីស្តឈ្មោះ ង្វៀន ធី មែនទេ>?<>

ជៈ បាទ បញ្ហានេះ ខ្ញុំក៏អត់បានដែលដឹង ហើយស្គាល់ដែរ អត់ស្គាល់ទេ។

សៈ បាទសូមអរគុណ។ មិនអីទេ ខ្ញុំសូមសួរទូរលេខមួយទៀត ឯកសារE3/1204 តេឡេក្រាមសារពា៤បញ្ជូនទៅអឺម-៧០ – ម-៧០។ នៅក្នុងកថាខណ្ឌ៥ គឺលើកឡើងថា “បុគ្គលបីនាក់ដែលរត់មកពីស្ទឹងត្រែង គឺជាខ្មាំងច្បាស់តែម្តង។ ពួកនេះ<មាន>កាន់រូប សីហនុ។ ម្នាក់ឈ្មោះ ជឿ ជាយោធាភូមិភាគឦសាន ឥឡូវនេះសម្រេចយ៉ាងណា<បោស>សម្អាត<នៅទី>នេះ ឬជូនទៅ<ភូមិភាគ>ឦសាន។” តើលោកបានទទួលបញ្ជា<ណាមួយ ឬក៏>ធ្វើការសង្កេតទៅលើ<សកម្មភាពណាមួយរបស់កងកម្លាំងខ្មែរក្រហមនៅតំបន់>របស់លោក<ក្នុងការបោសសម្អាតអ្នកដែល>គាំទ្រ<>សីហនុ <ទេ>?

ជៈ បាទ បញ្ហាហ្នឹងក៏ខ្ញុំមិនបានដឹងដែរ អត់ដឹងទេ។

[១៣:៥៥:០០]

សៈ សូមអរគុណ។ សាក្សីមួយទៀត បានឆ្លើយនៅថ្ងៃទី១០ ខែមីនា ឆ្នាំនេះ។ ឯកសារនោះគឺ E1/399.1*(ស៊ីក)* ត្រង់ម៉ោង១១:២៨នាទី នាពេលព្រឹក។ គេសួរគាត់ថា តើមានវៀតណាមនៅក្នុងស្រុក

1 របស់គាត់នៅចន្លោះ<> ខែមេសា ឆ្នាំ៧៥ ដល់៧៨ ដែលឬទេ? <ចាន់ តូច> សាក្សីពីមណ្ឌលគិរីបាន
2 លើកឡើងថា "តាមការអង្កេតរបស់គាត់អត់មានទេ ដោយសារតែរបបនោះនៅពេលនោះ គឺបានអនុវត្ត
3 គោលយោបាយយ៉ាងតឹងរ៉ឹង។ ជនជាតិវៀតណាមណាមួយដែលគេរកឃើញ សូម្បីតែម្នាក់ក៏ដោយ ត្រូវ
4 បានគេជ្រើសរើសដកចេញ ហើយស្លាប់ចោល"។ ខ្ញុំចង់សុំសួរលោក<នូវអ្វីដែលលោកបានសង្កេត> តើ
5 គោលនយោបាយរបស់របបខ្មែរក្រហមពេលនោះ ដែលអនុវត្តចំពោះជនជាតិវៀតណាម <ខ្ញុំ>មិនមែន
6 <និយាយពី>ជនជាតិភាគ<តិច>ដូចជា<>ព្នង <ឬចារ៉ាយ ដែលជាជនជាតិភាគតិចវៀតណាមនោះ
7 ទេ គឺខ្ញុំនិយាយអំពីជនជាតិវៀតណាមតែម្តង> ថាតើមានគោលនយោបាយ<ចំពោះអ្នកទាំងនោះទេ ឱ្យ
8 ពួកគេរស់នៅ ឬក៏>សម្លាប់<>ចោល<>?

9 **អ្នកបកប្រែ៖**

10 សុំកែតម្រូវគឺសាក្សី ចាន់ តួយ។

11 **លោក ជិន សារឿន៖**

12 **ជ៖** បាទ បញ្ហានេះគឺខ្ញុំក៏អត់បានដឹងច្រើនដែរ ប៉ុន្តែការផ្សព្វផ្សាយនិងការអប់រំរៀនសូត្រ
13 ក្នុងអង្គភាពមានតែភារកិច្ច ១) គឺការពារ, ២) និងកសាងបង្កបង្កើតផល ប៉ុណ្ណឹងទេដែលគេផ្សព្វផ្សាយ
14 ឱ្យខ្ញុំ។

15 [១៣:៥៦:៥៦]

16 **សួរដោយលោក នីកូឡាស គូមជែន៖**

17 **ស៖** សូមអរគុណ។ នៅសល់ទូរលេខមួយទៀតដែលវាពាក់ព័ន្ធ <គឺ>ឯកសារ E3/877 គឺ ផ្ញើ
18 ជូនបងជាទីគោរព<និងនឹករឭក>៨៧០, ម-៨៧០។ នៅក្នុងកថាខណ្ឌទី១ គឺមានកាលបរិច្ឆេទថ្ងៃ
19 <២០> ខែឧសភា ឆ្នាំ៧៧ នៅមុខព្រួញដាក់ដាំ "កម្ទេចពួកយួន ស្លាប់នឹងកន្លែងម្នាក់"។ កថាខណ្ឌទី២
20 "នៅថ្ងៃទី១៨ ឧសភា ៧៧ កងពល<លេខ២> បានចាប់ពួកយួនចំនួនពីរនាក់ ចាប់នៅខាងមុខព្រួញកែវ
21 សីមា និងស្រែព្រះ។ ពួកនេះនៅខាងអាធីវ ពាក់សព្តិ៍១, សព្តិ៍២។ វាសុំទៅស្រុកបាវាំង។" នៅខាងក្រោម
22 ទូរលេខនេះគឺចុះហត្ថលេខាដោយ ឆាន ហើយដាក់ថា "ថែម"។ សរសេរថែមថា "អំពីបញ្ហាយួននេះ
23 បានសម្រេចហើយ"។ តើលោក ថាតើជនជាតិវៀតណាមដែលប្រឆាំងនឹងរបបហាណូយ រួមទាំងអ្នក
24 ដែលជាកម្មាភិបាលរបស់របបធីវនោះ ត្រូវបានចាប់នៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានសម្លាប់ចោល
25 ក្នុងប្រទេសនេះផងដែរ តើលោកបានដឹងទេ?

ជៈ បាទ បញ្ហានេះក៏អត់បានទទួលដំណឹងអីដែរ។ ខ្ញុំអត់ដឹងទេ។

សៈ បាទ សូមអរគុណ។ ប្រធានបទមួយទៀត ដែលខ្ញុំចង់សុំសួរលោក ប្រហែលជាលោកអាចដឹង។ តើលោក<ធ្លាប់ទៅមើល ឬក៏>មានតួនាទីអ្វី ពាក់ព័ន្ធទៅនឹងបញ្ហាមន្ទីរសន្តិសុខនៅភ្នំក្រោលដែរឬទេ? តើលោកមានតួនាទី ឬមានបានដឹងទេ?

ជៈ បាទ បញ្ហាសន្តិសុខភ្នំក្រោលនេះ គឺខ្ញុំក៏អត់បាន និយាយទៅដូចខ្ញុំបានបញ្ជាក់ពីព្រឹកមិញអ៊ីចឹងថា តំបន់ហ្នឹងជិតទេ ប៉ុន្តែដូចឆ្ងាយណាស់ មិនងាយបានទៅ។ អ៊ីចឹងខ្ញុំគ្រាន់ថា បើគ្រាន់តែឮៗ វាមិនហ៊ាននិយាយឲ្យលោកប្រធាន ទាំងអង្គប្រជុំបានដឹងទេ វាគ្រាន់តែឮ ព្រោះមិនបានឃើញ ហើយនិងបានដឹង ព្រោះវានៅឆ្ងាយ។

[១៣:៥៩:៣៧]

សៈ តើលោកធ្លាប់ឮអ្វីបន្តិច ឬក៏អត់ដែលឮសោះ ថាតើមនុស្សប្រភេទណាដែលត្រូវបានគេឃុំខ្លួននៅមន្ទីរសន្តិសុខភ្នំក្រោល?

ជៈ បាទ នេះបញ្ហានេះ ខ្ញុំមិនបដិសេធទេ ហើយខ្ញុំសូមឆ្លើយត្រង់ គឺថាដឹង ឮៗ ប៉ុន្តែមិនបានឃើញ។ ឮៗចង់និយាយថា អ្នកដែលគេទៅជាមួយមេបញ្ជាការអ៊ីចឹង ហើយពេលគេត្រឡប់មកវិញអ៊ីចឹងទៅ គេថាសន្តិសុខនៅកន្លែងភ្នំក្រោលអ៊ីចេះមួយ អ៊ីចេះមួយ ប៉ុន្តែថាឃើញ ខ្ញុំអត់បានឃើញទេ គ្រាន់តែឮ មាននៅសន្តិសុខនៅភ្នំក្រោល។

សៈ តើលោកនៅចាំព័ត៌មានដែលលោកឮហ្នឹង<ទេ?> តើ<លោកអាច>ប្រាប់<បានទេ មេបញ្ជាការរបស់>លោក ពន្យល់លោកម៉ែចខ្លះដែរ? មនុស្សប្រភេទណា ដែលគេឃុំនៅទីនោះ ប៉ុន្មាននាក់ ហើយអ្នកទាំងអស់នោះ ធ្លាប់ត្រូវបានគេដោះលែងវិញ ឬក៏អ្នកទាំងអស់នោះត្រូវបានគេកម្ទេចចោល?

ជៈ ថាបញ្ហានេះ គឺអត់ៗដឹងទេ អត់ដឹង។

សៈ សូមអរគុណ។ លោកបានជម្រាបថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺថាលោកមានអាយុពី១៦ ទៅ១៩ឆ្នាំ ចន្លោះពីឆ្នាំ៧៥ ទៅដល់<៧៨>។ តើសមមិត្តរួមអាវុធរបស់លោកហ្នឹង ជាទូទៅហ្នឹង មានអាយុប៉ុន្មានឆ្នាំដែរ ពេលនោះ?

ជៈ បាទ ជំនាន់ហ្នឹង ចន្លោះហ្នឹង អាយុក្រោម២០ ក្រោមអាយុ២០ ក្រោម២០ចុះ។

[១៤:០១:៥១]

សៈ ក្រោមអាយុ២០ឆ្នាំ ចុះយុទ្ធជនជាទូទៅដែលមានអាយុក្មេងបំផុតហ្នឹង អាយុប៉ុន្មានឆ្នាំដែរ?

ជ: បាទ ក្រោមបំផុត ប្រហែលជា១៧ អ៊ីចឹងចន្លោះហ្នឹង ១៧មក២០ ២០ទៅ១៧ វានៅក្មេង។

ស: តើលោកអាចជម្រាបជូនតុលាការបានទេថា ឃុទ្ធជនទាំងអស់ហ្នឹង គោរពតាមបញ្ជា ធ្វើតាមអ្វីដែលលោកបានប្រាប់ អនុវត្តតាមវគ្គរៀនសូត្រនយោបាយអីដែរទេ? ហើយក៏តើលោកអាចជម្រាបជូនតុលាការបានទេ <តើវាដូចម្តេចដែរនៅពេលនោះ ហើយ>ហេតុអ្វីបានជាឃុទ្ធជនក្មេងៗទាំងអស់ហ្នឹង គោរពតាមបញ្ជាទាំងអស់នោះ?

ជ: បាទ ខ្ញុំសូមឆ្លើយលើបញ្ហាហ្នឹង។ ឃុទ្ធជនក្រោម អាយុក្រោម២០ឆ្នាំ គឺបានទទួលការអប់រំពីអង្គភាព អត់មានអីក្រៅពីថា ប្រទេសយើងឆ្លងពីសង្គ្រាមមក ត្រូវខំកសាង កសាង ហើយនិងអ្នកអនាគតនឹងអាចបញ្ជូនទៅការពារជាតិ។ កាលចន្លោះហ្នឹង ខ្ញុំនៅនឹងកងចល័តនៅឡើយទេ កងចល័តៗហ្នឹង គឺសម្រាប់តែបង្កបង្កើតផល បង្កបង្កើតផលខាងក្រោយ។ សូមអស់។

ស: តើមានការដាក់វិន័យអីទេ ចំពោះអ្នកណាដែលមិនគោរពតាមបញ្ជាណាមួយនោះ?

ជ: បាទ ជារួម ខ្ញុំមិនបានយល់ជ្រៅជ្រះទេ ទូទាំងខេត្ត។ នេះ ខ្ញុំនិយាយតែក្នុងអង្គភាពខ្ញុំ ដែលនៅប្រចាំជាមួយកងទ័ពព្រំដែននេះ ឃើញថាអត់មានដាក់ទោស ដាក់ពៃរ៍អីទេ។ បើសិនជាមានបញ្ហាខុសឆ្គង ហៅមកអប់រំ អប់រំ ហើយកែប្រែធម្មតាទេ អាហ្នឹងគឺចំពោះតែអង្គភាពខ្ញុំទេ ឯទូទាំងខេត្ត ខ្ញុំអត់ៗបានដឹងទេ។

[១៤:០៤:៤០]

ស: ខ្ញុំមានសំណួរមួយទៀតទេ ពាក់ព័ន្ធទៅនឹងចម្លើយចុងក្រោយនេះ។ យោងតាមប្រតិចារឹកដែលតុលាការទទួលបាន ឯកសារបានពីស-២១ គឺឯកសារនេះរួមមានការចាប់ខ្លួនមនុស្សមកពីកងពល ៩២០។ ហើយនៅក្នុងសៀវភៅដែលខ្ញុំបានអានឲ្យលោកស្តាប់ពីខាងដើម និយាយអំពីការបោសសម្អាតនៅខេត្តមណ្ឌលគិរីនោះ គឺថាមានបញ្ជីមួយដែលមានរៀបរាប់កងឃុទ្ធជនដល់ទៅ៤០០នាក់ មកពីកងពល៩២០ដែលត្រូវបានបញ្ជូនខ្លួនមកស-២១។ តើលោកអាចជម្រាបជូនតុលាការបានទេ ថាហេតុអ្វីបានជាឃុទ្ធជនទាំងអស់ដែលគេបញ្ជូនមកពីមណ្ឌលគិរីត្រូវគេសម្លាប់?

ចៅក្រម ក្លូឌា ហ្វេនស៍:

លោកសហព្រះរាជអាជ្ញា នៅពេលដែលគាត់កំពុងតែគិតរកចម្លើយនេះសូមលោកផ្តល់លេខឯកសារយោងផង។

លោក នីកូឡាស គូមជែន:

1 នេះគឺជាឧបសម្ព័ន្ធ<"ឃ"> គឺបញ្ជី<សម្គាប់>ស-២១ <មកពីតំបន់១០៥។ បញ្ជីនេះចាប់ផ្តើម
2 ពី>ERN <00397712> ហើយ ERN ចុងបញ្ចប់គឺ 00397726។

3 **សួរដោយលោក នីកូឡាស គូមជែន៖**

4 **ស៖** លោកសាក្សី តើលោកមានបានដឹងទេ ថាហេតុអ្វីបានជាអ្នកទាំងអស់នេះ ត្រូវបញ្ជូនមកពី
5 មណ្ឌលគិរីឲ្យមកភ្នំពេញ ហើយត្រូវបានគេសម្លាប់ចោលនោះ?

6 **លោក ជិន សារឿន៖**

7 **ជ៖** បាទ ខ្ញុំសូមឆ្លើយបញ្ហោហ្នឹងគឺ ក្រោយពីខ្ញុំផ្លាស់ពី៩២០ ទៅតំបន់១០៥ គេហៅថា នៅវរ
8 សេនាតូច៥០២មក គឺសភាពការណ៍ និងការងារផ្ទៃក្នុងរបស់៩២០ គឺខ្ញុំអត់បានដឹងទេ អត់ដឹងទេ។

9 [១៤:០៧:២៣]

10 **លោក នីកូឡាស គូមជែន៖**

11 សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

12 **ប្រធានអង្គជំនុំ៖**

13 អរគុណលោកព្រះរាជអាជ្ញា។ ជាបន្ត--

14 **កញ្ញា សុង ឆវ៉ន្ត៖**

15 សូមទោសលោកប្រធាន ដោយសារនៅមានប្រធានបទតូចមួយទៀត ដោយសារខាងសហព្រះ
16 រាជអាជ្ញានៅសល់ពេលវេលាបន្តិចទៀតដែរ អ៊ីចឹងស្នើសុំការអនុញ្ញាតពីលោកប្រធានដើម្បីសួរសំណួរ
17 លើប្រធានបទតូចមួយចុងក្រោយ។

18 **ប្រធានអង្គជំនុំ៖**

19 សូមអញ្ជើញ!

20 **កញ្ញា សុង ឆវ៉ន្ត៖**

21 ចាស អរគុណលោកប្រធាន។ សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ភាគី
22 និងអង្គសវនាការទាំងមូល។

23 **សួរដោយកញ្ញា សុង ឆវ៉ន្ត៖**

24 **ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ សុង ឆវ៉ន្ត ជាតំណាងសហព្រះរាជអាជ្ញាជាតិ។
25 ខ្ញុំនៅសល់ប្រធានបទតូចមួយចង់ពិភាក្សាជាមួយលោកដែរ ពាក់ព័ន្ធជាមួយនឹងអាពាហ៍ពិពាហ៍ដោយ

បង្ខំ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកបានឆ្លើយនៅក្នុងកំណត់ហេតុដែលលោកបានធ្វើការពិភាក្សាជាមួយនឹងខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ពីការរៀបការរបស់លោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោកនៅចាំទេថា លោករៀបការនៅក្នុងឆ្នាំណាដែរ នៅពេលនោះ?

[១៤:០៨:៤៤]

ប្រធានអង្គជំនុំ៖

លោកសាក្សី ចាំមីក្រូហ្វូនប្រតិបត្តិការក្រហមសិន ចាំឆ្លើយ បាទ។

លោក ជិន សារឿន៖

ជ៖ បាទ ចំពោះការបង្ខិតបង្ខំ ឬការងារពលកម្មនេះ គឺខ្ញុំបានឆ្លងកាត់អស់ហើយ គឺលំបាកណាស់។ ដូចខ្ញុំបានឆ្លើយជាមួយក្រុមស្រាវជ្រាវអ៊ីចឹង។ គឺវ័យក្មេង ហើយត្រូវធ្វើការច្រើន ហើយខ្វះខាតជីវភាព។

សួរដោយកញ្ញា សុង ឆវ៉ន្ត៖

ស៖ សុំទោសលោកសាក្សី ដោយសារខ្ញុំកំពុងតែពិភាក្សាជាមួយនឹងរឿងអាពាហ៍ពិពាហ៍ រឿងរៀបការ។ ហើយបន្តិចទៀត ខ្ញុំនឹងពិភាក្សាជាមួយនឹងស្ថានភាពការងារ។ ប៉ុន្តែឥឡូវនេះ យើងនិយាយគ្នាអំពីរឿងរៀបការសិន។ តើលោករៀបអាពាហ៍ពិពាហ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមែនទេ? ហើយប្រសិនបើនៅក្នុងអំឡុងពេលនោះមែន លោកនៅចាំឆ្នាំពិតប្រាកដទេ ថាក្នុងឆ្នាំណាដែរ?

ជ៖ បាទ ចំពោះការរៀបការ ខ្ញុំរៀបនៅឆ្នាំ ខែថ្ងៃអត់ដឹងទេ ដឹងតែឆ្នាំ១៩៧៧ បាទ១៩៧៧។

[១៤:១០:០១]

ស៖ លោកអាចបញ្ជាក់បានទេថា ពេលនោះលោករៀបការជាមួយអ្នកណា? ហើយការរៀបចំហ្នឹងយ៉ាងណាដែរ? លោកជាអ្នកសម្រេចរើសអ្នកដែលលោកត្រូវរៀបការជាមួយ ឬក៏មានការរៀបចំ? ហើយបើសិនបើមាន អ្នកណាជាអ្នកសម្រេចឲ្យមានការរៀបចំការរៀបការនោះ?

ជ៖ បាទ ចំពោះបញ្ហានេះ គឺមេបញ្ជាការខ្ញុំហ្នឹងគាត់សួរ បាទនុ៎ងសួរហ្មង អត់មានការចាប់បង្ខំទេ ព្រោះអ៊ីចឹងបានខ្ញុំៗបានឆ្លើយហើយថា ដោយឡែកខុសតែអង្គភាពខ្ញុំដែលនៅព្រំដែនទេ។ គឺសួរត្រឹមត្រូវ ប៉ុន្តែគ្រាន់ថារៀបការហ្នឹង គឺមិនមែនមួយគូ ពីរគូទេ។ ខ្ញុំការហ្នឹងប្រាំមួយដណ្តប់គូ ប្រាំមួយដណ្តប់គូ។ អ៊ីចឹងគឺការហូបចុកហ្នឹង កាលនុ៎ងវានេះដែរ គោមួយចំហៀង គោមួយចំហៀង ហើយមាន់មួយចំនួនអ៊ីចឹង។ ដល់អ៊ីចឹងគឺអត់មានអាចារ្យមានអីទេ ដូចថា ដូចយើងអង្គុយអ៊ីចឹងទៅគូៗៗទៅ ណែនាំ

1 បានគ្នាជាគូតែម្តង។

2 **សៈ** ចាស ហើយតើស្ត្រីដែលលោករៀបការជាមួយនឹង គាត់ជាប្រជាពលរដ្ឋខ្មែរធម្មតា ឬក៏ជា
3 ជនជាតិភាគតិចដែរ? ហើយលោកស្គាល់គាត់ពេលណាដែរ?

4 **ជៈ** បាទ បញ្ហាហ្នឹង គឺខ្ញុំសូមឆ្លើយបន្តិច បើចង់ឲ្យច្បាស់ទៀត អាហ្នឹងវាវែងពេក វែងពេក។
5 មូលហេតុដែលខ្ញុំឡើងពី៩២០ទៅ១០៥នេះ គោលដៅគេឲ្យពង្រីកប្រជាពលរដ្ឋនៅក្នុងខេត្តមណ្ឌលគិរី
6 នេះនិយាយឲ្យវែង ឲ្យអស់បន្តិចទៅ ដើម្បីឲ្យឆាប់យល់។ អ៊ីចឹងផែនការរបស់គេ គឺបុរសហ្នឹងគឺយកស្ត្រី
7 ជនជាតិ។ ផែនការណ៎ា! ហើយដល់បុរសជនជាតិ ឲ្យយកស្ត្រីខ្មែរយើងមកពីក្រោម។ អ៊ីចឹងក្នុងអង្គភាព
8 ខ្ញុំហ្នឹង ពីស្រុកមកហ្នឹងស្រី៥០ បុរស៥០ដែរ។ តែខ្ញុំអត់បានអនុវត្តតាមទេ គឺខ្ញុំយកគ្នាខ្ញុំមកពី ទៅពីស្រុក
9 តែម្តង បាទយកខ្មែរគ្នាឯង។

10 [១៤:១២:២០]

11 **សៈ** លោកនិយាយដល់ផែនការដែលរៀបចំឲ្យមានការរៀបអាពាហ៍ពិពាហ៍រវាងខ្មែរជាមួយ
12 នឹងជនជាតិភាគតិច ហើយនិងជនជាតិភាគតិចជាមួយនឹងខ្មែរហ្នឹង តើផែនការហ្នឹងដាក់ចេញមកពីថ្នាក់
13 ណាដែរ? ហើយអ្នកណាជាអ្នកណែនាំ ឬក៏ដាក់បញ្ហាឲ្យមានផែនការបែបអ៊ីចឹង?

14 **ជៈ** បាទ បញ្ហានេះគឺជាឯកសារជាបទបញ្ជា អត់មានទេ។ ប៉ុន្តែឮតៗពីគ្នាតែម្តង គឺគេនិយាយ
15 ៗដូចខ្ញុំនិយាយពីអ៊ីចឹង។ បាទ គឺដើម្បីឲ្យវាថាច្របាច់សាច់ដាច់ឈាមជាមួយគ្នានេះ រវាងជនជាតិ និង
16 ខ្មែរ អត់មាននេះ។

17 **សៈ** ចុះអ្នកដែលជា ឧទាហរណ៍ថាជាបុរសជនជាតិខ្មែរ ដែលត្រូវរៀបការជាមួយនឹងស្ត្រីដែល
18 ជាជនជាតិភាគតិចហ្នឹង តើត្រូវតែចេះនិយាយភាសាដូចគ្នា ឬក៏អត់ចាំបាច់ចេះនិយាយភាសាជាមួយគ្នា
19 ទេ គឺត្រូវតែរៀបការតែម្តង?

20 **ជៈ** បាទ ទោះបីមានផែនការអ៊ីចឹងក៏ដោយ ខាងចំពោះដែលអង្គភាពខ្ញុំហ្នឹង គឺអត់ៗមានទេ
21 មានតែយកខ្មែរគ្នាឯង ហើយយកខ្មែរគ្នាឯងពីក្រោមទៅ។

22 **សៈ** ចុះលោកអាចលើកឧទាហរណ៍បានទេថា នៅអង្គភាពណា ឬក៏បុគ្គលឈ្មោះណាដែល
23 លោកបាននិយាយមុនហ្នឹង ថាមានផែនការ ហើយរៀបការបុរសជនជាតិខ្មែរជាមួយនឹងស្ត្រីជនជាតិ
24 ភាគតិចនោះ?

25 [១៤:១៤:១៨]

ជៈ បាទអត់មាននិយាយអង្គភាពក្រៅទេ គឺឮអង្គភាពខ្ញុំតែម្តង។ ជាផែនការគេឲ្យរៀបចំអីចឹង ឲ្យយកអីចឹង ប៉ុន្តែខាងខ្ញុំអត់អនុវត្តតាម។ បាទ គឺយកគ្នា ខ្មែរដូចគ្នា។

សៈ ចាស អរគុណ។ មុននេះតាំងពីព្រឹកមក ក៏ដូចគ្នានេះដែរ លោកបាននិយាយអំពីស្ថានភាពលំបាកដែលលោកត្រូវទៅធ្វើការ ដែលនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យហ្នឹង។ សូមលោកជួយបញ្ជាក់ម្តងទៀត ថាតើស្ថានភាពលំបាកដែលលោកទៅធ្វើការក្នុងនាមកងចល័តហ្នឹង តើចាប់ផ្តើមពីពេលណាដល់ឆ្នាំណា? ហើយលំបាកយ៉ាងណាខ្លះដែរ ពីស្ថានភាពរស់នៅ?

ប្រធានអង្គជំនុំ៖

លោកសាក្សី!

លោក ជិន សារឿន៖

ជៈ បាទច្រឡំ! បាទហើយខ្ញុំសូមឆ្លើយសាឡើងវិញចុះ ហើយសូមទោស ដែលចេះតែភ័ន្តច្រឡំ មិនបានមើលភ្លើង។ បាទ គឺគិតទៅខ្ញុំចេញពីខេត្តក្រចេះមក គឺគេដឹកនឹងឡាន។ អីចឹងផ្លូវអត់មានទេ អត់មានផ្លូវទេ មានតែមុខព្រួយ។ អីចឹងពីក្រចេះទៅដល់មណ្ឌលគិរីហ្នឹង គឺមានខ្សែបន្ទាត់អីចឹង បើកឡានដល់ត្រីមណា ដាក់កម្លាំងចុះត្រង់ហ្នឹង ធ្វើត្រង់ហ្នឹង ធ្វើបាន១០ម៉ែត្រ ២០ម៉ែត្រ ៣០ម៉ែត្រ ១០០ម៉ែត្រ បើកឡានតទៅទៀត។ អីចឹងធ្វើដោយកម្លាំងមនុស្ស អត់មានគ្រឿងចក្រអីទេ។ អាហ្នឹងគឺរយៈពេលប្រហែលជាជាង១ខែបានត្រួសត្រាយផ្លូវហ្នឹងដល់កោះញែក។ បានដល់កោះញែក គឺទៅអត់មានអ្នកណាធ្វើផ្ទះឲ្យទេ គឺកងខ្លួនឯងហ្នឹង គឺធ្វើកាប់ឫស្សី គាប់បន្ទាំ មកធ្វើជាផ្ទះ។ អីចឹងគឺបានរៀបចំ ផែនការគេហ្នឹង គឺរៀបចំឲ្យធ្វើជាការដ្ឋាន គេហៅថាស្រែ ធ្វើស្រែ។ អីចឹងការធ្វើនេះ និយាយពីការងារពលកម្ម គឺគេងពីព្រឹកម៉ោងប្រាំអីគឺផ្តុំកញ្ចែ។ ផ្តុំកញ្ចែហ្នឹង គឺហាត់ ហាត់ជារបៀបកងទ័ពអីចឹង លូនក្រាប សម្រាកប្រុងអី ហាត់ប្រាណអីចឹង។ អីចឹងដល់ម៉ោងប្រាំមួយ ប្រាំមួយព្រឹក ប្រាំមួយព្រឹកហ្នឹងគឺលុបលាងមុខមាត់ ដល់ម៉ោងប្រាំមួយកន្លះញ៉ាំបាយ។ ពេលញ៉ាំបាយរួចម៉ោងប្រាំពីរ ចុះទៅការដ្ឋាន។ ការទៅធ្វើហ្នឹង គឺលើកភ្លឺ និងផ្លាក់ដី គឺអត់មាន១នង្គ័ល អត់មានគោ អត់មានគោយន្ត គ្មានអាត្រាក់អីទេ គឺកម្លាំងពលកម្មយុវវ័យតែម្តង។

[១៤:១៧:២៦]

បាទអីចឹង គឺអ្នកខ្លះហ្នឹងទ្រាំទ្រ កាប់ ខ្លះដេកនៅនឹងភ្លឺស្រែ ខ្លះគឺកាប់ៗហ្នឹងសម្រាក អត់ប៉ានយូរទេ អត់ប៉ានយូរទេ ដូចថាវាខ្សោយពេកទៅ លួចសម្រាកបន្តិចទៅ រួចហ្នឹងកាប់ទៀតទៅ។ អីចឹងគឺ

ម៉ោងដប់មួយគឺឡើងមកវិញ។ ម៉ោងដប់មួយកន្លះ ញ៉ាំបាយហើយអ៊ីចឹងទៅសម្រាក ដល់ម៉ោងមួយកន្លះ គឺចូលធ្វើការទៀត រហូតដល់ម៉ោងប្រាំល្ងាច។ ញ៉ាំបាយអីហើយ អីហើយអ៊ីចឹង ម៉ោងប្រាំមួយកន្លះល្ងាចហ្នឹង ចេញដំណើរទៅទៀត។ ចេញទៅធ្វើការទាំងយប់ ដល់ម៉ោងដប់មួយយប់។ អ៊ីចឹងរយៈកាលខ្លះហ្នឹងគឺទ្រាំបានត្រឹម កម្លាំងទេ និយាយពីកម្លាំង។ អ៊ីចឹងដល់ពេល១០ថ្ងៃ ឬ២០ថ្ងៃ គឺខ្សោយមែនទែនហើយ។ ចំពោះខ្ញុំផង ជួនណាពេលយប់ ពេលយប់ហ្នឹងគឺអត់មានពិលមានគោមអីទេ ដុតឫស្សី ធ្វើពន្លឺដើរ។ ជួនណាដេក ឡើងពីភ្លឺមួយហ្នឹង អ្ហ៎! អញដល់ភ្លឺហើយ។ ចុះពីភ្លឺដើរទៀត បុកភ្លឺមួយទៀតបានភ្ញាក់មានអ្នកដើរតាមគ្នា តាមសម្រិបជើង។ អាហ្នឹងគឺឃើញថា វាបើនិយាយពីការងារពលកម្ម វា។លើសពីកម្លាំងយើង ហើយការហូបចុកអី ពេលព្រឹកគឺហូបបបរ ពេលថ្ងៃត្រឡប់មកវិញញ៉ាំបាយមួយចាន គេហៅថាមួយចានចង្កឹះ អត់មានលើសទេ គឺមួយចានចង្កឹះម្នាក់។ អាហ្នឹងសូមបញ្ជាក់ប៉ុណ្ណឹង។

[១៤:១៩:០៧]

សួរដោយកញ្ញា សុង ឆវ៉ន្ត៖

ស៖ ចាស អរគុណ។ សំណួរចុងក្រោយ លោកសាក្សីនៅក្នុងចម្លើយរបស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺនៅត្រង់ឯកសារ E3/10578 ខ្មែរ ERN 00042513, ERN ជាភាសាអង់គ្លេស 01249752 ដល់53, ជាភាសាបារាំង 0124976។ លោកបាននិយាយថា៖ “គេមិនខ្វល់ថាពួកយើងមានហូបឆ្អែត ឬអត់នោះទេ”។ ហេតុអ្វីបានជាលោកនិយាយដូច្នេះ?

ឆ៖ បាទ បញ្ហានេះគឺគេអត់ដឹងថា យើងញ៉ាំឆ្អែត មិនឆ្អែតអីទេ គឺគេដឹងថា ធ្វើម៉េច ធ្វើពលកម្មឲ្យបានតាមផែនការរបស់ថ្នាក់លើដាក់ ប៉ុណ្ណឹង។ រឿងយើងញ៉ាំឆ្អែតមិនឆ្អែតអី ទោះបីអ្នកណាញ៉ាំតិចទៅសល់ ក៏មិនខ្វល់អីដែរ ប៉ុន្តែឃុវវ័យមិនរឿងសល់ទេ មួយចានចង្កឹះប៉ុណ្ណោះនោះ។ គឺអត់មានខ្វល់និយាយរឿង ចង់បានតែរឿងពលកម្ម។

កញ្ញា សុង ឆវ៉ន្ត៖

ចាស សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។ ខាងតំណាងអយ្យការអស់សំណួរ។

ប្រធានអង្គជំនុំ៖

សូមអរគុណលោកព្រះរាជអាជ្ញា។ ជាបន្តផ្តល់វេទិកាដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរលើសាក្សីនេះ។ សូមអញ្ជើញ!

[១៤:២០:៥២]

លោក ពេជ អង្គ៖

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ មេធាវីនាំមុខ សូមអនុញ្ញាតប្រគល់សិទ្ធិជូនលោកមេធាវី វ៉ែន ពៅ ដើម្បីសួរទៅលោកសាក្សីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។

ប្រធានអង្គជំនុំ៖

សូមអញ្ជើញលោកមេធាវី!

លោក វ៉ែន ពៅ៖

បាទ សូមជម្រាបសួរលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

សួរដោយលោក វ៉ែន ពៅ៖

ស៖ ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ វ៉ែន ពៅ ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនដែលត្រូវសួរលោក ពាក់ព័ន្ធនឹងចម្លើយរបស់លោកដែលបានឆ្លើយរួចហើយ ជាមួយមជ្ឈមណ្ឌលឯកសារ។ សំណួរខ្ញុំជាដំបូង គឺពាក់ព័ន្ធទៅនឹងចម្លើយរបស់លោកនោះ គឺលេខឯកសារ គឺ E3/7960។ ERN ជាភាសាខ្មែរ 00851665, ERN ជាភាសាអង់គ្លេស 00450295 និង ERN ជាភាសាបារាំង 00763898។ នៅក្នុងចម្លើយរបស់លោក លោកបានឆ្លើយថា ខេត្តមណ្ឌលគិរី ឬក៏ឈ្មោះតំបន់១០៥ ដែលជាតំបន់ស្វយ័ត។ សំណួររបស់ខ្ញុំចង់សួរថា តើលោកដឹងថា ខេត្តមណ្ឌលគិរីដែលជាតំបន់ស្វយ័តនេះ មកពីណា? អ្នកណាប្រាប់លោក? ហេតុអីបានជាលោកដឹងថា ជាតំបន់ស្វយ័ត?

[១៤:២២:៣៤]

លោក ជិន សារឿន៖

ឆ៖ បាទ ដែលខ្ញុំដឹងថា តំបន់ស្វយ័តនេះ ព្រោះធម្មតាកាលណាស្រុកវាមានខេត្ត ហើយដល់ខេត្តវាត្រូវមានភូមិភាគ។ នេះគឺមេខ្ញុំគាត់និយាយថា មេ -- ខេត្តឡើងទៅភ្នំពេញផ្ទាល់តែម្តង អត់មានភូមិភាគ។ អ៊ីចឹងគឺឮតាមមេខ្ញុំ។

ស៖ អ៊ីចឹងបានន័យថា តំបន់ស្វយ័តហ្នឹង មានលក្ខណៈពិសេសជាងតំបន់ធម្មតាមែនទេ ដែលត្រូវរាយការណ៍ផ្ទាល់មកភ្នំពេញ បានន័យអ៊ីចឹង មែនទេលោក?

ជៈ បាទ តាមខ្ញុំដឹង គឺអ៊ីចឹងហើយ។ អ៊ីចឹង គឺឡើង*ភាយវិច* ផ្ដាល់តែម្ដង។

សៈ បាទ សូមអរគុណ។ ហើយនៅក្នុងចម្លើយរបស់លោកនៅឯកសារដដែលហ្នឹងដែរ លោកបានឆ្លើយថា លោកបានឆ្លើយថា "នៅចុងឆ្នាំ៧៦ យោធាតំបន់បានស្នើសុំប្រជាជនថ្មីឲ្យមករស់នៅខេត្តមណ្ឌលគិរី ដើម្បីបង្កបង្កើនប្រជាជននៅខេត្តនេះ"។ តើលោកអាចបញ្ជាក់បានទេ ប្រជាជនថ្មីដែលលោកចង់សំដៅហ្នឹងគឺមកពីណា? មកពីខេត្តផ្សេងៗ ឬក៏ប្រជាជន១៧មេសា លោកអាចបញ្ជាក់បានទេ?

ជៈ បាទបញ្ជោហ្នឹង គឺមិនមែនប្រជាជន១៧មេសាទេ ដូចខ្ញុំបាននិយាយហើយ ខ្ញុំ កាលខ្ញុំធ្វើការក្នុងឃុំហ្នឹងគេជ្រើសរើស អ្នកណាដែលអត់មានពាក់ព័ន្ធនិន្នាការ១៧មេសា បងប្អូនជាមេឃុំ មេស្រុក មេខេត្តអី ជំនាន់សង្គមនោះគឺគេយក គេយក។ អ៊ីចឹងកម្លាំងដែលកែនមកមណ្ឌលគិរី គឺសុទ្ធតែអ្នកកសិករ ហើយមក រួមគឺទៅពីតាកែវ ហើយនិងភូមិភាគឧត្តរ ខាងសៀមរាប ពីកម្លាំងពីរខេត្តហ្នឹងទៅ។ ខាងខ្ញុំគឺទៅមួយខេត្ត ហើយខាងឧត្តរ គេទៅដែរ គឺជួបជុំគ្នានៅទន្លេបួនមុខហ្នឹង ជិះកាណូតទៅជាមួយគ្នាតែម្ដង។

[១៤:២៥:០២]

សៈ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា តើប្រជាជនដែលលោកសំដៅនោះ គឺបានទៅជាមូលដ្ឋានគ្រួសារយោធា ឬក៏ប្រជាជនធម្មតាដែលទៅពី លោកថាភូមិភាគឧត្តរនោះ និងខេត្តតាកែវសុទ្ធតែជាគ្រួសារមូលដ្ឋានកងទ័ព ឬក៏ប្រជាជនធម្មតាដែរបាទ?

ជៈ បាទ ចំពោះខាងឧត្តរខ្ញុំមិនសូវច្បាស់ ប៉ុន្តែច្បាស់ខាងខេត្តខ្ញុំគឺយកប្រជាជន កូនប្រជាជននៅតាមភូមិតែម្ដង អត់មានដែលធ្វើអីទាំងអស់។

សៈ បាទ សូមអរគុណ។ នៅក្នុងចម្លើយរបស់លោក ក៏បានធ្លាប់បញ្ជាក់ថានៅក្នុងពេលមួយនោះ លោកត្រូវបានគេបញ្ឈរជើង៣ខែដែរ។ ខ្ញុំចង់សួរថាតើគេបញ្ឈរជើងលោកនោះ ដោយសារលោកមានកំហុសអី លោកអាចបញ្ជាក់បានទេ?

ជៈ បាទ បញ្ជោបញ្ឈរជើងនេះ គឺខ្ញុំសូមបញ្ជាក់លោកប្រធាន ក៏ដូចជាបងដែលសួរ គឺខ្ពាចខាងស្រាវជ្រាវក្ដាប់មិនបានមិនដឹងទេ គាត់ដាក់ក្នុងឯកសារចម្លើយរបស់ខ្ញុំនោះណ៎ា។ ប៉ុន្តែក្នុងន័យថា បញ្ឈរហ្នឹងគឺមិនមែនបញ្ឈរមានកំហុសអីទេ គេឲ្យយើងសម្រាក ព្រោះឃើញស្គមៗពេកទៅពី៩២០ វាអើ! ចុះបើប្រុសមុខឡើងដូចស្ដីហើយ នារីក៏ដូចគ្នាដែរ។ អ៊ីចឹងគឺទៅដល់តំបន់ហ្នឹង គេមិនឲ្យធ្វើការអីទាំងអស់

គេឲ្យតែហូប ហើយនិងដើរលេង។

សៈ បាទ សូមអរគុណ។ តើនៅក្នុងតំបន់១០៥ដែលលោកស្នាក់នៅ និងធ្វើការនោះ ថាតើក្នុងអំឡុងពេលនោះ លោកមានបានចូលរៀនវគ្គរៀនសូត្រ ឬក៏បំពាក់បំប៉នអីដែរទេ?

[១៤:២៧:១៥]

ជៈ បាទ បញ្ហានេះ ដូចខ្ញុំបាននិយាយហើយថា ក្រោយពីគេឲ្យខ្ញុំសម្រាករយៈពេលខែមក គឺខាងតំបន់គេជ្រើសរើសខាងខ្ញុំហ្នឹងមួយចំនួនទៅនៅជាមួយអង្គភាពការពារ គឺវរសេនាតូច៥០២នោះ។ អីចឹង គឺការរៀនសូត្រអត់មានបានទទួលអីក្រៅពីដែលខ្ញុំបាននិយាយទេ គឺអប់រំតែពីរឿងកសាង និងការពារ។ កសាងហ្នឹងគឺបង្កបង្កើនផល ប៉ុន្តែមិនក្តៅដូចកាលនៅ៩២០ទេ។

សៈ បាទ ហើយនៅសម័យនោះ លោកដែលឮស្ទូរពាក្យថា “បោសសម្អាតខ្មាំង ឬក៏អ្នកដែលក្បត់ផ្ទៃក្នុងបក្ស” អីទេ លោកដែលឮស្ទូរពាក្យហ្នឹង ឬក៏លោកធ្លាប់បានទទួលការរៀនសូត្រពីបញ្ហាពាក្យអស់ទាំងហ្នឹងទេ?

ជៈ បាទ ចំពោះឮគឺឮ រឿងថាបោសសម្អាត ប៉ុន្តែត្រង់ឃើញ ហើយនិងត្រង់ដឹងនៅអង្គភាពខ្ញុំវាអត់ធ្លាប់មាន អង្គភាព ដោយឡែកតែនៅព្រំដែនទេ បើថាខាងៗនៅនឹងស្រុក នៅនឹងខេត្តហ្នឹងអាហ្នឹងគឺខ្ញុំអត់ដឹងទេ ព្រោះគ្រាន់តែឮថាគេបោសសម្អាត បោសសម្អាតហ្នឹង។

សៈ បាទ សូមអរគុណ។ តើលោកដែលឮពាក្យថាខ្មាំងទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺគេចាត់ទុកមនុស្សប្រភេទណាថាជាខ្មាំង លោកអាចធ្លាប់ឮ ឬមានអ្នកណាប្រាប់លោកទេថាពាក្យថាខ្មាំងហ្នឹង គឺសំដៅលើមនុស្សណាខ្លះលោកមានបានដឹង បានឮបញ្ហានេះទេ?

[១៤:២៩:០៦]

ជៈ បាទ បញ្ហានេះគឺបានឮ ហើយនិងដឹង គឺចង់និយាយថា កំណត់ថាខ្មាំងនេះគឺឧទាហរណ៍ថាយើងកាប់ដី ផ្តាក់ដីអីចឹង បើយើងមិនចេះថ្នមសម្ភារៈហ្នឹង គេថាយើងខ្មាំងហើយ យើងបំផ្លាញទ្រព្យសម្បត្តិរដ្ឋ។ អាហ្នឹងគឺអត់មានថាខ្មាំងទាក់ទងជាមួយខ្សែនេះខ្សែនោះទេ គឺខ្មាំងហ្នឹង គឺបំផ្លាញសម្ភារៈគឺដូចថាចបដែលយើងកាប់អីចឹង កាលណាបាក់ទៅ គេៗម្នាក់ទៀតគេថាន៎ែ! អ្នែងខ្មាំងហើយ។ អីចឹងបានដូចខ្ញុំនិយាយហើយ ខ្ញុំថាខ្ញុំៗកាប់ ពេលជាប់ឫសភ្លុកអីអត់ប៊ានគាស់ទេ យកដៃអង្រួនអីចឹងហ្មង ទាល់តែចេញបានៗបន្តកាប់ទៀត។

សៈ ចុះលោក ៗថាខ្មាំង កាលណាធ្វើអីខុស ដូចជាធ្វើការងារធ្វេសប្រហែសអីជាដើម ថាតើ

ចុះទោសកំហុសដែលគាត់ចាត់ទុកថាខ្លាំងហ្នឹង តើគេដាក់ទោសដោយរបៀបណាដែរទៅ?

ឆៃ៖ បាទ ចំពោះអង្គភាពខ្ញុំអត់ដែលៗឃើញគេចាប់ដាក់ទោស ដាក់អីទេ ព្រោះអប់រំតែៗថា គ្នាយើងធ្វើអីក៏ដោយប្រយ័ត្នប្រយែង ប្រយ័ត្នប្រយែង កុំឲ្យបាក់ តែបាក់ អង្គការចោទយើងថាខ្លាំងហើយ។ អ៊ីចឹងនាំគ្នាចេះតែប្រយ័ត្នអ៊ីចឹងទៅ។

សេ៖ បាទ កាលពីព្រឹកមិញ លោកបានឆ្លើយទៅនឹងសំណួររបស់ព្រះរាជអាជ្ញា លោកថានៅសម័យនោះកាលណាប្តីគេចោទថាខុស ឬក៏មានកំហុស ប្រពន្ធឬក៏កូនហ្នឹងត្រូវបានគេចាប់យកទៅហើយ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថាតើលោកសំដៅថាពាក្យថា “កំហុស ឬខុស” ហ្នឹងគឺកំហុសអីជាក់លាក់ទៅដែលគេថា ចោទថាខុសហ្នឹង គឺខុសអីខ្លះ? លោកអាចបញ្ជាក់បានទេ?

[១៤:៣១:១៧]

ឆៃ៖ បាទ ក្នុងចម្លើយ ក្នុងឯកសារដែលខ្ញុំបានឆ្លើយនេះគឺ កំហុសត្រង់ថា គាត់ម្នាក់ហ្នឹងឈ្មោះ រ៉ែត បាទ រ៉ែត ហ្នឹងគឺគាត់កងពល អនុកងពល៩១៦។ អ៊ីចឹងគាត់ទៅសារភាពជាមួយខាងរដ្ឋកម្ពុជានៅសៀមរាប។ អ៊ីចឹងប្រពន្ធគាត់នៅជំរំ ដែលខ្ញុំឃើញជាក់ស្តែងនេះគឺចង់និយាយថា ពេលដឹងថាប្តីគាត់ចូលសារភាពហើយ គឺប្រពន្ធ គេយកទៅដាក់សន្តិសុខអូរកេងកងតែម្តង។

សេ៖ បាទ សូមអរគុណ។ ខ្ញុំចង់សួរលោកមួយទៀត ពាក់ព័ន្ធនឹងថ្នាក់ដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ ថាតើលោកមានដឹង ឬមានពីណាប្រាប់លោកថា ក្នុងរបបនេះ នៅតំបន់១០៥ហ្នឹងមានថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យណាខ្លះ បានទៅធ្វើទស្សនកិច្ចនៅនោះ? លោកបានដឹង ឬមានពីណាប្រាប់លោកទេ?

ឆៃ៖ បាទពេលដែលខ្ញុំមកដល់តំបន់១០៥នេះហើយ គឺអត់ដែលបានដឹងថាថ្នាក់ដឹកនាំណាគេទៅទស្សនកិច្ចណាអីទេ គឺអត់ដឹងទេ។

សេ៖ បាទ សុំអរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ ៗចង់បញ្ជាក់ពីរឿងការរៀបការរបស់លោកបន្តិច។ លោកអំមិញបានបញ្ជាក់ជូនសហព្រះរាជអាជ្ញាជាតិហើយថា លោករៀបការនៅឆ្នាំប្រហែល ១៩៧៧។ ថាតើពេលដែលលោករៀបការនោះ លោកស្គាល់ប្រពន្ធលោកមុន ឬក៏អត់ស្គាល់ទេ គេចាប់ផ្សំផ្គុំលោក?

ឆៃ៖ បាទ ចំពោះខ្ញុំផ្ទាល់គឺស្គាល់គ្នាមុន ស្គាល់គ្នាមុន គឺមូលហេតុអី គឺមេហ្នឹងគាត់ស្រឡាញ់ខ្ញុំ រាប់អានខ្ញុំជាប្អូនធម៌ អ៊ីចឹងគឺគាត់ប្រាប់មុន។ “ប្រាប់មក ឯងស្រឡាញ់អត់ណៅ៎ នេះមិត្តនេះ?” អ៊ីចឹងគឺ

ដឹងគ្នាហើយ។ ឯក្រៅពីហ្នឹង ហៅមកសួរបណ្តោយ ព្រម មិនព្រមអីគឺត្រូវតែព្រម។

[១៤:៣៣:៤២]

សៈ អ៊ីចឹងបាននិយាយថា ជាសំណាងតែលោកមួយទេ ក្រៅពីហ្នឹងអ្នកដទៃត្រូវបានគេបង្ខំ។ អ៊ីចឹងមែនទេ?

ឆៈ បាទ។

ប្រធានអង្គជំនុំៈ

សូមអរគុណលោកមេធាវី។ សូមអញ្ជើញលោកចៅក្រម!

លោកស្រី ម៉ារី ហ្គ្រីវ៉ដ៍ៈ

លោកប្រធាន។ ខ្ញុំឃើញថា យើងនៅសល់ប្រហែលជា៥នាទីទៀត ហើយខ្ញុំមានសំណួរមួយចំនួនតូច សួរពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍។ បើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសូមសួរបន្តបន្តិចទៀតទេ លោកប្រធាន។

ប្រធានអង្គជំនុំៈ

សូមអញ្ជើញលោកមេធាវី!

លោកស្រី ម៉ារី ហ្គ្រីវ៉ដ៍ៈ

សូមអរគុណលោកប្រធាន។

សួរដោយលោកស្រី ម៉ារី ហ្គ្រីវ៉ដ៍ៈ

សៈ ជម្រាបសួរលោកសាក្សី ខ្ញុំមានមួយចំនួនតូចទេ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍១៦គូ ដែលលោកទើបតែនិយាយនេះ។ លោកនិយាយអំពីស្ត្រីដែល<>មេបញ្ជាការរបស់លោក<ណែនាំឲ្យលោក>។ ខ្ញុំចង់ដឹងថា ស្ត្រីហ្នឹងជាទាហាន ឬក៏ជាស៊ីវិល?

[១៤:៣៥:១៧]

លោក ជិន សារឿនៈ

ឆៈ បាទ ស្ត្រីដែលជាភរិយាខ្ញុំហ្នឹង គឺជាកងចល័តនៅក្នុងអង្គភាពហ្នឹង ជាកងចល័តមក ទៅពីតាកែវជាមួយខ្ញុំ។

សៈ ចុះក្នុងចំណោម១៦គូហ្នឹង ទាំងស្ត្រី និងបុរសដែលរៀបការនៅថ្ងៃហ្នឹង គឺមកពីកងតែមួយមែនទេ?

ជៈ បាទ នៅក្នុងអង្គភាពតែមួយ។

សៈ មុននេះលោកឆ្លើយថា គេអនុគ្រោះចំពោះលោក ពីព្រោះថាមេបញ្ជាការរបស់លោកហ្នឹងស្រឡាញ់ចូលចិត្តលោក។ ចុះបុរសផ្សេងទៀតដែលរៀបការនៅថ្ងៃនោះដែរនុង៎ គាត់ស្គាល់ប្រពន្ធដែលគាត់រៀបការហ្នឹងជាមុនទេ?

ជៈ បាទ ស្គាល់ ស្គាល់គ្នាទៅវិញទៅមក ប៉ុន្តែគ្រាន់ថា មួយណាជាគូអ្នកណា គឺអត់ដឹងទាំងអស់ ទាល់តែថ្ងៃដែលមេបញ្ជាការគាត់ហៅទាំងពីរហ្នឹងមក ទល់គ្នាតែម្តង ឧបមាថា លោក“ក”ឯងស្រឡាញ់ នាង“ខ”អត់ ចិត្តគឺអត់មានហ៊ានប្រកែកទេ ត្រូវតែស្រឡាញ់អ៊ីចឹងឯង។ ហ្នឹងគឺនៅអង្គ -- ជួបគ្នា គឺរៀបតែម្តង។ សួរល្ងាចហ្នឹង ស្អែកឡើងការទៅបណ្តោយ។

សៈ ចុះនៅថ្ងៃនុ៎ង មានបុរស ឬស្ត្រីណាប្រកែកមិនព្រមរៀបការទេ?

[១៤:៣៧:២៧]

ជៈ បាទ ក្នុង១៦រូបហ្នឹងមានមួយរូបដែរ ប្រកែក ក៏ប៉ុន្តែដូចថា មេគាត់ហៅទៅសម្រុះសម្រួលគ្នាទៅ ក៏បានឯកភាពចូលរៀបការទៅ។ ប៉ុន្តែក្នុងការហ្នឹង ហ្នឹងនិយាយជាការពិត គឺនារីគ្នាស្លៀកពាក់ស្អាតអ៊ីចឹងហើយ ឯបុរសដែលមិនពេញចិត្តហ្នឹង គឺស្លៀកពាក់ខោអាវរហែកចូលរៀបការជាមួយគ្នាតែម្តង។ ប៉ុន្តែពិសោធទៅ មានតែគាត់ហ្នឹងទេដែលនៅ។ អ៊ីចឹង១៦គូ សុំៗលើសសំណួរបន្តិចហើយ ១៦គូហ្នឹង នៅតែពីរៗគូទេ នៅខ្ញុំមួយ ហើយនិងគាត់ហ្នឹង។ ក្រៅពីហ្នឹង ដឹងទៅណាអស់ហើយទេ។ គេទៅស្រុក ទៅភូមិគេអស់ហើយ។

សៈ សូមអរគុណ។ តើគេមានពន្យល់ប្រាប់លោកទេថា មូលហេតុអីបានជាគេឲ្យលោករៀបការជាមួយស្ត្រីនុ៎ងនៅថ្ងៃនុ៎ង? ហើយអ្នកផ្សេងទៀតក៏ដូចគ្នាដែរ តើគេមានបានពន្យល់អំពីមូលហេតុដែលគេតម្រូវឲ្យរៀបការទេ?

ជៈ បាទ បញ្ហាហ្នឹង ដូចខ្ញុំបាននិយាយខាងដើមអ៊ីចឹង គឺជាបុរស និងស្ត្រី ក្រៅពីខ្ញុំម្នាក់ហ្នឹងគឺអត់ដឹងគ្នាទេ អត់ដឹងគូអ្នកណា គូអ្នកណាទេ អត់ទេ។ ហើយអ៊ីចឹងហ្នឹង គ្រាន់តែផ្សព្វផ្សាយពីព្រឹកហ្នឹងថា ឥឡូវអង្គការនឹងរៀបចំឲ្យពួកឯងមានប្តី មានប្រពន្ធ។ អ៊ីចឹងដល់ពេលល្ងាច គឺគេហៅឈ្មោះដែលត្រូវសួរហ្នឹង មកតែម្តង។ មួយគូៗមក សួរគ្នាទៅ។ ខ្ញុំសូមអស់ប៉ុណ្ណឹង។

សៈ មុននេះលោកបានឆ្លើយថា គេមានផែនការរៀបការរវាងខ្មែរនឹងស្ត្រីជនជាតិភាគតិច ដើម្បីបង្កើនប្រជាជនខ្មែរ នេះបើតាមអ្វីដែលខ្ញុំយល់។ តើលោកទទួលបានព័ត៌មានស្រដៀងគ្នាហ្នឹងទេ ពាក់ព័ន្ធ

នឹងការរៀបការរបស់លោកហ្នឹង? គេឲ្យលោកការ គេឲ្យលោករៀបការហ្នឹង គឺគេមានគោលដៅមួយ គឺបង្កើនចំនួនប្រជាជន តើលោកមានយល់អ៊ីចឹងទេ?

[១៤:៤០:១១]

ជៈ បាទ បញ្ហាហ្នឹងគឺយល់ថា ឲ្យរៀបការហ្នឹងគឺដើម្បីបង្កើនប្រជាជនក្នុងខេត្តហ្នឹងឲ្យបានច្រើន។ ក៏ប៉ុន្តែដូចឮពាក្យថា ខ្មែរយកជនជាតិ ជនជាតិយកខ្មែរនេះ គឺដើម្បីឲ្យវាសាច់ ភ្ជាប់សាច់ ភ្ជាប់ឈាមគ្នាតែមួយ កុំឲ្យមានខ្មែរ ឲ្យមានជនជាតិ។ ប៉ុន្តែដោយឡែក ដូចខ្ញុំបានបញ្ជាក់ខាងដើមអ៊ីចឹង គឺអត់មានអីណា អ្នកណាយកនារីជនជាតិ ឬក៏បុរសជនជាតិទេ គឺខ្មែរយកខ្មែរគ្នាឯង។

សៈ សំណួរចុងក្រោយលោកប្រធាន ខ្ញុំសុំអនុញ្ញាត។ តើគេមានប្រាប់ឲ្យលោករួមដំណេកជាមួយប្រពន្ធរបស់លោកទេ នៅពេលដែលយប់រៀបការហើយនោះ? ហើយប្រសិនបើគេឲ្យលោករួមដំណេកនោះ តើដំណើរការនៃការរួមដំណេកហ្នឹង ប្រព្រឹត្តទៅយ៉ាងម៉េចខ្លះ?

ជៈ បាទ នេះជាការរួមដំណេក គឺជារឿងផ្ទៃក្នុងរវាងពីរនាក់ទេ ក៏ប៉ុន្តែគ្រាន់ថា ពេលរៀបហើយដែលទើបហើយហ្នឹង ប្រធានអង្គភាពហ្នឹងបានប្រគល់ផ្ទះឲ្យ មួយគូផ្ទះមួយ មួយគូផ្ទះមួយ អ៊ីចឹង គឺខាងស្រីទៅនៅ ចាំនៅផ្ទះទៅ ហើយខាងបុរសហ្នឹងគឺមានអ្នកចាស់ព្រឹទ្ធាចារ្យ អាយុច្រើនជាងគេម្នាក់ហ្នឹង គឺនាំជូនទៅផ្ទះស្ត្រីហ្នឹង គឺគេបានរៀបចំអ៊ីចឹងឯង។

សៈ ពេលយប់ហ្នឹងគេមានតាមដានលោកទេ? លោកមានឃើញអ្នកណាម្នាក់លបមើលលោកអីទេពេលយប់ហ្នឹង?

ជៈ បាទ គឺមិនមានអ្នកណាលបលួចមើលអីទេ ព្រោះកាលនោះ ដូចជាថា វិន័យតឹងណាស់។ តែយប់ហើយ ក្រៅពីផ្ទះខ្លួនឯងអត់មានដើរឆ្វែងឆ្វាត់ទេ។

[១៤:៤៣:១២]

លោកស្រី ម៉ារី ហ្គ្រីវ៉ង់ៈ

សូមអរគុណលោកប្រធាន។ សូមអរគុណលោកសាក្សីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

ប្រធានអង្គជំនុំៈ

សូមអរគុណលោកមេធាវី។ ឥឡូវដែលពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ។

មន្ត្រីតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញមុនពេលចាប់ផ្តើមសវនាការ។

សូមអញ្ជើញសម្រាក!

(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០៧ នាទី)

[១៥:០៨:០១]

ប្រធានអង្គជំនុំ៖

សូមអញ្ជើញអង្គុយ!

ជាបន្តសូមផ្តល់វេទិកាដល់មេធាវីការពារក្តីលោក ខៀវ សំផន តាំងសំណួរសាក្សីនេះ។ សូមអញ្ជើញ!

កញ្ញា អង់តា ហ្គីសសេ៖

លោកប្រធាន អម្បាញ់មិញនេះ ខ្ញុំស្មានថាលោកចៅក្រម ឡាវែន៍ គាត់មានសំណួរស្នូរ។ ហើយបើសិនជានេះនោះ បើថាខ្ញុំដឹងមុននោះ ខ្ញុំប្រហែលជាប្រាប់ទៅអង្គជំនុំជម្រះថាពួកខាងខ្ញុំនេះអត់មានសំណួរទេ លោកប្រធាន។ អម្បាញ់មិញខ្ញុំស្មានថាលោកចៅក្រម ឡាវែន៍ គាត់មានសំណួរ។ អ៊ីចឹងហើយបានចូលពីសម្រាកមកវិញហ្នឹង។

ប្រធានអង្គជំនុំ៖

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

លោក នីកូឡាស គូមជែន៖

សូមអរគុណ។ ដោយសារស្ថានភាពនេះ យើងលើកឡើងអំពីបញ្ហាកិច្ចប្រជុំរៀបចំសវនាការថ្ងៃស្អែក <ឬក៏នៅពេលដែលការសួរសាក្សីបានបញ្ចប់។> ដោយសារតែសាក្សីនេះ គាត់បញ្ចប់នៅពេលនេះ។ ខ្ញុំគិតថាយើងគួរតែធ្វើនៅពេលរសៀល ឬក៏ស្អែកម៉ោងដប់កន្លះ។

(ចៅក្រមពិភាក្សាគ្នា)

[១៥:១០:៥៦]

ប្រធានអង្គជំនុំ៖

សូមអរគុណ។ សវនាការស្តាប់សក្ខីកម្មសាក្សី ជិន សារឿន ដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះ

អរគុណលោក ជិន សារឿន ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សី ក្នុងរយៈពេលមួយថ្ងៃនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៅក្នុងរឿងក្តីនេះ។ ការផ្តល់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ វត្តមានរបស់លោកនៅ អ.វ.ត.ក ដែលងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានឬគោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសំណាងល្អ ហើយមានសេចក្តីសុខ សេចក្តីចម្រើន និងធ្វើដំណើរវិលត្រឡប់ទៅវិញ ប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជួនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយដំណើរការសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះផ្អាកប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការនឹងលើកបន្តធ្វើនៅថ្ងៃចន្ទ ទី ០៨ ខែសីហា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃចន្ទ ទី០៨ ខែសីហា ឆ្នាំ២០១៦ អង្គជំនុំជម្រះនឹងធ្វើសវនាការបង្ហាញឯកសារគន្លឹះរបស់ភាគី។ ដោយឡែកនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦ អង្គជំនុំជម្រះនឹងធ្វើកិច្ចប្រជុំរៀបចំសវនាការ និងចាប់ផ្តើមធ្វើនៅម៉ោងមួយ សាមសិបនាទីរសៀល ដើម្បីពិភាក្សាពីបញ្ហាមួយចំនួនទាក់ទងនឹងការដាក់បង្ហាញឯកសារពីក្នុងសំណុំរឿងផ្សេងៗ និងបញ្ហាផ្សេងៗទៀត។ ហើយកិច្ចប្រជុំរៀបចំសវនាការនេះ នឹងធ្វើឡើងជាអសាធារណៈមួយផ្នែក និងសាធារណៈមួយផ្នែក។ ដូច្នេះសូមភាគី និងសាធារណជនជ្រាប និងអញ្ជើញចូលរួមតាមការកំណត់។

ហើយមេធាវីការពារក្តីទាំងពីរក្រុម បានជូនដំណឹងមកអង្គជំនុំជម្រះថា ជនជាប់ចោទទាំងពីរមិនមានបំណងក្នុងការចូលរួមក្នុងកិច្ចប្រជុំនេះទេ។

ហេតុនេះ អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជាប់ចោទទាំងពីររូប លោក ន្ឈួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការវិញ នៅថ្ងៃចន្ទ ទី០៨ ខែសីហា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

អញ្ជើញសម្រាក៕

(សវនាការផ្អាកនៅម៉ោង ១៥:១៣ នាទី)